សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite Royale de Droit et des Sciences Economoiques.

Royal University of Law and Economics.

## សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍រវាង

# ពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា ត្រា ដារី**

**កញ្ញា ឆេង ស៊ីឌួច**

ណែនាំដោយ

**លោកស្រី ម៉ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ ២៩ (និស្សិតអាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite Royale de Droit et des Sciences Economoiques.

Royal University of Law and Economics.

## សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍រវាង
# ពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា ត្រា ដារី**

**កញ្ញា ឆេង ស៊ីវឡុច**

ណែនាំដោយ

**លោកស្រី ម៉ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ ២៩ (និស្សិតអាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្ដីថ្លែងអំណរគុណ**

ជាបឋមនាងខ្ញុំទាំងពីរនាក់ឈ្មោះ **ឆេង ស៊ីវឆូច** និង **ត្រា ដារី** ជានិសិត្សអាហារូបករណ៍មួយរយភាគរយរបស់ក្រសួងអប់រំយុវជន និងកីឡា ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៩ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០ - ២០២៤។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

- លោកឪពុក **ជុយ ម៉ុនហេន** និងអ្នកម្ដាយ **យ៉ន ស៊ីវឡឹន**
- លោកឪពុក **សក ចិត្រា** និងអ្នកម្ដាយ **ទ៉ា ឌុន**

កូនសូមអរគុណមាតាបិតាទាំងបួន ដែលលោកបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ណែនាំ ផ្ដល់ដំបូន្មានល្អៗ ព្រមទាំងឧបត្ថម្ភទំនុកបម្រុងការសិក្សារៀនសូត្រដល់កូន និងជាមនុស្សដំបូងគេបង្អស់ដែលតែងតែជួយជំរុញ ជួយលើកទឹកចិត្តគ្រប់បែបយ៉ាង តាំងពីកូននៅរៀនថ្នាក់មត្តេយ្យ រហូតមកដល់ថ្នាក់បរិញ្ញាបត្រ។ ហើយទោះបីជាលំបាកយ៉ាងណាក៏ដោយ ក៏លោកអ្នកមានគុណមិនដែលមានប្រសាសន៍ត្អូញត្អែរពីការនឿយហត់អ្វីឱ្យកូនៗដឹងឡើយ។ ផ្ទុយទៅវិញលោកទាំងបួនមានតែខិតខំបន្ថែមក្នុងការណែនាំកូនៗឱ្យខិតខំសិក្សារៀនសូត្រឱ្យបានជ្រៅជ្រះ និងបញ្ចប់ការសិក្សាដោយទទួលបាននូវភាពជោគជ័យ។

នាងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានបើកកម្មវិធីជាច្រើនសម្រាប់ផ្ដល់នូវអាហារូបករណ៍ជូនចំពោះសិស្ស និស្សិតជាច្រើននាក់ដើម្បីជំរុញឱ្យអ្នកទាំងអស់គ្នាបានបន្តការសិក្សារៀនសូត្រ ឱ្យបានខ្ពង់ខ្ពស់គ្រប់ៗគ្នា។ មិនតែប៉ុណ្ណោះ នាងខ្ញុំទាំងពីរនាក់ក៏សូមថ្លែងអំណរគុណចំពោះ **ក្រសួងអប់រំយុវជន និងកីឡា** ដែលបានផ្ដល់នូវអាហារូបករណ៍មួយភាគរយក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះដល់នាងខ្ញុំទាំងពីរនាក់ ព្រមទាំងនិស្សិតជាច្រើននាក់ទៀតផងដែរ។

ទន្ទឹមនឹងគ្នានេះផងដែរ នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអប់រំ បង្ហាត់បង្ហាញផ្លូវយ៉ាងអស់ពីសមត្ថភាពក្នុងការផ្ទេរនូវចំណេះដឹង ការអនុវត្តន៍ បទពិសោធន៍ ការផ្ដល់នូវជំនួយជាឯកសារក្នុងការសិក្សាស្រាវជ្រាវ ដល់នាងខ្ញុំទាំងពីរនាក់ក្នុងការរៀនសូត្រដោយពុំត្រូវការការតបស្នងអ្វីឡើយ។

ជាពិសេសបំផុត នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ សាស្ត្រាចារ្យដឹកនាំសារណានាងខ្ញុំ **លោកស្រី សាស្ត្រាចារ្យ ម៉ៃយ ធីតា** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ទាំង

កម្លាំងកាយ ទាំងកម្លាំងចិត្តក្នុងការផ្តល់ជាដំបូន្មាន គំនិត ចំណេះដឹង ការពិភាក្សាសារយោបល់ ការលើកទឹកចិត្ត ការជំរុញឱ្យខិតខំប្រឹងប្រែង ការបង្ហាញផ្លូវដល់នាងខ្ញុំទាំងពីរនាក់ ចាប់តាំងពីថ្ងៃផ្តើមសរសេរ រហូតមកទល់ថ្ងៃដែលបានទទួលស្នាដៃជាស្ថាពរមួយនេះ គុណបំណាច់មួយនេះគឺមានតម្លៃវិសេសវិសាលពុំអាចកាត់ថ្លៃបាន។

ជាចុងក្រោយនាងខ្ញុំ **ឆេខ ស៊ីវឆ្វច** និង **ត្រា ដារី** សូមថ្លែងអំណរគុណដល់ លោកតាលោកយាយ អ៊ំ ពូ មីង បងប្អូន ទាំងអស់នៃសមាជិកក្រុមគ្រួសារ និងអ្នកគ្រូ លោកគ្រូតាំងពីថ្នាក់មត្តេយ្យ រហូតមកដល់ថ្នាក់បរិញ្ញាបត្រ ទាំងសិស្សច្បង មិត្តភក្តិ រួមទាំងបុគ្គលជាច្រើនរូបទៀតដែលពួកគាត់តែងតែនៅក្បែរនាងខ្ញុំ ចាំជួយលើកទឹកចិត្ត ជួយផ្តល់នូវដំណោះស្រាយល្អៗជាអាទិ៍។ ពិសេសជាងនេះទៅទៀត គឺពួកគាត់ទាំងអស់គ្នាមានភាពជឿជាក់មកលើរូបនាងខ្ញុំទាំងពីរនាក់ ដែលសកម្មភាពមួយនេះ គឺជាចំណែកមួយយ៉ាងធំធេង នៅក្នុងការជំរុញដំណើរការនៃការសិក្សារបស់នាងខ្ញុំទាំងពីរនាក់ឱ្យកាន់តែមានទំនុកចិត្ត និងភាពក្លាហានកន្លងមក។

ជាកិច្ចបញ្ចប់ នាងខ្ញុំទាំងពីរនាក់សូមលំឱនកាយលើកម្រាមទាំងដប់ប្រណម្យបួងសួងសំពះគោរព ដល់អ្នកមានគុណទាំងបួន ញាតិមិត្តជិតឆ្ងាយ ព្រមទាំងថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ និងមិត្តនិស្សិតគ្រប់រូប សូមឱ្យសំណាងល្អ មានសុខភាពមាំមួន ជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាយ៉ាងលម្អិតអស់រយៈពេល ៤ ឆ្នាំ លើផ្នែកនីតិសាស្ត្រកន្លងមកនេះ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាបានផ្តល់នូវពុទ្ធិ ចំណេះដឹងជាច្រើនដល់នាងខ្ញុំទាំងពីរនាក់ ក្នុងការក្រេបជញ្ជក់សិក្សាស្រាវជ្រាវសម្រាប់ប្រើប្រាស់នាថ្ងៃអនាគត។ មិនតែប៉ុណ្ណោះខ្ញុំទាំងពីរនាក់មានសេចក្តីសោមនស្សរីករាយដែលសាកលវិទ្យាល័យបានផ្តល់ឱកាសដល់ នាងខ្ញុំទាំងពីរនាក់ក្នុងការបញ្ចេញនូវសមត្ថភាពចងក្រងសារណាក្រោមប្រធានបទស្តីពី « **អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា** » ក្នុងការបញ្ចប់ការសិក្សាមួយនេះ ដើម្បីទុកជាស្នាដៃនៃការសិក្សារយៈពេល ៤ ឆ្នាំរបស់យើងខ្ញុំទាំងពីរនាក់ និងបានរក្សាទុកជាឯកសារសម្រាប់ជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗទៀតផងដែរ។

ការជ្រើសរើសប្រធានបទនេះឡើងក៏ព្រោះតែ នៅក្នុងប្រទេសកម្ពុជាយើងនេះ ចំណងអាពាហ៍ពិពាហ៍គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ហើយវាក៏ជាដំណាក់កាលដំបូង មុននឹងឈានទៅដល់ការបង្កើតគ្រួសារនាពេលអនាគត។ ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋខ្មែរមួយចំនួនតែងយល់ច្រឡំថា ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី គឺជាការរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់កំណត់ទៅវិញ។ ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍បែបនេះ វាជាការអនុវត្តន៍ទៅតាមប្រពៃណីដូនតាតែប៉ុណ្ណោះ ហើយក៏មិនមានអានុភាពតាមផ្លូវច្បាប់នោះដែរ។ ដោយសារតែមើលឃើញថា ប្រជាពលរដ្ឋមួយចំនួនតូចពុំទាន់មានការយល់ដឹងទូលំទូលាយអំពីនីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍ ទើបពួកខ្ញុំសម្រេចចិត្តលើកយកប្រធានបទនេះដើម្បីបង្ហាញដល់បុគ្គលគ្រប់រូបដែលមានបំណងបង្កើតគ្រួសារពេលអនាគតឱ្យបានយល់ដឹងកាន់តែស៊ីជម្រៅពីបែបបទនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងស្របតាមការកំណត់របស់ច្បាប់ ដែលនាំឱ្យអាពាហ៍ពិពាហ៍នោះរឹងមាំ មានសុភមង្គល និងយូរអង្វែង។

យ៉ាងណាមិញនាងខ្ញុំទាំងពីរនាក់ សូមធ្វើការអភ័យទោសទុកជាមុនចំពោះការស្រាវជ្រាវលើប្រធានបទមួយនេះ គឺនៅមានចន្លោះខ្វះខាត ទាំងពាក្យពេចន៍ អត្ថន័យ ខ្លឹមសារ អក្ខរាវិរុទ្ធ និងឃ្លោងឃ្លា ត្រង់ណាមួយជាក់ជាពុំខាន។ ពីព្រោះសៀវភៅមួយក្បាលនេះត្រូវបានសង្ខេប និងសម្រាយយកតែខ្លឹមសារមួយចំនួនដែលពាក់ព័ន្ធទៅនឹងប្រធានបទខាងលើតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ សូមលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានជាទីរាប់អាន មេត្តាខន្តីអភ័យទោស ចំពោះកំហុសខុសឆ្គងដោយប្រការណាមួយដោយអចេតនាក្នុងការស្រាវជ្រាវរបស់នាងខ្ញុំទាំងពីរនាក់ដោយក្តីអនុគ្រោះផង។

ជាចុងក្រោយនាងខ្ញុំទាំងពីរនាក់សូមស្វាគមន៍ទទួលរាល់មតិរិះគុណ និងមតិផ្តល់យោបល់ទាំងឡាយពីសំណាក់អស់លោកលោកស្រី លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តអ្នកអានគ្រប់ៗគ្នា ដើម្បីស្ថាបនាកែតម្រូវនូវស្នាដៃមួយនេះឱ្យកាន់តែល្អប្រសើរឡើង។

# មាតិកា

ទំព័រ

**មាតិកា**............................................................................................................................i

**សេចក្តីផ្តើម** ............................................................................................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍**

**១.១. និយមន័យ អាពាហ៍ពិពាហ៍** ................................................................................................... ៦

១.១.១. ក្នុងន័យអក្សរសាស្ត្រខ្មែរ ...................................................................................................... ៦

១.១.២. ក្នុងន័យតាមការកំណត់ច្បាប់.....................................................................................................៧

១.១.២.១. ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ......................................................................................៧

១.១.២.២. សន្ធានុក្រមនៃច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ ២០២៣ ......................................................................................................................................៧

១.១.២.៣. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ............................................................................................ ៨

**១.២. ប្រវត្តិនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទំលាប់** ..................................................... ៨

១.២.១. អាពាហ៍ពិពាហ៍តាមរយៈរឿងព្រេងនិទាន ................................................................................ ៨

១.២.២. អាពាហ៍ពិពាហ៍តាមប្រពៃណីជាតិខ្មែរ.....................................................................................១៩

**១.៣. បទដ្ឋានគតិយុត្តនៃអាពាហ៍ពិពាហ៍**..........................................................................................២៤

១.៣.១. ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ...................................................................................................២៤

១.៣.២. របបនយោបាយផ្តាច់ការ (១៩៧៥–១៩៧៩).............................................................................២៥

១.៣.៣. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ .....................................................................២៦

១.៣.៤. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ...................................................................................................២៧

## ជំពូកទី២

## របបគតិយុត្តនៃអាពាហ៍ពិពាហ៍

**២.១. ទំនាក់ទំនងគតិយុត្តមុនរៀបអាពាហ៍ពិពាហ៍** ........................................................... ២៩

២.១.១. លក្ខខណ្ឌនៃកំជាប់ពាក្យតាមផ្លូវច្បាប់ (មិនមែនជាកាតព្វកិច្ច) ........................................ ២៩

២.១.២. ការរំលាយកំជាប់ពាក្យ ........................................................................................ ៣០

២.១.២.១ ការរំលាយកំជាប់ពាក្យដោយមូលហេតុត្រឹមត្រូវ ......................................................... ៣០

២.១.២.២ ការរំលាយកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ ................................................... ៣១

**២.២. លក្ខខណ្ឌគតិយុត្តដើម្បីរៀបអាពាហ៍ពិពាហ៍** ............................................................. ៣២

២.២.១. លក្ខខណ្ឌភេទរបស់ភាគី ...................................................................................... ៣៣

២.២.២. លក្ខខណ្ឌអាយុរបស់ភាគី ..................................................................................... ៣៤

២.២.២.១. អាពាហ៍ពិពាហ៍របស់ជនដែលទទួលបានអត្តាធីនភាព ................................................ ៣៥

២.២.២.២. អាពាហ៍ពិពាហ៍របស់នីតិជន និងអនីតិជន ........................................................... ៣៦

២.២.៣. ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព .......................................................................... ៣៨

២.២.៤. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត .................................................. ៣៩

២.២.៥. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិ ....................................................... ៤០

២.២.៥.១. ការហាមឃាត់ចំពោះញាតិលោហិតក្នុងខ្សែផ្ទាល់ ........................................................ ៤១

២.២.៥.២. ការហាមឃាត់ចំពោះសាខាញាតិលោហិត ............................................................... ៤១

២.២.៦. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ ................................................... ៤១

២.២.៦.១. ការហាមឃាត់ចំពោះញាតិពន្ធក្នុងខ្សែផ្ទាល់ ............................................................ ៤២

២.២.៦.២. ការហាមឃាត់ចំពោះសាខាញាតិពន្ធ ................................................................... ៤៣

២.២.៧. ការរៀបអាពាហ៍ពិពាហ៍របស់ជនដែលត្រូវបានកម្រិតសមត្ថភាព ........................................ ៤៤

២.២.៧.១. អាពាហ៍ពិពាហ៍របស់ជនស្ថិតក្រោមអាណាព្យាបាលទូទៅ ..........................................៤៤

២.២.៧.២. អាពាហ៍ពិពាហ៍របស់ជនស្ថិតក្រោមហិតូបត្ថម្ភ ..........................................................៤៥

២.២.៨. គោលការណ៍ស្ម័គ្រចិត្ត ..........................................................................................................៤៥

**២.៣. នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍** ......................................................................................... ៤៧

២.៣.១. ដំណាក់កាលនៃការដាក់ពាក្យស្នើសុំ........................................................................................ ៤៧

២.៣.១.១. ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍.................................................................. ៤៧

២.៣.១.២. ដំណាក់កាលត្រួតពិនិត្យរបស់មន្ត្រីអត្រានុកូលដ្ឋាន ......................................................៤៨

២.៣.២. ការចេញបណ្ណប្រកាសជាសាធារណៈ ........................................................................................៤៩

២.៣.២.១. រយៈពេលរង់ចាំ ..........................................................................................................៤៩

២.៣.២.២. អ្នកដែលមានសិទ្ធិធ្វើបណ្តឹងជំទាស់........................................................................៥០

២.៣.២.៣. មូលហេតុជំទាស់នឹងគម្រោងអាពាហ៍ពិពាហ៍ ..........................................................៥១

២.៣.២.៤. ការសម្រេចលើបណ្តឹងជំទាស់....................................................................................៥២

២.៣.៣. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍............................................................................................ ៥៣

២.៣.៣.១. ការចុះបញ្ជីអាពាហ៍ពិពាហ៍........................................................................................៥៤

២.៣.៣.២. ការចេញសំបុត្រអាពាហ៍ពិពាហ៍.................................................................................៥៥

## ជំពូកទី៣

## អានុភាពនៃអាពាហ៍ពិពាហ៍

**៣.១. ទំនាក់ទំនងគតិយុត្តនៃសាមីប្តីប្រពន្ធ** ..................................................................................៥៨

៣.១.១. ការប្រើប្រាស់នាមត្រកូលប្តីប្រពន្ធ ...........................................................................................៥៨

៣.១.២. ករណីយកិច្ចរបស់សហព័ទ្ធ......................................................................................................៥៩

៣.១.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម ...............................៥៩

៣.១.៤ ទំនាក់ទំនងសហព័ទ្ធ និងញាតិ ៥៩
៣.១.៥. សិទ្ធិ និងករណីកិច្ចរបស់អ្នកមានអំណាចមេបា ៦០
**៣.២. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ** ៦០
៣.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ៦០
៣.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ៦១
៣.២.២.១. ចំណែកបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ ៦១
៣.២.២.២. ទ្រព្យសម្បត្តិដោយឡែក ៦១
៣.២.២.៣. ប្រព័ន្ធទ្រព្យសម្បត្តិរួម ៦៤
**៣.៣. មោឃភាពនៃអាពាហ៍ពិពាហ៍** ៦៦
៣.៣.១. មូលហេតុនៃការមោឃភាពអាពាហ៍ពិពាហ៍ ៦៦
៣.៣.១.១. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុភាន់ច្រឡំលើមនុស្ស ៦៦
៣.៣.១.២ ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុការបង្ខិតបង្ខំ ៦៧
៣.៣.១.៣. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុផ្សេងទៀត ៦៧
៣.៣.១.៤. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ៦៨
៣.៣.១.៥. ភាគីមិនបានជូនដំណឹងជាសាធារណៈ ៦៨
៣.៣.១.៦. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ៦៨
៣.៣.១.៧. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ៦៩
៣.៣.២. អ្នកដែលមានសិទ្ធិមោឃភាពអាពាហ៍ពិពាហ៍ ៦៩
៣.៣.៣. អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍ ៧០
**៣.៤. ការលុបចោលនៃអាពាហ៍ពិពាហ៍** ៧០
៣.៤.១. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ៧០

៣.៤.១.១. អាពាហ៍ពិពាហ៍របស់ជនមិនទាន់គ្រប់អាយុរៀបការ ..... ៧០
៣.៤.១.២. ទ្វេពន្ធភាព ..... ៧១
៣.៤.១.៣. អាពាហ៍ពិពាហ៍រវាងញាតិលោហិត ..... ៧២
៣.៤.១.៤. អាពាហ៍ពិពាហ៍រវាងញាតិពន្ធ ..... ៧២
៣.៤.១.៥. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ..... ៧៣
៣.៤.១.៦. អាពាហ៍ពិពាហ៍ដោយការឆបោក ..... ៧៣
៣.៤.១.៧. អាពាហ៍ពិពាហ៍ដោយការគំរាមកំហែង ..... ៧៤
៣.៤.២. អ្នកមានសិទ្ធិលុបចោលអាពាហ៍ពិពាហ៍ ..... ៧៤
៣.៤.៣. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ..... ៧៥
**សេចក្តីសន្និដ្ឋាន** ..... ៧៦
**អនុសាសន៍** ..... ៧៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមាននូវការប្រកាន់ខ្ជាប់អរិយធម៌ និងប្រពៃណីទំនៀមទម្លាប់យ៉ាងចំណាស់ និងល្អផូរផង់តាំងពីបរមបុរាណមកម្លេះ ដែលពុំមានជាតិសាសន៍ណាអាចមកធ្វើការលួច ឆក់ ប្លន់ ឬកេងបន្លំយកនូវភាពល្អប្រណិតរបស់ខ្មែរទៅបាននោះទេ។ ជាធម្មតា នៅក្នុងរដ្ឋមួយដើម្បីឈានទៅរកការរស់នៅដោយសម្បូរសប្បាយ និងមានភាពអូរអរពេញលក្ខណៈជារដ្ឋមួយបាន ក៏ត្រូវមានចំណែកនៃការបង្កើតនូវគ្រួសារជាមេកជាងនៃធនធានមនុស្ស ដែលកើតឡើងពីចំណងអាពាហ៍ពិពាហ៍ និងត្រូវមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងរដ្ឋនោះផងដែរ។ ជាការពិតណាស់ សម្រាប់សង្គមខ្មែរ ការរៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីទំនៀមទម្លាប់ពិតជាមានសារៈសំខាន់ណាស់ ព្រោះថាប្រជាជនខ្មែរឱ្យតម្លៃយ៉ាងខ្លាំងទៅលើ ស្ត្រី ដែលបុស និងនារីត្រូវតែប្រតិបត្តិទៅដោយពុំគួររំលងដោយប្រការណាមួយឡើយ។ អាពាហ៍ពិពាហ៍ គឺជាការចាប់ផ្ដើមរបស់មនុស្សពីរនាក់ដែលស្ម័គ្រចិត្តរួមរស់នៅជាមួយគ្នាបង្កើតបានជាគ្រួសារបន្តពូជពង្សវង្សត្រកូល និងមានកាតព្វកិច្ចក្នុងការជួយសង្គ្រោះគ្នាទៅវិញទៅមក។ ការរៀបអាពាហ៍ពិពាហ៍នេះទៀតសោតគឺធ្វើឡើងជាច្រើនដំណាក់កាលពោលគឺភាគីខាងបុរស និងនារី មានការស្ម័គ្រចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយពុំមានការបង្ខិតបង្ខំពីតតិយជនណាឡើយ ព្រមទាំងមាននូវលក្ខខណ្ឌជាច្រើនទៀត ដែលអាចញ៉ាំងឱ្យអាពាហ៍ពិពាហ៍នោះអាចកើតឡើងទៅបានរហូតដល់ភាគីបុរស និងនារីនោះបានក្លាយជាសហព័ទ្ធនឹងគ្នា។ មិនតែប៉ុណ្ណោះ ក៏មានលក្ខខណ្ឌមួយចំនួនត្រូវបានហាមឃាត់ផងដែរ។

ជាក់ស្ដែង បើយើងនិយាយពីការរៀបអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរពីសម័យបុរាណមកទល់នឹងបច្ចុប្បន្នធ្លាប់បានឆ្លងកាត់ជាច្រើនរបប ជាច្រើនសម័យកាលមកផងនោះ យើងឃើញថា ការរៀបអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរពីសម័យមុនគឺពុំទាន់មានលក្ខណៈពេញលេញតាមច្បាប់នៅឡើយទេ។ យ៉ាងណាមិញបច្ចុប្បន្នការរៀបអាពាហ៍ពិពាហ៍ដោយគ្រាន់តែជាការប្រារព្ធឡើងនូវពិធី និងមានការដឹងឮពីសាធារណជនដោយពុំមានលិខិតស្នាម និងសាក្សីពិតប្រាកដណាមួយមកបញ្ជាក់នោះ គឺជារឿងមួយដែលនាំឱ្យមានបញ្ហាប្រឈមនៅពេលខាងមុខជាក់ជាមិនខាន។ ហេតុនេះហើយបានជាក្រមរដ្ឋប្បវេណីនាពេលបច្ចុប្បន្នគឺ បានកំណត់យ៉ាងជាក់លាក់ពីការរៀបអាពាហ៍ពិពាហ៍ មិនថាដំណាក់កាលនៃកំជាប់ពាក្យ លក្ខខណ្ឌនៃកំជាប់ពាក្យព្រមទាំងដំណោះស្រាយពេលមានភាគីណាម្នាក់ធ្វើឱ្យកំជាប់នោះរលាយទៅវិញ។ ជាពិសេសគឺការចែងពីលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍នេះតែម្ដង ព្រោះវាជាលក្ខខណ្ឌមួយដែលអាចឱ្យអាពាហ៍ពិពាហ៍របស់អនាគតស្វាមី ភរិយានេះមានលក្ខណៈពេញលេញ និងស្របតាមច្បាប់ដែលតតាំងជាមួយ

គតិយជន និងអាចជួយក្នុងការបង្ការទំនាស់នាពេលអនាគត។ ជាងនេះទៅទៀត ការគ្រប់គ្រងទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ក៏ជាកត្តាសំខាន់ដែរបុគ្គលពីរនាក់ត្រូវមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬក្រោយរៀបអាពាហ៍ពិពាហ៍។

ដោយយោងតាមវិសាលភាពនៃសង្គមខ្មែរ និងវិសាលភាពនៃការតាក់តែងច្បាប់របស់ប្រទេសកម្ពុជាបច្ចុប្បន្ន យើងអាចមើលឃើញថា កម្ពុជាបានរៀបចំតាក់តែងពីដំណាក់កាល ក៏ដូចជារបៀបរបបក្នុងការរៀបអាពាហ៍ពិពាហ៍ដែលពេញលក្ខណៈច្បាប់ជាច្រើនប្រភេទដូចជា៖ ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅកម្ពុជា ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅបរទេស ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅបរទេស និងការរៀបអាពាហ៍ពិពាហ៍រវាងជនអន្តោប្រវេសន៍ ឬជនបរទេសដែលរស់នៅស្របច្បាប់នៅប្រទេសកម្ពុជាជាដើម។ ក្នុងនេះដែរ ក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសក្នុងការសិក្សាពីប្រធានបទទាក់ទងនឹងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ព្រោះថាក្រុមយើងខ្ញុំចង់រក្សាវិសាលភាពនៃប្រធានបទនៅត្រឹមកម្រិតនៃការសិក្សាស្រាវជ្រាវតែទៅលើទំនាក់ទំនងគតិយុត្តិរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែលមានសញ្ជាតិខ្មែរលើទឹកដីកម្ពុជាប៉ុណ្ណោះ។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នេះផងដែរ ប្រជាពលរដ្ឋខ្មែរមួយចំនួនតូចពុំសូវមានការយល់ដឹងទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍បែបណាដែលហៅថា ការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ ដោយសារតែប្រជាពលរដ្ឋខ្មែរមានការប្រកាន់យ៉ាងខ្ជាប់ខ្ជួនទៅលើការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីដែលមានតាំងពីដូនតាមក ហេតុនេះទើបធ្វើឱ្យការរៀបអាពាហ៍ពិពាហ៍ក្នុងប្រទេសកម្ពុជាមួយចំនួនតូចជាការរៀបអាពាហ៍ពិពាហ៍ដែលគោរពទៅតាមប្រពៃណី តែមិនបានគោរពទៅតាមច្បាប់។ យ៉ាងណាមិញ មានកត្តាជាច្រើនដែលនាំឱ្យមានការបន្សល់ទុក ក៏ដូចជាបង្កើតឱ្យមាននូវអាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់ ឬយើងអាចហៅបានថា ការរស់នៅជាមួយគ្នាតាមបែបអនីតិសង្វាសបែបនេះដូចជា ការឆ្លងកាត់នូវសង្គ្រាមរ៉ាំរ៉ៃ ដែលនាំឱ្យប្រជាពលរដ្ឋមានការភ័យខ្លាច ទើបពុំសូវអនុវត្តតាមនីតិវិធីច្បាប់ និងកត្តាចម្បងនាពេលបច្ចុប្បន្ន គឺការកង្វះខាតនូវការយល់ដឹងអំពីទិដ្ឋភាពផ្នែកច្បាប់ក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នេះតែម្តង។ ដោយសារតែការគិតថាបុគ្គលពីរនាក់ដែលស្ម័គ្រចិត្តក្នុងការរួមរស់នៅជាមួយគ្នា និងរស់នៅជាមួយគ្នាលុះដល់ដង្ហើមចុងក្រោយ ដែរយើងពុំបានស្វែងយល់ពីផលវិបាកដែលកើតឡើងនៅពេលមានភាគីណាម្នាក់ក្បត់ចិត្ត ឬចង់ផ្តាច់ទំនាក់ទំនងនេះ ព្រោះថាចិត្តមនុស្សជាអ្វីដែលយើងពុំអាចស្មានដឹងជាមុនឡើយ ហើយវាជាអ្វីដែលនឹងនាំឱ្យមានបញ្ហាកើតឡើងមិនត្រឹមតែបុគ្គល

តែពីរនាក់នោះទេ ប៉ុន្តែក៏ជាបញ្ហាសម្រាប់គ្រួសារទាំងសងខាងដែលនឹងមានវិវាទប៉ះទង្គិចដល់ទំនាក់ទំនងល្អដែលធ្លាប់មាន ពីការរៀបអាពាហ៍ពិពាហ៍ដោយមិនស្របទៅតាមការបញ្ញត្តិរបស់ច្បាប់នេះជាក់ជាមិនខាន។

**ដោយយោងតាមមូលហេតុនេះហើយ ទើបមានបញ្ហាចោទឡើងជាច្រើនទាក់ទិននឹងបញ្ហានេះ ថាតើការរៀបអាពាហ៍ពិពាហ៍តាមប្រព័ន្ធច្បាប់នាពេលបច្ចុប្បន្នត្រូវឆ្លងកាត់នូវដំណាក់កាល និងនីតិវិធីអ្វីខ្លះ? ហើយថាតើក្រោយពេលរៀបអាពាហ៍ពិពាហ៍នាំឱ្យសហព័ទ្ធនោះបង្កើតបានជាចំណងអានុភាពគតិយុត្តិបែបណាខ្លះ? តើមានមូលហេតុអ្វីខ្លះដែលនាំឱ្យអាពាហ៍ពិពាហ៍នោះកើតមាននូវមោឃភាព និងការលុបចោល?**

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងដែលក្រុមនាងខ្ញុំធ្វើការយកនូវប្រធានបទ « **អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា** » គឺនាងខ្ញុំទាំងពីរនាក់យល់ឃើញថា ទោះបីប្រទេសកម្ពុជាកំពុងតែមានការអភិវឌ្ឍន៍ និងការកែប្រែនូវប្រព័ន្ធច្បាប់បានល្អយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហាចោទឡើងក្នុងសង្គមទាក់ទងនឹងវិវាទដែលបណ្ដាលមកពីអាពាហ៍ពិពាហ៍នេះផងដែរ។ ដូច្នេះហើយក្រុមនាងខ្ញុំមានការប្ដេជ្ញាចិត្តក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះឱ្យបានកាន់តែស៊ីជម្រៅលើនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ក៏ដូចជាការលើកឡើងមកសារជាថ្មីពីប្រវត្តិខ្លះៗនៃអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ប្រជាជនកម្ពុជាផងដែរ។ លើសពីនេះទៅទៀត ក្រុមនាងខ្ញុំចង់ធ្វើការសិក្សាស្រាវជ្រាវឱ្យបានកាន់តែច្បាស់ពីនីតិវិធីនៃអាពាហ៍ពិពាហ៍ដូចជា៖ មុនពេលរៀបអាពាហ៍ពិពាហ៍, អំឡុងពេលរៀបអាពាហ៍ពិពាហ៍, ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ស្របតាមច្បាប់ដែលបានចែងកំណត់ និងអានុភាពនៃអាពាហ៍ពិពាហ៍ ក៏ដូចជាមូលហេតុមួយចំនួនដែលនាំឱ្យកើតមាននូវមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍មួយ ទុកជាចំណេះដឹងបន្ថែមឱ្យកាន់តែច្បាស់សម្រាប់ខ្លួនឯង និងជាទុនឯកសារសម្រាប់ការសិក្សាស្រាវជ្រាវដល់ជំនាន់ក្រោយៗផងដែរ។

គោលបំណងចម្បងៗផ្សេងទៀតរួមមាន៖

- យល់ដឹងបន្ថែមពីប្រវត្តិអាពាហ៍ពិពាហ៍ និងអាពាហ៍ពិពាហ៍សម័យបុរាណ
- បម្លាស់ប្ដូរនៃការរៀបអាពាហ៍ពិពាហ៍ពីមួយសម័យកាលទៅមួយសម័យកាល
- ស្វែងយល់ពីលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ
- ស្វែងយល់បន្ថែមពីទិដ្ឋភាពច្បាប់ និងការអនុវត្តជាក់ស្ដែងរបស់ប្រជាពលរដ្ឋខ្មែរ
- ស្វែងយល់ពីអនុភាពដែលកើតឡើងពីការរៀបអាពាហ៍ពិពាហ៍
- ស្វែងយល់ពីមូលហេតុដែលនាំឱ្យមានមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍
- ធ្វើការសន្និដ្ឋាន និងអនុសាសន៍ដើម្បីអាចកែសម្រួលបញ្ហាមួយចំនួនដែលកើតមានក្នុងសង្គម

➢ ចងក្រងទុកជាឯកសារ ក៏ដូចជាស្នាដៃ ទុកសម្រាប់ការសិក្សាស្រាវជ្រាវជំនាន់ក្រោយៗ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សា

ប្រធានបទដែលក្រុមនាងខ្ញុំធ្វើការស្រាវជ្រាវនេះ គឺទាក់ទងតែលើនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋខ្មែរនៅកម្ពុជាតែប៉ុណ្ណោះ ដោយពុំលាតសន្ធឹងទៅលើបរទេសនោះឡើយ។ ការស្រាវជ្រាវនេះទៀតសោត គឺពឹងផ្អែកទៅលើទិដ្ឋភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ក៏ដូចជាអនុក្រឹត្យ ឬប្រកាសផ្សេងៗទៀតដែលទាក់ទងនឹងប្រធានបទនេះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺសម្រាប់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវយកទុកជាជំនួយដល់ការសិក្សា មិនតែប៉ុណ្ណោះនាងខ្ញុំទាំងពីរនាក់ក៏ទុកជាដើមទុន និងចំណេះដឹងបន្ថែមដល់សាធារណជនផងដែរ។ ប្រធានបទមួយនេះនឹងជួយសម្រួលដល់ពួកគេក្នុងការសិក្សាស្រាវជ្រាវ និងការរស់នៅជាក់ស្តែងនៅក្នុងសង្គមជាតិ ដោយពួកគេនឹងយល់កាន់តែស៊ីជម្រៅទាក់ទងនឹងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ស្របតាមលក្ខខណ្ឌច្បាប់ ដើម្បីជៀសវាងនូវរាល់បញ្ហាណាមួយកើតមានឡើងអំឡុងពេល និងក្រោយពេលនៃការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ ដោយសារការយល់ច្រឡំដោយប្រការណាមួយផងដែរ។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើសារណារបស់ក្រុមនាងខ្ញុំ គឺពឹងផ្អែកទៅលើការសុំមតិយោបល់ ក៏ដូចជាការណែនាំ និងពន្យល់បន្ថែមពីអ្នកគ្រូដឹកនាំសារណា ការសុំមតិយោបល់បន្ថែមពីលោកចៅក្រម ក្រឡាបញ្ជីពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងនៅក្នុងសង្គម និងការដកស្រង់ចេញពីប្រភពឯកសារជាច្រើនទៀតដូចជា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនានាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នៅកម្ពុជា។ ជាពិសេសនោះគឺ ឯកសារនានាដែលបានមកពីបណ្ណាល័យនៃសាកលវិទ្យាល័យផ្ទាល់តែម្តង ក៏ដូចជាឯកសារ សៀវភៅនានាដែលបានមកពីសាស្ត្រាចារ្យ សិស្សច្បង និងការសុំមតិពីអ្នកមានបទពិសោធន៍ផ្ទាល់ពីការរៀបអាពាហ៍ពិពាហ៍ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យយល់កាន់តែច្បាស់ និងឆ្លើយតបទៅនឹងសារណាក្រោមប្រធានបទ « ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា » ក្រុមនាងខ្ញុំបានបែងចែកមាតិកាជា បី ជំពូកដូចខាងក្រោម៖

➢ ជំពូកទី១ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

១.១. និយមន័យអាពាហ៍ពិពាហ៍

១.២. ប្រវត្តិនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទម្លាប់ខ្មែរ

១.៣. បទដ្ឋានគតិយុត្តនៃអាពាហ៍ពិពាហ៍

- ជំពូកទី២ របបគតិយុត្តនៃអាពាហ៍ពិពាហ៍

២.១. ទំនាក់ទំនងគតិយុត្តមុនរៀបអាពាហ៍ពិពាហ៍

២.២. លក្ខខណ្ឌគតិយុត្តដើម្បីរៀបអាពាហ៍ពិពាហ៍

២.៣. នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍

- ជំពូកទី៣ អានុភាពនៃអាពាហ៍ពិពាហ៍

៣.១. អានុភាពនៃអាពាហ៍ពិពាហ៍

៣.២. ប្រព័ន្ធទ្រព្យសម្បត្តិប្តី ប្រពន្ធ

៣.៣. មោឃភាពនៃអាពាហ៍ពិពាហ៍

៣.៤. ការលុបចោលអាពាហ៍ពិពាហ៍

# ជំពូកទី ១

# សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

# ជំពូកទី ១

# សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

ប្រជាជនកម្ពុជាយើងបានប្រកាន់ខ្ជាប់នូវប្រពៃទំនៀមទំលាប់យ៉ាងល្អប្រពៃ ជាពិសេសគឺការប្រារព្ធនូវកម្មវិធីអ្វីមួយដែលមានលក្ខណៈជាតិ និងប្រកបដោយភាពថ្លៃថ្នូរ។ ជាក់ស្តែង ប្រពៃណីទំនៀមទំលាប់ខ្មែរដែលមានលក្ខណៈល្អផូរផង់ និងប្រកបដោយភាពប្រណីតដែរប្រទេសមួយចំនួនពុំអាចធ្វើបាននោះគឺ ប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍របស់ប្រជាជនខ្មែរនេះឯង។ យើងដឹងហើយថា នៅបណ្តាប្រទេសមួយចំនួនដូចជានៅ អឺរ៉ុបជាដើម ពុំមានការរៀបអាពាហ៍ពិពាហ៍ដែលតឹងរឹងដូចជាប្រទេសកម្ពុជានោះឡើយ ដោយពួកគេអាចរួមរស់នៅជាមួយគ្នាដោយពុំខ្វាយខ្វល់ពីការរៀបអាពាហ៍ពិពាហ៍នោះទេ ហើយពួកគេចង់រៀបអាពាហ៍ពិពាហ៍ពេលណាក៏បាន។ ដោយឡែកប្រទេសកម្ពុជាវិញ ថ្វីត្បិតតែពុំមានឯកសារណាមួយមកបញ្ជាក់ឱ្យច្បាស់លាស់ថា ការរៀបអាពាហ៍ពិពាហ៍បានចាប់បដិសន្ធិឡើងតាំងពីពេលណាឱ្យពិតប្រាកដក៏ពិតមែន ប៉ុន្តែអរិយធម៌ខ្មែរយើង គឺបានកើតមានឡើងជាយូរលង់ណាស់មកហើយ។ ហេតុនេះយើងអាចសន្នតបានថា ប្រពៃណីនៃការរៀបការរបស់ប្រជាជនខ្មែរក៏បានតាក់តែង និងប្រតិបត្តិមកជាយូរណាស់មកហើយដូចគ្នាដែរ។ តាំងពីបុរាណកាលមក អ្នកដែលមានអំណាចមេបា ក៏ដូចជាឪពុកម្តាយនៃគ្រួសារនីមួយៗមែងតែផ្សំផ្គុំគូរស្រករដល់កូនៗរបស់ខ្លួន។ រហូតមកដល់បច្ចុប្បន្ន វិសាលភាពនៃច្បាប់មានការរីកចម្រើន ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ក៏ត្រូវមានការបំពេញបន្ថែមដើម្បីឱ្យកាន់តែសមស្រប និងគោរពទៅតាមវិធានច្បាប់ដែលបានដាក់ចេញមក ក្នុងគោលបំណងលើកកម្ពស់ប្រពៃណីទំនៀមទំលាប់ខ្មែរឱ្យកាន់តែល្អផូរផង់ និងថែរក្សាបាននូវសណ្តាប់ធ្នាប់សង្គមផងដែរ។

## ១.១. និយមន័យ អាពាហ៍ពិពាហ៍

### ១.១.១. ក្នុងន័យអក្សរសាស្ត្រខ្មែរ

អត្ថន័យនៃពាក្យ « **អាពាហ៍ពាហ៍** » បានកំណត់នៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត**។ ពាក្យ « **អាពាហ៍ពាហ៍** » គឺជានាមសព្ទ (សំ. បា. អាវាហ + វិវាហ, ខ្មែរប្រើផ្លាស់ វ ជា ព) មង្គលការ គូបុរសស្ត្រីដែលបាននាំមកហើយនាំត្រឡប់ទៅវិញ (ពីរលើក) « បានរៀបមង្គលការអាពាហ៍ពិពាហ៍ពេញច្បាប់ »។ តាមរូបសព្ទ អាវាហ (អាពាហ៍ពិពាហ៍) ថា « នាំមក », វិវាហ (ពិពាហ៍) ថា « នាំត្រឡប់ទៅវិញ » តាមអធិប្បាយក្នុងគម្ពីរកែសព្ទថា ការនាំកូនស្រីមកខាងលំនៅកូនប្រុសហៅថា អាវាហៈ (អាពាហ៍), ការនាំកូនប្រុសត្រឡប់ទៅខាងលំនៅកូនស្រីវិញ ហៅថា វិវាហៈ (ពិពាហ៍), ប៉ុន្តែតាមទំនៀមខ្មែរ ត្រូវនាំកូនប្រុសមកខាងលំនៅកូនស្រីមុនហៅថា អាពាហ៍ (ត្រូវធ្វើពីល្ងាច), លុះដល់វេលាព្រឹកឡើងនាំកូនស្រីទៅឯរោងខាងកូនប្រុសវិញ ហៅថា ពិពាហ៍,

មង្គលការដែលបានធ្វើទាំងពីរបែបនេះទើបហៅថា មង្គលការអាពាហ៍ពិពាហ៍, បើបានធ្វើត្រឹមតែ អាពាហ៍ ហៅថា អាវាហមង្គល, បើធ្វើតែ ពិពាហ៍ ហៅថា វិវាហមង្គល។ ព. កា. បញ្ជាក់សព្ទ អាពាហ៍ និងពិពាហ៍ថា « អាពាហ៍ ប្រែថាការនាំមក នូវប្រុសពន្លកជាគូភ្ជា មកផ្ទះខាងស្រីតាមវេលា។ ពិពាហ៍ ប្រែថា នាំស្រីទៅវិញ »។

## ១.១.២. ក្នុងន័យតាមការកំណត់ច្បាប់

### ១.១.២.១. ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០

**អាពាហ៍ពិពាហ៍** គឺជាកិច្ចសន្យាយ៉ាងឱឡារិកមួយដែលបុរសម្នាក់ និងស្រីម្នាក់ប្ដេជ្ញាគ្នាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមច្បាប់ដែលបានបញ្ញត្តិមក ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។[១] **ឧទាហរណ៍**៖ បុរស **ក** មានអាយុ ២៥ឆ្នាំ និងនារី **ខ** មានអាយុ ២២ឆ្នាំ ជាគូសង្សារនឹងគ្នាដោយសន្យាថានឹងស្រឡាញ់គ្នាជារៀងរហូតទៅ ដែលនេះជាការសន្យាធម្មតា ពុំមានលក្ខខណ្ឌចាប់បង្ខំឱ្យត្រូវតែបំពេញនោះឡើយ ព្រោះវាជាពាក្យសន្យាតាមដែលគូសង្សារដទៃតែងតែធ្វើប៉ុណ្ណោះ។ ប៉ុន្មានឆ្នាំក្រោយមក បុរស **ក** បានឱ្យឪពុកម្ដាយរបស់ខ្លួនចូលស្ដីដណ្ដឹងនារី **ខ** ដែរជាសង្សាររបស់ខ្លួន។ ពួកគេបានធ្វើពិធីកំជាប់ពាក្យដោយសន្យាជាមួយគ្នាថានឹងរៀបការជាមួយគ្នាទៅថ្ងៃអនាគត។ លុះដល់ពេលវេលាសមរម្យមួយដែលគ្រួសារទាំងសងខាងយល់ថាសមគួរ ពួកគេក៏បានរៀបចំនូវពិធីអាពាហ៍ពិពាហ៍មួយដោយគោរពតាមពាក្យសន្យាដែរខ្លួនបានផ្ដល់ឱ្យដៃគូរបស់ខ្លួន។ កាលណាដែលពួកគេបានរៀបអាពាហ៍ពិពាហ៍ស្របតាមការកំណត់របស់ច្បាប់ហើយនោះ បើពួកគេផ្លាស់ប្ដូរចិត្តចង់បញ្ចប់អាពាហ៍ពិពាហ៍នេះវិញ គឺពួកគេមិនអាចរំលាយទៅតាមទំនើងចិត្តបាននោះទេ ពួកគេត្រូវតែគោរពទៅវិធានតាមច្បាប់។

### ១.១.២.២. សន្ធានុក្រមនៃច្បាប់ស្ដីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣

**អាពាហ៍ពិពាហ៍** សំដៅដល់កិច្ចសន្យាពិសេសដែលកើតចេញពីឆន្ទៈព្រមព្រៀងរវាងបុរសម្នាក់ និងនារីម្នាក់ដែលមានបំណងរួមរស់ជាមួយគ្នា និងសង្គ្រោះគ្នាទៅវិញទៅមក ហើយបុរស និងនារីនោះ ត្រូវតែមានលក្ខខណ្ឌដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។[២] **ឧទាហរណ៍**៖ បុរស **ក** មានអាយុ ៣០ឆ្នាំ និងនារី **ខ** មានអាយុ ២៥ឆ្នាំ អ្នកទាំងពីរមានបំណងចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នា។ អាពាហ៍ពិពាហ៍ពួកគេនឹងអាចកើតមានឡើង ដោយការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងស្ម័គ្រចិត្ត និងយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា

[១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩២០, មាត្រា ១១៤។

[២] សន្ធានុក្រមនៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ចំណុចទី១៩។

ដោយគ្មានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ។ ការបង្ហាញឆន្ទៈរៀបអាពាហ៍ពិពាហ៍នេះ ភាគីទាំងសងខាងក៏ត្រូវទទួលយកនូវកាតព្វកិច្ចសង្គ្រោះគ្នាទៅវិញទៅមក និងគោរពតាមលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដែលក្រមរដ្ឋប្បវេណីនេះបានចែង។

#### ១.១.២.៣. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**អាពាហ៍ពិពាហ៍** គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថានឹងរួមរស់នៅជាមួយគ្នា បង្កើតជាចំណងគតិយុត្តក្នុងនាមជាប្ដីប្រពន្ធ ដោយទំនាក់ទំនងនេះត្រូវបានច្បាប់ទទួលស្គាល់ លុះត្រាតែអ្នកទាំងពីរបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា។ **ឧទាហរណ៍**៖ បុរស **ក** និងនារី **ខ** ជាអនីតិជនបានព្រមព្រៀងនឹងគ្នាធ្វើពិធីកំជាប់ពាក្យ ដោយមានការយល់ព្រមពីអាណាព្យាបាល និងបានសន្យាថានឹងរៀបការជាមួយគ្នានៅថ្ងៃអនាគត។ លុះភាគីទាំងសងខាងបានដល់នីតិភាពនៃការរៀបអាពាហ៍ពិពាហ៍ហើយនោះ អ្នកទាំងពីរគឺអាចដំណើរការនៃការរៀបអាពាហ៍ពិពាហ៍របស់ខ្លួនដោយគោរពតាមការកំណត់របស់ក្រមរដ្ឋប្បវេណីថ្មីនេះ។ លុះអ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍ហើយ ដែលបានចុះបញ្ជី និងសំបុត្រអាពាហ៍ពិពាហ៍រួចរាល់ហើយ ភាគីទាំងពីរនឹងក្លាយជាប្ដីប្រពន្ធនឹងគ្នាដោយស្របច្បាប់ និងមានកាតព្វកិច្ចរួមគ្នាក្នុងនាមជាប្ដីប្រពន្ធជាច្រើនទៀត។

## ១.២. ប្រវត្តិនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទំលាប់

### ១.២.១. អាពាហ៍ពិពាហ៍តាមរយៈរឿងព្រេងនិទាន

សង្គមមួយខុសពីសង្គមមួយដោយសារវប្បធម៌អរិយធម៌របស់ជាតិនោះ។ ខ្មែរគឺជាជនជាតិដ៏ចំណាស់មួយដែលមានវប្បធម៌ អរិយធម៌របស់ខ្លួនតាំងពីយូរណាស់មកហើយ ដែលគេចាត់ទុកថាជាអរិយធម៌ប្រទេសមួយក្នុងពិភពលោកក្នុងសម័យមហានគរ ហើយអ្វីដែលខ្មែរបានបន្សល់ទុកមកដល់រហូតបច្ចុប្បន្ននេះគឺ វប្បធម៌អរិយធម៌ ដែលក្នុងនោះមានប្រពៃណីទំនៀមទំលាប់ ជាពិសេសគឺការរៀបអាពាហ៍ពិពាហ៍។ ពិធីនេះខ្មែរបានឱ្យតម្លៃណាស់ចំពោះជីវិតបុរស និងស្ត្រី មុននឹងក្លាយជាប្ដីប្រពន្ធនឹងគ្នាត្រូវតែឆ្លងកាត់ជាដាច់ខាត ទោះបីតូចក្ដី ធំក្ដី បើពុំនោះទេគេចាត់ទុកថាជាមនុស្សរស់នៅមិនចុះសម្រុងនឹងសង្គម គ្មានសិរីសួស្ដីក្នុងជីវិត ម្យ៉ាងវិញទៀតគឺក្រុមគ្រួសាររបស់ពួកគេត្រូវអាប់ឱននូវកិត្តិយស ដោយសារតែពុំគោរពតាមប្រពៃណីរបស់ខ្លួន។ នៅក្នុងនោះដែរ យើងសង្កេតឃើញថា ពិធីនៃអាពាហ៍ពិពាហ៍មានច្រើនរបៀបណាស់កាលពីសម័យបុរាណ ហើយរយៈពេលនៃការរៀបចំធ្វើក៏វែងឆ្ងាយណាស់ដែរ ជាហេតុធ្វើឱ្យកូនចៅជំនាន់ក្រោយជ្រើសរើសយកតែពីធីសំខាន់មករៀបចំតែប៉ុណ្ណោះ។ ចំពោះប្រវត្តិនៃអាពាហ៍ពិពាហ៍ខ្មែរយើងពុំមានឯកសារណាបានបញ្ជាក់ឱ្យកាន់តែច្បាស់លាស់នោះទេ គ្រាន់តែមានមតិខ្លះៗលើកយកសន្និដ្ឋានតែប៉ុណ្ណោះដូចជា៖ អ្នកខ្លះថា អាពាហ៍ពិពាហ៍ខ្មែរយកលំនាំតាម រឿង

រាមកេរ្តិ៍ គឺពិធីមង្គលការរវាង ព្រះរាម និងនាងសិតា របស់មហាឥស្សីមិថិលា។ ខ្លះទៀតថាយកលំនាំតាមរឿងព្រះវេស្សន្តរ គឺពិធីអភិសេកចៅក្រឹស្នា និងជាលី។ ចំណែកឯខ្លះទៀតថា យកលំនាំតាមពិធីអភិសេកព្រះថោង នាងនាគ។ រីឯពិធីដែលគេបានរៀបចំនោះ គឺវាមានប្រវិត្តទាក់ទងទៅនឹងរឿងព្រេងខ្មែរ។ រឿងព្រេងខ្មែរ គឺជាប្រភេទអក្សរសិល្ប៍ប្រជាប្រិយ គ្មានប្រភពដើម គ្មានអ្នកនិពន្ធច្បាស់លាស់ វាកើតចេញពីប្រជាជនដែលផ្សាយចេញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈការនិទានឡើងតៗ។ ករណីនេះហើយយើងអាចសន្និដ្ឋានបានថា ប្រពៃណីរៀបមង្គលការរបស់ប្រជាពលរដ្ឋខ្មែរយើងគឺ និយមតាមទំលាប់តៗគ្នារហូតមកដល់ដល់សព្វថ្ងៃនេះ។ ដូចនេះយើងខ្ញុំសូមលើកយកមកបង្ហាញនូវពិធីមួយចំនួនដែលទាក់ទងទៅនឹងរឿងព្រេងខ្មែរ៖

- **ពិធីស្ដីដណ្ដឹង៖** កាលពីព្រេងនាយ មានស្ដេចស្រីមួយព្រះអង្គព្រះនាម ស្រីអយុធ្យា ដែលសោយរាជ្យនៅនគរខ្មែរ។ ដោយព្រះនាងជាស្ដេចសោយរាជ្យ គ្មានបុរសណាមួយហ៊ានដណ្ដឹងយកជាភរិយាឡើយ។ ម្ល៉ោះហើយព្រះនាងរកដណ្ដឹងបុរសដ៏មានរូបសម្រស់ល្អជាទីគាប់ព្រះទ័យមកធ្វើជាព្រះស្វាមីវិញ ហើយដោយហេតុព្រះរាជានី ស្រីអយុធ្យាដណ្ដឹងប្រុសជាព្រះស្វាមីដូច្នោះ ស្រីៗដែលនៅក្រោមព្រះរាជឱវាទ ក៏ដណ្ដឹងប្រុសៗធ្វើជាស្វាមីតាមដែរ។ ក្នុងរាជ្ជកាលនោះស្រីៗខ្លះ ដែលមានរូបមិនស្អាតទៅរកដណ្ដឹងប្រុសៗ គេនាំគ្នាប្រកែកមិនយក គេរើសតែស្រីៗមានរូបល្អៗ ទើបយកធ្វើជាភរិយា។ ធ្វើដូច្នេះអស់មួយរាជ្ជកាលស្ដេចស្រីនេះ។ លុះមកដល់រាជ្យស្ដេចក្រោយៗទៀត ពួកស្រីៗជំនុំគ្នាថា «ឥឡូវនេះដូចជាមិនសមសោះ ខ្លួនយើងជាស្រីហើយដើរដណ្ដឹងប្រុសៗ ធ្វើជាប្ដី ដូច្នេះយើងនឹងនាំគ្នាលើកដីចាក់ពូនជាភ្នំ ភ្នាល់ជាមួយនឹងពួកប្រុសៗ គឺប្រុសលើកដីធ្វើជាភ្នំមួយ យើងស្រីធ្វើជាភ្នំមួយភ្នាល់គ្នា។ បើប្រុសៗចាញ់យើងត្រូវឲ្យប្រុសៗដណ្ដឹងយើងជាស្រីវិញ»។ លុះគិតដូច្នេះហើយ ក៏នាំគ្នាទៅបបួល ពួកប្រុសៗធ្វើភ្នំ ចុះខសន្យាភ្នាល់គ្នាដូចពោលមក ហើយគេក៏បានចាត់មេកំណែន កេណ្ឌមនុស្សស្រីឲ្យបានច្រើន ខាងប្រុសមានមេកំណែន ខាងប្រុសដើរកេណ្ឌ ខាងស្រីមានមេកំណែន ខាងស្រីដើរកេណ្ឌ។ លុះកេណ្ឌបានគ្នាច្រើន គ្រប់ចំនួនខាងប្រុស និងខាងស្រីរួចហើយ ក៏និយាយនិងគ្នាថា «យើងទាំងអស់គ្នាត្រូវជញ្ជូនដីដរាបណាដល់ផ្កាយព្រឹករះ ទើបឈប់ទាំងអស់គ្នា។ បើផ្កាយព្រឹកមិនទាន់រះមិនត្រូវឈប់ទេ»។ គិតព្រមគ្នាដូច្នេះហើយពួកគេក៏នាំគ្នារៀបចំទៅជញ្ជូនដី រែកទូលតាមក្រុមរៀងៗខ្លួនទៅ។

  ពេលនោះជាពេលរាត្រី ពួកស្រីៗមានប្រាជ្ញាជញ្ជូនដីអស់វេលាបីបួនម៉ោង ក៏នាំគ្នាបង្ហូតគោមតូចមួយយ៉ាងខ្ពស់ នៅជ្រុងឥសានភ្នំ។ ពួកប្រុសៗក្រឡេកមើលទៅលើឃើញមានគោមដែលស្រីបង្ហូតនឹងឫស្សីមួយដើមនោះ ស្មានថាផ្កាយព្រឹករះក៏បបួលគ្នាឈប់ធ្វើការ នាំគ្នានិទ្រាលក់អស់ទៅគ្មានសល់ម្នាក់។ ពួកស្រីៗក៏នាំគ្នាជញ្ជូនដីដរាបណាដល់ផ្កាយព្រឹករះមែនទែនទើបឈប់។ ដល់មាន់រងាវកឺតប្រុសៗភ្ញាក់ឡើង

ឃើញផ្កាយព្រឹករះក៏លាន់មាត់ថា «យើងទាំងអស់គ្នាខុសហើយ ផ្កាយព្រឹកមែនទែនទើបតែនឹងរះសោះ»។ ហើយនាំគ្នាក្រឡេកមើលទៅភ្នំស្រីមានទំហំខ្ពស់ជាងភ្នំរបស់ខ្លួន ក៏មានសេចក្ដីអៀនអន់ក្នុងចិត្តដោយចាញ់កលស្រីៗ។ តាំងពីកាលនោះមកប្រុសៗក៏ដណ្ដឹងស្រីៗធ្វើជាភរិយាវិញម្ដងដរាបដល់សព្វថ្ងៃនេះ។[៣] ការស្ដីដណ្ដឹងនេះខ្មែរយើងតែងតែរៀបចំជាបណ្ដាការ ឬថ្លៃទឹកដោះទៅជូនចាស់ទុំខាងនារី។

- **ពិធីស៊ីស្លា-បញ្ជាប់ពាក្យ៖** គឺជាពិធីដំបូងគេបំផុតមុននឹងឆ្លងទៅដល់ការរៀបអាពាហ៍ពិពាហ៍។ ចំពោះពិធីនេះមានរឿងដំណាលថា៖ មានបុរសពីរនាក់ទៅឃ្វាលក្របីជួបគ្នា ក៏សុំគ្នាធ្វើជាភ្លើ និងសាកសួរគ្នាពីកូន ម្នាក់ថាមានកូនស្រី ម្នាក់ទៀតថាមានកូនប្រុស។ ភ្លើដែលមានកូនប្រុស និយាយសុំផ្សំផ្គុំកូន និងកូនឱ្យជាគូសម្ព័ន្ធនឹងគ្នា ហើយបុរសមានកូនស្រីក៏ព្រម។ ទើបបុរសមានកូនប្រុសបានយកកន្សែងស្លាពីថ្នក់ខ្លួនស្រាយលាឱ្យបុរសមានកូនស្រីនោះស៊ី ហើយថាដ្បិតមកក្នុងព្រៃ គ្មានអ្វីជាគ្រឿងមកបញ្ចាំចិត្តទេ ទើបសុំឱ្យសំឡាញ់ស៊ីស្លាកន្សែងនេះមួយមាត់ចុះដើម្បីជាកិច្ចសន្យានឹងគ្នាតទៅ។ បុរសដែលមានកូនស្រីក៏ព្រមទទួលតាម។ ហេតុនេះហើយទើបកើតមានការស៊ីស្លាដក់ ស្លាកន្សែង ចង់សម្វាច តាំងពីគ្រឹមនោះមក។
  - **ចំពោះអត្ថន័យនៃពិធីនេះគឺ៖** ពិធីនេះមានអត្ថន័យជ្រាលជ្រៅណាស់នៅក្នុងសង្គមខ្មែរយើង។ កូនប្រុសស្រីអាចរៀបការបានលុះត្រាតែឪពុកម្ដាយទាំងសងខាងដឹងឮ ព្រោះថាបើទោះបីជានរណាជួយដឹងឮ ក៏មិនស្មើនឹងការទទួលដឹងឮពីឪពុកម្ដាយដែរ។ ហេតុដូចនេះហើយពិធីស៊ីស្លានេះ ជាពិធីមួយដែលឪពុកម្ដាយ និងចាស់ទុំសាមីខ្លួន កូនប្រុសស្រីទទួលដឹងឮទាំងអស់គ្នាថាយល់ព្រមឱ្យកូនទាំងពីរអ្នកនោះបានជាប្ដីប្រពន្ធ។
- **ពិធីកាត់សក់៖** ទាក់ទងទៅនឹងរឿងដំណាលថា កាលពីព្រេងនាយ មានសេដ្ឋីម្នាក់រៀបការកូនស្រី។ គ្រានោះមានចាតុម្មហារាជិកានៅឯឋានសួគ៌ បានបើកទិព្វចក្ខុមកមើលឋានមនុស្សលោកនៅឯផែនដី ហើយទតឃើញមហាសេដ្ឋីកំពុងប្រារព្ធពិធីរៀបមង្គលការកូន។ ចាតុម្មមហារាជក៏ចាត់បញ្ជូនវិស្សកម្មទេវបុត្រពីរអង្គដែលមួយអង្គជាខ្មាន់ព្រះកេស (ជាងកាត់សក់) មួយទៀតជាអ្នកជាអ្នកសំអាងកាយ ចុះមកកាន់ផែនដីដើម្បីលក់កន្ត្រៃទិព្វ និងក្រាសទិព្វទៅឱ្យមហាសេដ្ឋីនោះ។ កន្ត្រៃ និងក្រាសទិព្វនេះ អាចនាំលាភសក្ការៈ ភ័ព្វសំណាង និងដំណឹងល្អៗដល់មនុស្សលោក ឱ្យរស់ប្រកបដោយសន្តិភាពសុភមង្គល និងវិបុលសុខ។ វិស្សកម្មទេវបុត្រទាំងពីរ ប្រកបដោយសំលៀកបំពាក់ស្រស់ឆើតឆាយ និងទ្រពានកន្ត្រៃទិព្វក្រាសទិព្វជាប់នឹងដៃ។ មហាសេដ្ឋីកាលបើឃើញហើយចង់បានរបស់នេះណាស់ ក៏ស្នើសុំឱ្យវិស្សកម្មទេវកម្មទាំងពីរ កាត់សាកមើលមុននឹងជឿវត្ថុទាំងនោះ។ វិស្សកម្មទេវបុត្រក៏យល់ព្រមតាមសំណូមពររបស់លោកសេដ្ឋី ហើយក៏

[៣] ដកស្រង់ចេញពីគេហទំព័រ https://search.app/oDriBNqKKuAooTvt5។

បង្ហាញថ្វីដៃឱ្យឃើញដូចចិត្ត។ ពេលកាត់សក់រួច ក៏នាំកូនប្រុសស្រីទៅងូចទឹកជំរះកាយក្នុងត្រពាំង (ពាយ) ដ៏ថ្លាឆ្វង់ និងត្រជាក់ល្ហឹម ដោយមានបទចម្រៀងច្រៀងកំដរផង។

- **អត្ថន័យនៃចម្រៀងគឺ៖** ដើម្បីអង្វរករ និងបញ្ចេញចង្រៃឧបទ្រព ព្រមទាំងបិសាចឱ្យចៀសចេញឆ្ងាយពីសាមីខ្លួនទាំងពីរនេះ ដូចជាការមុជទឹកជំរះកាយជាដើម។ ចំណែកឯមហាសេដ្ឋីកាលបើឃើញដូច្នេះក៏ភ្ញាក់ស្រឡាំងកាំង ដែលកូនទាំងពីរមើលទៅល្អដូចជាព្រះរាជា។ រួចហើយលោកក៏ចេញថ្លៃឈ្នួលកាត់សក់ និងជាវកន្ត្រៃនោះយកទុកជាកម្មសិទ្ធសម្រាប់ប្រើប្រាស់ទៅថ្ងៃមុខ។ បន្ទាប់មកសេដ្ឋីក៏សុំឱ្យទេវបុត្រទាំងពីរច្រៀងប្រសិទ្ធិពរជ័យជូនដល់កូនរបស់គាត់ទាំងពីរដើម្បីឱ្យមានសេចក្តីសុខក្នុងជីវិត និងឱ្យប្រាសចាកអំពីបាបកម្មគ្រប់យ៉ាង និងចេះតែស្រលាញ់គ្នាជារៀងរហូត។
- **ចំពោះអត្ថន័យនៃពិធីនេះគឺ៖** ជាការពិតណាស់សុភមង្គលវាអាស្រ័យនៅលើមុខមាត់រាប់បញ្ចូលទាំងសក់ក្បាល។ មនុស្សកើតមកមានតួខ្លួនសព្វគ្រប់អស់ហើយ តែប្រសិនណាបើគ្មានសក់វានាំឱ្យសម្រស់នៃរូបរាងកាយរបស់យើងក៏មិនស្អាតដែរ រហូតដល់មានពាក្យចំអែរចំអន់ថា «ត្រងោលបរបាញ់ លាបខ្លាញ់គីង្គក់ ត្រងោលដេកលក់គីង្គក់លោតថើប »។ អាស្រ័យហេតុនេះសក់ក៏ជាផ្នែកសំខាន់មួយសំរាប់ជាជំនួយដើម្បីធ្វើឱ្យសម្រស់របស់យើងកើនឡើង ប៉ុន្តែប្រសិនបើយើងមានសក់ហើយ យើងត្រូវចេះថែរក្សាដោយការកាត់តម្រឹមវាឱ្យបានត្រឹមត្រូវទៅតាមវ័យ និងភេទទៀតផង បើពុំដូចនេះទេវានឹងធ្វើឱ្យយើងគ្មានសិរីសួស្តី ដោយសារការឧបទ្រពនៃសក់របស់យើង។ ករណីនេះហើយបានជានៅពេលរៀបអាពាហ៍ពិពាហ៍ បុរាណយើងមិនភ្លេចទេនូវទំនៀមទំលាប់កាត់សក់នេះដើម្បីឱ្យកូនកំលោះកូនក្រមុំមានសម្រស់ស្រស់ស្អាតផូរផង់ ជាពិសេសនោះគឺការនាំជោគនាំជ័យសិរីសួស្តីសុភមង្គលក្នុងជីវិតគូអនាគត។

➢ **ពិធីសែនក្រុងពាលី៖** ពិធីនេះមិនថាតែពិធីរៀបមង្គលការប៉ុណ្ណោះទេ ពិធីបុណ្យទៀនផ្សេងៗក៏មានធ្វើពិធីនេះដែរ គឺដើម្បីរំលឹកគុណដល់ម្ចាស់ទឹកម្ចាស់ដី។ ប្រវត្តិនៃពិធីនេះ មានតាំងពីយូរយារណាស់មកហើយ គឺមានតាមរយៈព្រហ្មញ្ញសាសនា ព្រះឥសូរ និងព្រះនារាណ៍ជាបងប្អូនបង្កើតនឹងគ្នា ហើយជាអ្នកមានមហិទ្ធិឫទ្ធិខ្លាំងណាស់ក្នុងការគ្រប់គ្រងលោក ឯក្រុងពាលីជាអ្នកមានឥទ្ធិពលក្នុងការគ្រប់គ្រងលោកដែរ។ គេថាភ្នំមួយមិនដែរមានខ្លាពីរទេ ត្រង់ចំណុចនេះចង់មានន័យថា ខាងព្រះនារាណ៍ចង់សំដែងមហិទ្ធិឫទ្ធិរបស់ខ្លួនក្នុងការដណ្តើមទឹកដីកាន់កាប់ពីក្រុងពាលី។ ព្រះនារាណ៍ បានធ្វើល្បិចកិចកលសុំដីបីជំហានពីក្រុងពាលី។ ក្រុងពាលីមិនដឹងពីល្បិចរបស់ព្រះនារាណ៍ ក៏អនុញ្ញាតយល់ព្រមឱ្យ។ ក្រោយពីយល់ព្រមប្រគល់ដីបីជំហានពីក្រុងពាលីភ្លាម ព្រះនារាណ៍ក៏បានកាឡាខ្លួនឱ្យធំអស្ចារ្យ (ពីមុនជាមនុស្សតឿ) ហើយឈានជើងជាន់បីជំហានគឺក្នុងមួយជំហានយកអស់ឋានបាដាល មួយជំហានទៀតឋានកណ្តាល និងមួយជំហានទៀតយក

អស់ឋានព្រះព្រហ្មតែម្តង។ ក្រោយមកក្រុងពាលីអស់ដីកាន់កាប់ ក៏វិលទៅនៅចក្រវាលតរៀងទៅ ប៉ុន្តែមុននឹងទៅសូមផ្តាំថាកាលណាមានការរៀបចំសង់លំនៅឋានថ្មី ឬមានរៀបចំពិធីមង្គលការកូនប្រុសស្រី ត្រូវរៀបចំសែនព្រេនសុំទឹកដីហៅថា ក្រុងពាលីជាកិច្ចតបស្នងរំលឹកគុណដល់ក្រុងពាលី ដែលជាម្ចាស់ទឹកដីខាងដើមផង ឯព្រះនារាណ៍ក៏យល់ព្រម។ តាំងពីនោះមកទើបមានទំនៀមទំលាប់នេះជារៀងរហូតមក ។

– **ចំពោះអត្ថន័យនៃពិធីនេះគឺ៖** ដើម្បីរំលឹកគុណដល់ម្ចាស់ទឹកម្ចាស់ដី យើងដឹងហើយថាខ្មែរយើងមានជំនឿណាស់ក្នុងការគោរពដល់ម្ចាស់ទឹកម្ចាស់ដី មិនត្រឹមតែនៅក្នុងពិធីអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ មានដូចជា ពិធីសង់លំនៅឋានថ្មី ពិធីបុណ្យផ្សេងៗ សូម្បីតែការដើរចូលទៅក្នុងព្រៃតែងទន្ទេញជាប់មាត់ថា សូមឱ្យម្ចាស់ទឹក ម្ចាស់ដីដែលថែរក្សា ព្រៃភ្នំនេះជួយកូនចៅឱ្យបានសេចក្តីសុខផង រួចហើយក៏មានជាសំណែនបន្តិចបន្តួចជានិមិត្តរូបក្នុងការរំលឹកគុណ។ ដូច្នេះពេលរៀបអាពាហ៍ពិពាហ៍ កូនកំលោះត្រូវមករៀបការខាងកូនស្រី ហេតុនេះកូនកំលោះដាច់ខាតត្រូវតែរៀបពិធីសែនពេនចំពោះម្ចាស់ទឹកម្ចាស់ដីនៃផ្ទះរបស់កូនក្រមុំ ដើម្បីសុំសេចក្តីសុខ ក្នុងថ្ងៃរៀបពិធី និងជាការប្រកាសពត៌មានប្រាប់ដល់ម្ចាស់ទឹកម្ចាស់ដីមុននឹងមករស់នៅលើទឹកដីរបស់គ។

➢ **ពិធីធ្វើបុកលក្ខ័~ធ្វើធ្មេញ៖** ហេតុដែលបានជាកូនក្រមុំត្រូវធ្វើធ្មេញពីព្រោះកូនក្រមុំមានកំណើតពីសត្វនាគ។ តាមរយៈនៃពិធីនេះមានរឿងព្រេងដំណាលថា មានក្សត្រមួយអង្គ មានមហេសីជាសត្វនាគដែលប្រែខ្លួនជាមនុស្ស។ នៅពេលដែលមហេសីនោះមានការខ្វល់ខ្វាយ ដេកស្រមើស្រមៃនឹកគិតអំពីរឿងរបស់កូនដែលព្រាត់ប្រាស់គ្នាទៅ ក៏ក្លាយទៅជាសត្វនាគមួយវិញមួយរំពេច ហើយដែលធ្វើឱ្យមនុស្សគ្រប់គ្នាបានឃើញមានការភ័យខ្លាច។ ហេតុដែលបានជាមហេសីក្លាយជាសត្វនាគដូច្នេះមកពី បើតាមការទស្សន៍ទាយរបស់លោកហោរា គឺមកពីពិស នៃចង្កូមនាគដ៏មុតស្រួច ដែលធ្វើឱ្យមហេសីទៅជាររើរវាយគិតស្រមៃផ្តេសផ្តាស។ ដើម្បីរំងាប់ពិស គឺត្រូវតម្រឹមចង្កូមនាគដោយបៀមឧសថបន្សាបពិស។ ក្រោយពេលដែលមហេសីបានធ្វើការបៀមនូវឧសថនោះហើយ អាការរវើរវាយលែងកើតមានទៀតហើយ បន្ទាប់មកក៏រស់នៅប្រកបដោយសុខសានតរៀងទៅ។ លុះក្រោយមកអាចារ្យក៏ចងក្បួននេះទុកថា បើជនណារៀបមង្គលការកូនប្រុសស្រី ឬបំបួសនាគក្តីត្រូវរៀបចំនូវពិធីនេះដោយល្អប្រពៃ។

– **ចំពោះអត្ថន័យនៃពិធីនេះគឺ៖** ខ្មែរយើងនិយមធ្វើពិធីនេះនៅពេលរៀបមង្គលការកូន ប្រុសស្រីក្នុងន័យថាជីវិតជាប្តីប្រពន្ធតែងប្រើជីវិតរួមគ្នា ដូចនេះបញ្ហាតែងតែកើតមានឡើងចំពោះរូបគេ ដូចជាមានគ្រប់ រសជាតិទាំងអស់មាន ផ្អែម ប្រៃ ល្វីង ជូរ ចត់ បើសិនជាជួបនូវរសជាតិណាមួយត្រូវចេះដោះស្រាយបញ្ហានោះដោយរបៀបបន្សាបនូវរសទាំងនោះ លើកលែងតែរសជាតិផ្អែម គឺជានិមិត្តរូបនៃការផ្អែមល្ហែមនៃជីវិត ជីវិតនេះស្ថិតនៅជាអមតទាល់តែចេះអាធ្យាស្រ័យគ្នាទៅវិញទៅមក ម្យ៉ាង

ទៀតខ្មែរយើងនិយមធ្វើពិធីនេះគឺដើម្បីរំងាប់ពិសនៅក្នុងមាត់ព្រោះថាអ្វីៗដែលចេញពីមាត់ គឺវាមាន លាយឡំទាំងល្អ និងអាក្រក់ ដូចនេះខ្មែរនិយមឱ្យកូនប្រុសស្រីធ្វើធ្មេញ កាលបើធ្វើរួចហើយ រឿង ដែលចេញពីមាត់ទៅគឺឱ្យមានតែពាក្យផ្អែមល្ហែម ត្រជាក់ ស្រទន់ ទើបជាទីរាប់អានរបស់ញាតិផង ទាំងពួង ហើយក៏ជាចំណុចសុភមង្គលក្នុងជីវិតផងដែរ។

- **ពិធីលាងជើង៖** ជាពិធីមួយដែលខ្មែរយើងបានចាត់ទុកនាពេលចុងបញ្ចប់នៃពិធីអាពាហ៍ពិពាហ៍។ ពិធីមាន រឿងដំណាលថា កាលពីព្រេងនាយព្រះថោងបានរង់ចាំនាងនាគ មកទទួលទៅឋានភុជង្គនាគ ប៉ុន្តែស្តេច ភុជង្គនាគបានរារាំងបុត្រីមិនឱ្យមកជួបព្រះថោង។ ព្រះថោងឈរចាំនាងនាគនៅលើថ្មរហូតដល់លោកជើង ទើបនាងនាគរត់គេចពីបិតាមកជួបស្វាមី។ បុរាណបានកំណត់ថាថ្មជាតំណាងទឹកចិត្តមនុស្ស ចិត្តធ្ងន់ដូចថ្ម កុំប្រែប្រួលឡាស់។ រីឯទឹក តំណាងទឹកចិត្តស្រីគ្មានស្រលាញ់អ្វីលើសពីប្តី ចំណែកឯនៅពេលធ្វើពិធីនេះស្ត្រី លុតជង្គង់ចង់សំដៅថា កាលពីនៅវ័យក្រមុំពឹងឪពុកម្តាយ លុះដល់ពេលរៀបការពឹងប្តី។
  - **ចំពោះអត្ថន័យនៃពិធីនេះគឺ៖** យើងត្រូវយល់ថាមុននឹងចូលផ្ទះរបស់អ្នកម្នាក់ បុរាណលោកមាន ទំនៀមឱ្យលាងជើងសិន រួចហើយសឹមចូល ដោយហេតុថាកាលណាយើងធ្វើដំណើរមកតាមផ្លូវ រមែងតែងប្រលាក់ដីជាមិនខានជាពិសេសគឺជើងតែម្តង ដូចនេះហើយកូនកំលោះមុននឹងចូលផ្ទះកូន ក្រមុំត្រូវតែលាងជើងសិន ដើម្បីឱ្យមានសិរីសួស្តី ព្រោះសិរីសួស្តីនេះកើតមកពីភាពស្អាតនេះឯង។ ម្យ៉ាងទៀតមូលហេតុដែលចាស់បុរាណលើកឡើងនូវពិធីនេះក៏វាបានឆ្លុះបញ្ចាំងពី របៀបរបបរបស់ ខ្មែរយើងកាលណាមានភ្ញៀវមក គឺត្រូវចេញទៅទទួលភ្ញៀវដោយភ្ជាប់មកនូវទឹកដើម្បីឱ្យភ្ញៀវជំរះធូលី ដែលប្រលាក់។ ប៉ុន្តែនៅក្នុងពិធីនេះនាងនាគលាងជើងឱ្យស្វាមី ត្រង់ចំណុចនេះចង់បញ្ជាក់ពីការ លើកតម្កើនបុរសនៅក្នុងគ្រួសារជាមេគ្រួសារ ដែរភរិយាមានភារកិច្ចប្រតិបត្តិស្វាមីគ្រប់បែបយ៉ាង មិនត្រឹមតែការលាងជើងប៉ុណ្ណេះទេ។ អត្ថន័យមួយទៀត គឺដើម្បីជំរះនូវឧបទ្រព្យចង្រៃកើតមានតាំង ពីមុន ឱ្យវិនាសសាបសូន្យចាប់ពីពេលនេះតទៅ។
- **ពិធីជ័យហោង សួស្តីហោង៖** មានសេចក្តីដំណាលថា មានបុរស២នាក់ជាបងប្អូនបង្កើតនឹងគ្នា បងឈ្មោះ ជ័យ និងប្អូនមានឈ្មោះ សួស្តី។ បុគ្គលទាំងពីរជាមនុស្សមានភ័ព្វវាសនាល្អនឹងមានបុណ្យដ៏អស្ចារ្យ។ គ្រា នោះដូនជាផុតវង្សក្សត្រត្រិយ៍ ក្នុងនគរកម្ពុជាយើងនេះ អស់នាម៉ឺនសព្វមុខមន្ត្រី រាជបុរោហិតាចារ្យ នាំគ្នា ផ្សងសេះ-ដំរីមង្គល ឱ្យស្វែងរកអ្នកមានបុណ្យ។ ដំរី-សេះនោះក៏ដើរតម្រង់ឆ្ពោះទៅកាន់គេហដ្ឋានជ័យ និងសួ ស្តីនោះ ទើបនាម៉ឺនសព្វមុខមន្ត្រីដឹងច្បាស់ថា បុរសទាំងពីរនាក់បងប្អូនជាអ្នកមានបុណ្យ ក៏អញ្ជើញបុរស ទាំងពីរឱ្យឡើងជិះដំរីមក។ បងឈ្មោះ ជ័យ ត្រូវអភិសេកឱ្យធ្វើជាស្តេចគ្រងរាជ្យ ប្អូនឈ្មោះ សួស្តី តាំងឱ្យធ្វើ

ជា មហាឧបរាជ។វេលាដែលអភិសេកនោះ ប្រជាពលរដ្ឋទាំងអស់គ្នាស្រែកថ្វាយស័ព្ទសាធុការថា ជ័យ ហោង សួស្តីហោង ព្រមៗគ្នាឡើង។

- **ពិធីបង្វិលពពិល** ពិធីនេះមាននិទានដំណាលថា កាលពីយូរលង់ណាស់មកហើយមានកូនស្តេចមួយអង្គ ព្រះនាមថា ព្រះជ័យសុរិយារាជកុមារ នៅនគរកែកេតុជម្ពូទ្វីប បានទៅស្វែងរករៀនសិល្ប៍សាស្ត្រនឹងព្រះឥសូរ នៅភ្នំកៃលាស។ ព្រះឥសូរបានស្តោះទឹកមាត់ដាក់ព្រះឱស្ឋនៃព្រះរាជកុមារនោះឱ្យមានកំលាំងដូចដំរីសារ។ នៅពេលរៀបលាព្រះឥសូរមកនគរវិញ ព្រះរាជកុមារបានទទួលសុំពរពីព្រះឥសូរនូវវត្ថុអនុស្សាវរីយ៍ សំរាប់ពេលដែលខ្លួនរៀបអាពាហ៍ពិពាហ៍។ ព្រះឥសូរក៏បានប្រសិទ្ធីដីខ្សាច់ពីភ្នំចក្រវាឡ ធ្វើជាស្លឹកពោធិ៍មាស (តំណាងយោនី របស់ព្រះនាងឧមាមហេសីព្រះឥសូរ) និងជប់ថ្មពេជ្រពីភ្នំហិមាល័យ ជាទៀនពេជ្រ (តំណាងអង្គជាតិរបស់ព្រះឥសូរ) សន្មតឈ្មោះថាពពិលនិរត្តន៍) ប្រទានដល់រាជកុមារជ័យសុរិយានោះ។ អាស្រ័យដូចនេះហើយទើបមានពិធីនេះជារៀងរហូតតមក។
  - **ចំពោះអត្ថន័យនៃពិធីនេះគឺ៖** ការរំលឹកដល់ការបន្តពូជពង្សរបស់មនុស្ស។ មនុស្សកើតមក ត្រូវមានការចូលរួមរវាងធាតុពីរជាចំបាច់ ដែលធាតុនោះគឺទាល់តែមានមនុស្សប្រុស និងមនុស្សស្រីបូកបញ្ចូលគ្នា។ ដូចនេះបុរាណលើកឡើងនូវពិធីនេះគឺជានិមិត្តរូបនៃការបង្កើតមនុស្សនេះឯង ដែលយើងបានឃើញស្រាប់ហើយនៅក្នុងពិធីនេះមាន៖
- **ពិធីសំពះពេលា និងតោងស្បៃ៖** ពិធីនេះតាមរឿងព្រេងដំណាលថា កាលព្រះរាជកុមារបាននាងធារាវតី ជាព្រះរាជបុត្រីស្តេចភុជង្គនាគ រួចហើយស្តេចភុជង្គនាគក៏បានឡើងមករៀបអភិសេកព្រះថោង។ ពេលនោះរៀបឱ្យមានអាចារ្យកាន់ ពេលាថ្វាយព្រះថោង ឱ្យព្រះថោងឡើងគង់លើបល្ល័ង្ក ចាំពេលាឱ្យមហាកាន់ឈ្មោះវាយប្រជុំ ហើយឱ្យមានភ្លេងត្រែស័ង្ខដង្ហែព្រះថោង ឡើងទៅសំពះមង្គលការ។ លុះសំពះពរជ័យស្រេចហើយព្រះថោងនឹងយាងទៅពិភពនាគ ពេលនោះនាងនាគឱ្យព្រះថោងជាស្វាមីតោងជាយស្បៃនាងទើបទៅបាន។ លុះទៅដល់ពិភពនាគវេលាណា នាងនាគក៏យកគ្រឿងប្រដាប់នាគ មកថ្វាយព្រះថោងទ្រង់។ ហេតុនេះហើយបានជាអ្នកនគរយកតម្រាប់តាមរៀងមក បើអ្នកណាមួយរៀបមង្គលការកូនចៅ គេឱ្យមានអាចារ្យកាន់ពេលា ឱ្យអង្គុយចាំពេលា។ លុះសំពះហើយក្រោកចូលទៅក្នុង គេឱ្យប្រុសតោងជាយស្បៃស្រី រួចឱ្យស្រីឱ្យសំពត់ទៅប្រុសផ្លាស់ ជាប់ជាទំនៀមផ្សេងៗ តាំងពីព្រះថោងតោងស្បៃនាងនាគ ដរាបមកដល់សព្វថ្ងៃនេះ។
  - **ចំពោះអត្ថន័យនៃពិធីនេះគឺ** កាលដើមឡើយខ្មែរមានជំនឿយ៉ាងមុតមាំថា មុននឹងធ្វើអ្វីមួយត្រូវតែមានពេលវេលាមួយច្បាស់លាស់ ដើម្បីឱ្យការងាររបស់យើងទទួលបានជោគជ័យ។
- **ពិធីផ្កាស្លាបី៖** មានកុមារកំព្រា៤នាក់ជាសំលាញ់នឹងគ្នាមានឈ្មោះមិនប្រាកដ បានបបួលគ្នាទៅរៀនសិល្ប៍សាស្ត្រ។ លុះធ្វើដំណើរយូរទៅ ក៏បានជួបប្រទះនឹងអាចារ្យទិសាបាមោក្ខម្នាក់ដែលជាអ្នកបង្រៀនសិល្ប៍វិជ្ជា

គ្រប់មុខ។ កុមារទាំងបួននាក់ក៏ចូលទៅលើកដៃសំពះសុំស្នាក់នៅដើម្បីឱ្យអាចារ្យបង្រៀនសិល្បសាស្ត្រ។ អាចារ្យក៏យល់ព្រមទទួលកុមារទាំងបួនឱ្យជ្រកកោនជាមួយ។ កុមារទាំងបួននោះខំយកចិត្តទុកដាក់បំរើអាចារ្យអស់ចំនួន៥ឆ្នាំមិនឱ្យអាក់អន់ស្រពន់ចិត្តអ្វីឡើយ។ អាចារ្យក៏មានមេត្តាបង្រៀនសិល្បវិជ្ជាគ្រប់គ្នា គឺម្នាក់ឱ្យរៀនគម្ពីហោរា ម្នាក់ឱ្យរៀនសិល្បបាញ់ធ្នូស្នា ម្នាក់ឱ្យរៀនសិល្បមុជទឹក ម្នាក់ទៀតឱ្យរៀនសិល្បប្រស់ជីវិតមនុស្ស-សត្វ ដែលស្លាប់ហើយ ឱ្យរស់វិញបាន។ ទាំង៤នាក់ចេះសិល្បដ៏វិសេសផ្សេងៗគ្នា ។សម័យថ្ងៃមួយអ្នកទាំងបួនក៏គិតគ្នា យើងទាំងអស់គ្នារៀនសិល្បវិជ្ជាចេះគ្រប់ៗគ្នាហើយ រីឯខ្លួនក៏ធំពេញវ័យហើយដែរ ដូចនេះគួរយើងនាំគ្នាទៅសុំលាព្រះអាចារ្យទៅស្វែងរកទ្រព្យសម្បត្តិ ប្រពន្ធកូនរៀងៗខ្លួនចុះ។ គិតព្រមគ្នារួចហើយ ក៏ចូលទៅក្រាបបង្គំទូលលាព្រះអាចារ្យ លោកអាចារ្យក៏យល់ព្រមតាមសេចក្តីប្រាថ្នាឥតបីឃាត់ឃាំងអ្វីឡើយ។ អ្នកទាំងបួនក្រាបលាព្រះអាចារ្យរួចហើយ ក៏ដើរទៅដល់សមុទ្រធំ រកទូក ឬសំពៅនឹងឆ្លងទៅត្រើយម្ខាងពុំបាន ក៏នាំគ្នាដេកសំរាកក្រោមដើមឈើនាមាត់សមុទ្រនោះ។ អ្នកបីនាក់និយាយនឹងអ្នករៀនគម្ពីហោរា សំលាញ់ សំលាញ់ ឯងបានរៀនវិជ្ជាខាងហោរាសាស្ត្រ យើងចង់ដឹងណាស់ថា តើវិជ្ជានេះពូកែស័ក្តិសិទ្ធិយ៉ាងណា? ចូលអ្នកវាយលេខទាយល៍មើល! តើថ្ងៃស្អែកនេះ យើងបានឆ្លងទៅត្រើយម្ខាងដែររឺទេ? ម្យ៉ាងទៀតតើពួកយើងនឹងមានលាភអ្វីខ្លះ? បុរសដែលរៀនវិជ្ជាហោរាក៏ចាប់វាយលេខមើលសពជគ្រប់ហើយទាយថា ស្អែកនេះនាពេលព្រឹក ថ្ងៃពេញពន្លឺ យើងនឹងមានមហាលាភធំ តាមទំនាយថានឹងមានសត្វឥន្ទ្រីចាប់ពាំកូនក្រមុំស្តេចមួយហើរឆ្លងសមុទ្រមកពីទិសបូព-ប្រាកដ តើពួកអ្នកនឹងគិតយ៉ាងដូចម្តេច? បុរសចេះសិល្បបាញ់ធ្នូទទួលរាប់រង ត្រង់នេះទុកងារឱ្យខ្ញុំ ខ្ញុំនឹងបាញ់ដណ្តើមយកពីមាត់សត្វនោះឱ្យបានកុំបារម្ភ។ លុះព្រឹកឡើងថ្ងៃរះពេញពន្លឺ សត្វឥន្ទ្រីក៏ពាំក្រមុំស្តេចហើរឆ្លងសមុទ្រមកមែន។ បុរសចេះបាញ់ធ្នូ ហេតុតែត្រេកអរពេកឥតបានពិចារណាក៏បាញ់ភ្លាម ត្រូវសត្វធ្លាក់ទាំងនាងក្រមុំទៅក្នុងទឹកសមុទ្រ។ បុរសចេះហែលមុជ ទឹកជានាខ្លួនខ្ញុំនឹងហែលទឹក មុជទៅយកនាងមកឱ្យបានពីក្នុងសមុទ្រ ហើយក៏លោតទឹកហែលទៅស្រង់នាងនោះបានមកលើគោក តែនាងក្រមុំនោះរលត់សង្ខារទៅហើយ។ បុរសចេះសិល្បប្រស់ជីវិត ក៏សូត្រស្រែកសិល្បវិជ្ជាប្រស់ នាងនោះរស់ជីវិតឡើងវិញ។ ដោយនាងក្រមុំមានរូបល្អតល្អន់ឥតខ្ចោះ បុរសទាំងបួនក៏តាំងដណ្តើមគ្នាធ្វើជាប្រពន្ធរៀងខ្លួន។

- បុរសហោរា នាងនេះត្រូវបានយើង ព្រោះដើមកំណើតពីយើងទាយ។
- បុរសចេះបាញ់ អ្នកគ្រាន់តែទាយ កុំតែយើងបាញ់ធ្វើម្តេចបាន ត្រូវតែឱ្យនាងនោះមកធ្វើជាប្រពន្ធយើង។
- បុរសចេះមុជទឹកតប អ្នកបាញ់ធ្លាក់កណ្តាលសមុទ្រមែន កុំតែបានយើងហែលទឹកទៅយកមកធ្វើម្តេចនឹងបានត្រូវឱ្យនាងមកយើងធ្វើជាប្រពន្ធ។

◦ បុរសចេះប្រស់ អ្នកបានទៅយកពីក្នុងទឹកមែន តែនាងនោះអស់ជីវិតទៅហើយ បើកុំតែបាន យើងចេះប្រស់ធ្វើម្ដេចនឹងបានរស់ឡើងវិញ ដូចនេះនាងនេះត្រូវបានមកជាប្រពន្ធយើង។

បុរសទាំងបួនមិនសុខចិត្តរៀងខ្លួន ក៏នាំគ្នាបណ្ដើរស្រីនោះទៅរកចៅក្រមកាត់ក្ដីឱ្យ។ ក្រោយពីទទួលបណ្ដឹង ចៅក្រមក៏ឈ្វេងយល់ក៏បង្គាប់ទៅឱ្យចៅហោរា និងបុរសចេះប្រស់ឱ្យអង្គុយលើអាសនៈខ្ពស់ស្មើគ្នា បុរសចេះបាញ់ឱ្យអង្គុយបន្ទាប់ក្រោម បុរសចេះមុជទឹកឱ្យអង្គុយបន្ទាប់ពីក្រោមបង្អស់។ បន្ទាប់មក ក្រុមចៅក្រមក៏ប្រជុំកាត់សេចក្ដីថា បុរសហោរាដែលចេះទាយត្រូវលើកទុកជាឪពុកនាង បុរសចេះប្រស់ឱ្យរស់ជីវិតត្រូវទុកជាម្ដាយនាង បុរសចេះបាញ់ធ្នូត្រូវទុកជាបងបង្កើតរបស់នាង ព្រោះត្រូវការពារសង្គ្រោះប្អូនស្រី។ ចំណែកឯបុរសចេះមុជទឹកត្រូវទុកជាប្ដីនាងនេះ ព្រោះគេបានទៅប៉ះពាល់ដល់រូបកាយនាង តាំងពីក្នុងទឹកមុនគេ។ បុរសទាំងបួនក៏ទទួលយល់ព្រមតាមពាក្យចៅក្រមកាត់សេចក្ដី។ ប៉ុន្តែបុរសទាំងបី តបថា លោករៀបចំទុកដាក់យើងខ្ញុំ ជាឪពុក ជាម្ដាយ ជាបងនេះ យើងខ្ញុំសុខចិត្តហើយ តែសូមលោកមេត្តាជ្រើសរើសរបស់អ្វីដ៏ប្រសើរទុកជាដំណាងមង្គលតទៅមុខ ដើម្បីឱ្យកូនប្រសារបស់ឪពុកម្ដាយ និងបងក្នុងគ្រានេះផង។ ពេលនោះ គេក៏នាំគ្នាចាត់ចែងរកកាត់ផ្កាស្លាមួយខ្លួយកមក រៀបតុបតែងចែកជាបីចំណែកតំណាងអ្នកទាំងបី។ចំណែកដុំផ្កាស្លាបងត្រូវឪពុកទទួលពីដៃកូនប្រសា ចំណែកផ្កាស្លាកណ្ដាលត្រូវម្ដាយទទួល ចំណែកផ្កាស្លាពៅត្រូវបងបង្កើតទទួល។ ទំនៀមនេះ ក៏ជាប់រហូតមកដល់សព្វថ្ងៃនេះ។

– **ចំពោះអត្ថន័យនៃពិធីនេះគឺ៖** ធ្វើឡើងដើម្បីរំលឹកគុណដល់មាតា បិតា ដែលបានខិតខំចិញ្ចឹមបីបាច់តាំងពីតូចក្រូចឆ្មារមក។ យើងឃើញថានៅក្នុងពិធីនេះគេរៀបចំ ផ្កាស្លារុំអំបោះជាបីដុំ ដែលដុំទី១ ផ្កាស្លាច្បង ត្រូវដោតម្ជូចំនួន២១ មានន័យថា គុណឪពុក ដុំទី២ ផ្កាស្លាកណ្ដាល មាន១២ គឺគុណម្ដាយ ឯផ្កាស្លាពៅ មាន ៦ ចំពោះគុណបង ឬញាតិ។ ដូចនេះការរៀបចំនូវពិធីនេះឡើងគឺក្នុងគោលបំណងធំការដឹងគុណនេះឯង។

➢ **ពិធីបើកវាំងននៈ** ពិធីនេះមានរឿងដំណាលថា កាលដើមឡើយជ័យនឹងសួសជាមិត្តភ័ក្តិជិតស្និទ្ធ។ កាលបើជ័យចូលស្ដីដណ្ដឹងកូនគហបតី នៅបញ្ជូនគ្រាមបានហើយ មេបាតម្រូវបង្គាប់ឱ្យជ័យទៅរកឃ្មុំដើម្បីធ្វើទៀនពេលាមង្គលការ។ ជ័យនិងសួសបានបបួលគ្នាចូលព្រៃ សួសឱ្យជ័យដាក់សង្រែកឡើងចុងឈើរួចអូសជ័យឡើងលើ ហើយកាត់ខ្សែចោល។ បន្ទាប់មកសួសមានគំនិតក្បត់ ក៏រត់បកប្រាប់អ្នកដើមការ (គហបតី) ថាជ័យស្លាប់ហើយ។ មាតាបិតាក៏ជឿទាំងស្រុងហើយដើម្បីកុំឱ្យកូនមេម៉ាយឥតខាន់ស្លា ក៏សំរេចលើកកូនឱ្យទៅសួស។ លុះដល់ពេលអ្នកភ្លេងលេងបទបើកវាំងននសុំឱ្យអនចេញមក អ្នកភ្លេងរកអ្នកណាច្រៀងមិនបានដើម្បីឱ្យកូនក្រមុំចេញមក។ និយាយពីជ័យវិញបានបួងសួងដល់អស់អារុក្ខអារក្ស អ្នកតា ដែលស្ថិតនៅតាម

ព្រៃព្រឹក្សាអ្នកតាវល្លិ៍ដើម្បីឱ្យជួយ។ ពេលនោះទេវតាចាស់ស្រុកក៏និមិត្តជាវល្លិ៍មាសប្រាប់ឱ្យជ័យចុះមក។ ដោយពេលវេលាថ្ងៃការមកដល់ ជ័យបានរត់ទៅជួបអ្នកភ្លេង ហើយធានាខ្លួនជាអ្នកភ្លេងដ៏ប៉ិនប្រសប់។ ជ័យច្រៀងបទអនអើយស្រីអន នាងអនមិនព្រមចេញពីល្វែងឡើយ ទើបអ្នកភ្លេងសួរគ្នាថាជ័យ ឬសួស ឆ្លើយថាជ័យគ្រប់បីដង អនដឹងថាជ័យទើបចេញមកឱបជ័យ។ ពេលនោះជ័យកាន់ដាវកាប់សួសចោលទៅ ទើបរហូតមកដល់សព្វថ្ងៃនេះ អ្នកភ្លេងរាំចាំបើរាំងនន មានកាន់ដាវនៅដៃ។

- **ពិធីបើកផៀបបាយសី កន្សែងប្រាំហត្ថ ហូតដាវនិងសារកន្ទេល៖** ពិធីនេះមានរឿងដំណាលថា មានអ្នកមន្ត្រីធំម្នាក់ជាអ្នកបំពីស្តេចនៅនគរពារានសី។ ស្តេចបានប្រគល់តួនាទីទៅមន្ត្រីនោះដើរត្រួតត្រាមើលស្រុកទេសជនបទក្នុងនគរព្រោះប្រជារាស្ត្រចេះតែបះបោរ។ ទៅដល់ភូមិមួយ នាម៉ឺននោះមានចិត្តស្រលាញ់កូនក្រមុំនៅក្នុងភូមិនោះ ហើយបានទុកមាសបីតម្លឹងបញ្ជាំចិត្តនាងសិន សន្យាថាបីខែទៀតនឹងត្រឡប់មករៀបការតាមរបៀបអ្នកស្រុកភូមិវិញមិនខាន។ ពេលត្រឡប់ទៅដល់ទីក្រុងចេះតែមានធុរះរវល់យូរៗទៅ កន្លងហួសរហូតដល់បីឆ្នាំ មិនបានរៀបការតាមសន្យា។ ដោយសារយូរពេកឪពុកម្តាយបានសំរេចចិត្តរៀបការនាងទៅឱ្យបុរសផ្សេងៗ។ ចៃដន្យនៅថ្ងៃរៀបការ នាម៉ឺននោះនឹកឃើញបញ្ជាំមាសនាងនោះបីតម្លឹងក៏អន្ទះអន្ទែងរសាប់រសល់នៅពុំសុខ ក៏ឡើងទៅទូលព្រះមហាក្សត្រសុំសេនាទាហានចេញទៅត្រួតត្រាស្រុកក្រៅ។ ពេលដែលនាម៉ឺនទៅដល់ភូមិនោះ បានឃើញនារីដែលខ្លួនបញ្ជាំចិត្តកំពុងសំពះផ្ទឹមជាមួយប្តីថ្មី នាម៉ឺននោះខឹងខ្លាំងណាស់ ក៏ស្ទុះឡើងលើផ្ទះ ចាប់ទាញដៃនាងនោះមក ហើយហូតដាវសម្លាប់ប្រុសនោះនៅកន្លែងសំពះការ។ ឈាមក៏បាញ់ប្រលាក់ទៅពេញផ្ទះ បណ្តាជនដែលមកចូលរួមពិធីការភិតភ័យ ភ្ញាក់ផ្អើលរត់ចូលព្រៃអស់។ នាម៉ឺនក៏នាំនាងមកកន្លែងរៀបការវិញ។ ចំណែកឪពុកម្តាយព្រមទាំងញាតិសាលោហិត ភ័យខ្មៅមុខគ្រប់គ្នាក៏ទៅអញ្ជើញព្រាហ្មព្រឹទ្ធាចារ្យដែលចេះមន្ត ឱ្យមកសូត្របាចទឹករម្ងាប់ចង្រៃខ្មោចដែលស្លាប់លើផ្ទះ ត្រង់កន្លែងសំពះការនោះហើយសារកន្ទេលចោលទៅ។ លុះតំណក្រោយៗមកក្នុងពិធីមង្គលការ ក្រោយពីអង្គុយសំពះការហើយ គេមិនទាន់ឱ្យរុះរើកន្ទេល ខ្នើយទេ ចំឱ្យអាចារ្យរម្ងាប់សិន ដើម្បីឱ្យអស់ចងជាទំនៀមទំលាប់រហូតមក។ ហេតុនេះហើយ ទើបខ្មែរយើងនិយមឱ្យដាក់ដាវផ្ទឹមការ ហើយមានពិធីរាំសាកន្ទេល ជាប្រពៃណីរៀងមកដល់សព្វថ្ងៃនេះ។
- **ពិធីរៀបផ្លែឈើឱ្យបាន៣៦មុខ៖** ពិធីនេះមានរឿងព្រេងមួយដំណាលថា កាលពីព្រេងនាយមានព្រានព្រៃម្នាក់មានភារកិច្ចត្រូវចេញទៅបរបាញ់សត្វយកមកថ្វាយស្តេចជារៀងរាល់ថ្ងៃ។ ថ្ងៃមួយព្រានត្រឡប់មកផ្ទះវិញគ្មានសត្វមួយសោះ ព្រាននោះមានការបារម្ភណ៍ខ្លាំងណាស់។ ប៉ុន្តែត្រូវត្រឡប់មកវិញដើម្បីទូលស្តេចពីបញ្ហាបណ្តាលឱ្យដៃទទេយ៉ាងនេះ។ នៅពេលនោះព្រានបានសុំការប្រទានទោសអំពីព្រះមហាក្សត្រ ព្រោះខ្លួនរវល់តែមើលហ្វូងស្វារៀបការកូនប្រុសស្រីរបស់វា ហើយព្រាននោះបានរៀបរាប់នូវព្រឹត្តិការណ៍បានកើត

ឡើង។ ពិធីរបស់ពពួកសត្វស្វានោះបានធ្វើឱ្យពួកព្រានភ្លឹកអារម្មណ៍ ព្រោះចិត្តជាប់លួចមើល នូវសភាពការដ៏ចម្លែកនោះ។ ពពួកស្វាមានស្មារតីជួយសាមគ្គីគ្នាណាស់ ស្វាមួយៗសុទ្ធតែខំដើររកផ្លែឈើឱ្យបានពេញដៃដើម្បីយកមកទុកក្នុងពិធីការកូនញាតិមិត្តរបស់វា។ វាលើកដើរជាជួរៗដង្ហែកូនប្រុស ដៃកាន់ផ្លែឈើ គ្រប់មុខផ្សេងៗគ្នា ហើយព្រានរាប់ទៅឃើញថាមានចំនួន៣៦មុខ។ ព្រាននោះបានទូលស្តេចទៀតថា បើព្រះអង្គមានចំណង់ជ្រាបការពិត សូមទ្រង់បញ្ជាឱ្យយករទេះ ទៅដឹកផ្លែឈើនៅសេសសល់ក្នុងគំនរនោះមករាប់ចុះ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ក៏ចេញបញ្ជាឱ្យអាម៉ាតយករទេះទៅដឹកផ្លែឈើទាំងនោះមកហើយរាប់ទៅឃើញ៣៦មុខមែន។ ចាប់តាំងពីនោះមកព្រះរាជា ទ្រង់បញ្ជាថា ប្រសិនបើអ្នកណារៀបការកូនត្រូវជួយគ្នារកផ្លែឈើឱ្យបាន៣៦មុខដូចស្វា ព្រោះកុំឱ្យមនុស្សយើងចាញ់ស្វាដែលជាសត្វ។

បើតាមឯកសាររបស់អ្នកស្រី **កែវ ណារុំ** ដដែលនេះបញ្ជាក់ថា ផ្លែឈើទាំង៣៦មុខនេះមានទំនាក់ទំនងនឹងព្រះពុទ្ធសាសនា។ តាមពិតមិនមែន៣៦មុខទេ គឺមានដល់៣៨មុខឯណោះ។ មូលហេតុដែលនៅសល់៣៦មុខនេះដោយសារ អ្នកចម្រៀងច្រៀងមិនច្បាស់ ហើយច្រៀងថា៣៦មុខទៅ។ ផ្លែឈើទាំង៣៦នៃពុទ្ធបរិស័ទ្ធទាំងឡាយសំអាងទៅលើអក្ខរានៃធម៌ថ្វាយបង្គំ មួយចប់មាន៣៨អក្ខរា។ ម្យ៉ាងទៀតធម៌នេះគឺនាំឱ្យមនុស្សរកភពនៃសេចក្ដីសុខបានដោយការបើពាក្យសំដីពិរោះផ្អែមល្ហែម។ ដូច្នេះយើងឃើញថា ផ្លែឈើដែលគេយកមកហែរជំនូននេះគឺសុទ្ធតែផ្លែឈើដែលមានរសជាតិ និងមាននិមិត្តរូបល្អផងដែរ ដូចជា ផ្លែមៀន មានរសជាតិផ្អែម ហើយជានិមិត្តរូបនៃការសម្បូរសប្បាយនៃទ្រព្យសម្បត្តិ ទៀតផង។ ពិធីនីមួយៗក្នុងពេលរៀបមង្គលការនៅក្នុងសង្គមខ្មែរយើង វាកើតឡើងពីជំនឿតៗគ្នាពីម្នាក់ទៅម្នាក់ ក្នុងគោលបំណងតែមួយគត់ដើម្បីឱ្យបានសេចក្ដីសុខ។ ប្រសិនបើជំនឿនោះបានដក់ជាប់នៅក្នុងចិត្តហើយ វាប្រៀបបានទៅនឹងស្រមោលដែលអន្ទោលតាមប្រាណ បើមិនធ្វើក្លាចក្រែងពុំមានសេចក្ដីសុខ និងមួយវិញទៀតនៅក្នុងសង្គមខ្មែរបានឱ្យតម្លៃណាស់ចំពោះប្រពៃណីពេលរៀបការ។ មានន័យថា គូស្វាមីភរិយាណាយកគ្នាជាប្ដីប្រពន្ធដោយមិនបានរៀបការនោះ នាំឱ្យសង្គមគេមិនទទួលស្គាល់ រួចហើយនាំឱ្យគ្មានសេចក្ដីសុខនៅក្នុងជីវិត។ បើយើងបានរៀបការហើយ គួរតែរៀបចំពិធីនេះឱ្យបានត្រឹមត្រូវ បើសិនជាខ្វះចន្លោះក៏ខ្លាចក្រែងមិនបានសេចក្ដីសុខដែរ ករណីដូចជាពិធីសែនដូនតា ពិធីនេះគ្មានប្រភពដើមច្បាស់លាស់ទេ គ្រាន់តែមានជំនឿថា ខ្មែរយើងមានជំនឿទៅលើព្រលឹង ទោះបីស្លាប់បាត់បង់រូបកាយទៅហើយក្ដី ព្រលឹងនៅតែវិលវល់ចំពោះអ្នកនៅរស់ជានិច្ច។ ដូចនេះហើយខ្មែរយើងមានជំនឿ ដែលជំនឿយូរទៅៗក្លាយជាទំនៀមទំលាប់ ដែលធ្វើអ្វីក៏ដោយក៏មិនភ្លេចទេការបន់ស្រន់ដល់អ្នកដែលស្លាប់ទៅតាមរយៈ ព្រលឹងនេះឯង។

រួមសេចក្តីមក អាពាហ៍ពិពាហ៍ខ្មែរមានច្រើនពិធីណាស់ ហើយមានលក្ខណៈវែងឆ្ងាយទៀតផង។ ពិធីនីមួយៗសុទ្ធតែបានបង្កប់នូវអត្ថន័យល្អៗ ដែលជាបទពិសោធន៍សំរាប់អប់រំដល់កូនចៅជំនាន់ក្រោយឱ្យអនុវត្តតាម។ ពិធីមង្គលការដែលយើងកំពុងអនុវត្តសព្វថ្ងៃនេះ(មិនរាប់បញ្ចូលពិធីបរទេស) គឺបានកើតឡើងជាបន្តបន្ទាប់គ្នាចាប់តាំងពីមុនសម័យនគរភ្នំមកម្ល៉េះ ហើយក៏បានវិវត្តតាមទម្រង់ផ្សេងៗគ្នាដោយស្របទៅតាមសង្គមរបស់ខ្មែរយើង។ មុននឹងបុព្វបុរសយើងទទួល និងបង្កើតនូវពិធីណាមួយ លោកតែងយល់ឃើញថា ពិធីទាំងនោះនឹងជួយធ្វើឱ្យគូរស្វាមីភរិយាដែលរៀបការបានសេចក្តីសុខសេចក្តីចម្រើន និងមិនមានគ្រោះថ្នាក់អ្វីមកកើតឡើងដល់ពួកគេទាំងពីរឡើយ។ ដូចនេះគួរតែយើងគ្រប់គ្នាស្វែងយល់ នូវអត្ថន័យ នៃពិធីនេះជាបន្តទៀត ព្រមទាំងរួមគ្នាជួយថែរក្សាសូមកុំបោះបង់ តែគួរកុំនាំទំនៀមបរទេសមកអនុវត្តដើម្បីជៀសវាងការភាន់ច្រលំទៅថ្ងៃអនាគត។[4]

### ១.២.២. អាពាហ៍ពិពាហ៍តាមប្រពៃណីជាតិខ្មែរ

យោងតាមឯកសារប្រវត្តិសាស្ត្រមួយចំនួនបានសន្និដ្ឋានថា «អាពាហ៍ពិពាហ៍ខ្មែរបានចាប់បដិសន្ធិឡើងនៅក្នុងសម័យហ្វូណន ឬសម័យអាណាចក្រភ្នំ ឬសម័យនគរគោកធ្លក នៅដើមសតវត្សទី១នៃគ្រិស្តសករាជក្នុងរជ្ជកាលព្រះនាងលីវយី និងព្រះបាទហ៊ុនទាន»។ ដោយប្រជាជនខ្មែរនិយមឱ្យតម្លៃលើស្ត្រី ឬយើងហៅថា មាតាធិបតេយ្យ ដែលមកដល់បច្ចុប្បន្នយើងឃើញមានសុភាសិតក៏ដូចជា រឿងដំណាលជាច្រើនដែលលើកកម្ពស់ស្ត្រី ដូចជា រឿងដំណាលអំពី ព្រះថោងតោងស្បៃនាងនាគជាដើម ដែលប្រជាជនបានប្រារព្ធពិធីមួយដែលតម្រូវឱ្យកូនកំលោះតោងស្បៃកូនក្រមុំក្នុងដំណាក់កាលនៃការរៀបអាពាហ៍ពិពាហ៍ និងមានសុភាសិតផ្សេងៗដែលបានលើកឡើងថា «សំណាបយោងដី ស្រីយោងប្រុស» ជាដើម។

ជាក់ស្តែង ការរៀបអាពាហ៍ពិពាហ៍របស់ប្រជាជនខ្មែរតាំងពីសម័យបុរាណមក គឺគ្រួសារខ្មែរបានប្រើពេលវេលាយូរថ្ងៃ យូរខែទម្រាំអាចឈានដល់ការរៀបអាពាហ៍ពិពាហ៍ និងមានច្រើនដំណាក់កាលទាំងកូនស្រី និងកូនប្រុស។ កាលដើមឡើយ កូនប្រុសដែលត្រូវរៀបការជាមួយខាងស្រីនោះ ត្រូវទៅនៅផ្ទះខាងកូនស្រី ដើម្បីបម្រើក្រុមគ្រួសារខាងស្រីក្នុងរយៈពេលជាច្រើនខែ ច្រើនថ្ងៃ ដូចជា ពុះអុស បុកស្រូវ រែកទឹក ធ្វើស្រែ ចម្ការ ជំនួញ ជួញដូរទៅតាមផ្ទះកូនស្រីនោះថាតើមានអ្វីឱ្យកូនប្រុសបម្រើខ្លះ ក្នុងគោលបំណងឱ្យក្រុមគ្រួសារខាងស្រី ក៏ដូចជាឪពុកម្តាយខាងស្រីបានសង្កេតពីអត្តចរិត និងកិរិយាមារយាទរបស់កូនប្រសាររបស់ខ្លួន។ ហើយចំពោះការដែលកូនប្រុសទៅនៅ និងបម្រើគ្រួសារខាងស្រីនេះ កូនប្រុសនោះមិនទទួលបានលុយកាក់អ្វីនោះឡើយ ពោលគឺ

[4] ដកស្រង់ចេញពីគេហទំព័រ https://kroukhen.wordpress.com/wp-content/uploads/2009/12/story-kh.pdf។

ទទួលបានត្រឹមតែការទទួលទានបាយទឹកធម្មតា ហើយប្រសិនបើការប្រព្រឹត្តរបស់កូនប្រុសនោះធ្វើឱ្យគ្រួសារខាងស្រីមិនពេញចិត្តដោយប្រការណាមួយដែលយល់ថាមិនសមគួរ គ្រួសារខាងស្រីអាចផ្តាច់ពាក្យវិញបាន។[៥]

ជាការពិតណាស់ អាពាហ៍ពិពាហ៍របស់ជនជាតិខ្មែរ គឺមានលក្ខណៈច្រើនដំណាក់កាលខុសប្លែកពីការរៀបអាពាហ៍ពិពាហ៍ជាតិសាសន៍ដទៃ។ មុននឹងឈានទៅដល់ការរៀបមង្គលការកូនប្រុសស្រី លោកមេបាចាស់ទុំត្រូវអនុវត្តជាច្រើនទៀតដូចជា៖

➢ **ការចូលថែចូវ**

ចំពោះប្រជាជនកម្ពុជា មិនថានៅសម័យកាលណាក៏ដោយ មុននឹងឈានដល់ពិធីរៀបអាពាហ៍ពិពាហ៍ខ្មែរយើងមានទម្លាប់មួយគឺ ស៊ើបសួរពីប្រវត្តិគ្រួសារខាងនារី ឬខាងបុរសជាមុនសិន។ ក្រោយពីឪពុកម្តាយ ឬខាងកូនប្រុសបានគាប់ចិត្តនឹងកូនស្រីនរណាម្នាក់ហើយ ឪពុកម្តាយខាងកូនប្រុស និងសាមីខ្លួនផ្ទាល់បានពិភាក្សាគ្នាដើម្បីរកថ្ងៃទំនេរចូលទៅសួរសុខទុក្ខភាគីខាងកូនស្រីពីនេះពីនោះ។ គ្រួសារខាងប្រុសនឹងពឹងពាក់អ្នកដែលមានមុខមាត់ មានគេគោរពច្រើនក្នុងភូមិ (អ្នកផ្លូវ) ដើម្បីចូលស៊ើបសួរពីគ្រួសារខាងកូនស្រីថាកូនស្រីរបស់ពួកគាត់នៅទំនេរ ឬក៏មានគូរគាប់រួចទៅហើយ។ ដំណាក់កាលនេះ ហៅថា «ពិធីចូលថែចូវ» ដែលជាប្រពៃណីទំនៀមទម្លាប់ខ្មែរតាំងពីបរមបុរាណមក និងធ្វើឡើងជាបីដំណាក់កាលគឺ៖

- ដំណាក់កាលដំបូង៖ គ្រួសារខាងកូនប្រុសពឹងពាក់អ្នកផ្លូវឱ្យទៅសួរសុខទុក្ខគ្រួសារខាងកូនស្រី
- ដំណាក់កាលទីពីរ៖ គឺចូលទៅដើម្បីស្ទង់មតិថាឪពុកម្តាយខាងកូនស្រីផ្តល់ឱកាសឱ្យកូនប្រុសរបស់គាត់ដែរឬទេ? ប្រសិនបើការស្ទង់មតិនេះឃើញថាលទ្ធផលគ្រួសារខាងស្រីមិនយល់ទាស់អ្វីទេ នោះអ្នកផ្លូវ និងគ្រួសារខាងកូនប្រុសទៅម្តងទៀត
- ដំណាក់កាលចុងក្រោយ៖ អ្នកផ្លូវ និងគ្រួសារខាងប្រុសទៅម្តងទៀតដោយភ្ជាប់ជាមួយផ្លែឈើ បារី ម្លូ ស្លា ជាដើមដាក់លើជើងពាន ជូនមេបាខាងកូនខាងស្រី។

➢ **ការស្តីដណ្តឹង**

នៅពេលចូលស្តីដណ្តឹង មាតាបិតាខាងប្រុសរកអ្នកមុខអ្នកការ មានហោរបីនាក់ ឱ្យធ្វើជាអ្នកផ្លូវចូលទៅស្តីដណ្តឹងកូនស្រី ដោយមានរបស់កំដរដៃដូចជាការចូលថែចូវដែរ ដែលមានម្លូ ស្លា បារី ស្លាបផ្កា កំបោរ កាន់មកជាប់ដៃជាមួយផង។ ចំពោះការស្តីដណ្តឹងក៏មាន ៣ ដំណាក់កាលដូចគ្នាទៅនឹងការថែចូវដែរ ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្ននេះ គឺគេធ្វើតែមួយដំណាក់កាលជាការស្រេច។ ដំណាក់កាលស្តីដណ្តឹងនៅសម័យបុរាណរួមមាន៖

[៥] តន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រទី ១៥, ឆ្នាំ២០២១, ភ្នំពេញ។

- **លើកទីមួយ៖** អ្នកផ្លូវត្រូវជម្រាបទៅមេបាជាពាក្យយ៉ាងនេះថា « សូមទាន សូមជម្រាបអស់លោកមេបាតូចធំ ត្រកូលរៀមច្បង សូមទានជ្រាប ត្បិតពឹងពររកយើងខ្ញុំទាំងបីនាក់ឱ្យធ្វើជាអ្នកផ្លូវ នាំភស្តុភារបណ្ណាការមកជូនលោកមេបា សុំស្គាល់ សុំស្រឡាញ់ជាសម្ព័ន្ធមិត្តនឹងលោកមេបា ឈ្មោះនាង (ក) នៅទំនេរឥតមានទាក់ទងសម្ដីនឹងអ្នកណាទេ ឬដូចម្ដេច? » ពេលនោះលោកមេបាខាងស្រីនឹងឆ្លើយតបមកវិញថា ព្រម ឬ មិនព្រម។[៦]
- **លើកទីពីរ៖** អ្នកផ្លូវចូលទៅដូចមុនហើយនិយាយថា « ត្បិតដើងមុន យើងខ្ញុំសុំឱ្យលោកមេបាដោះពាក្យដែលជំពាក់នោះ ឥឡូវនេះលោកបានដោះរួចហើយរួចហើយ ឬនៅ? » ចំណែកមេបានឹងឆ្លើយតបទៅនឹងអ្វីដែលគេបានសន្យាពីមុនមកនោះ។[៧]
- **លើកទីបី៖** « អ្នកផ្លូវសុំស្ដីដណ្ដឹងម្ដងទៀត តែមេបាតូច (មេបាស្រី) ឆ្លើយថាស្រេចលើមេបាធំ(មេបាប្រុស) »។[៨]

ប៉ុន្តែបច្ចុប្បន្ន ពិធីមួយចំនួនក៏ត្រូវបានកាត់ចោលផងដែរ ដោយសារតែចំណាយពេលវេលាយូរ ចំណែកឯការចំណាយថវិការក៏ច្រើនផងដែរ។ ចំពោះពិធីចូលចែចូវ និងស្ដីដណ្ដឹងក៏ត្រូវបានកាត់ចេញនូវពិធីមួយចំនួនផងដែរ ដែលបច្ចុប្បន្ននេះការចូលចែចូវ គឺមានតែមួយលើកប៉ុណ្ណោះទេ ហើយកជាការតែម្ដង។ ចំពោះការស្ដីដណ្ដឹងវិញក៏ដូចគ្នាដែរ ឱ្យតែកូនប្រុសស្រីបានព្រមព្រៀងគ្នាហើយ មានការព្រមព្រៀងពីឪពុកម្ដាយទាំងសងខាងនោះគឺអាចប្រារព្ធពិធីបានដូចគ្នា ដែលភាគច្រើនគេធ្វើតែមួយលើកជាការស្រេច។ ម៉្យាងវិញទៀត វាចំណេញពេល និងថវិការសម្រាប់គ្រួសារទាំងពីរផងដែរ។

- **ពិធីស៊ីស្លា ឬពិធីភ្ជាប់ពាក្យ**

តាមប្រពៃណីខ្មែរ ពិធីនេះរៀបចំឡើងដើម្បីជាចំណងអនុស្សាវរីយ៍ និងជាការសន្យាមួយថានឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃខាងមុខ សម្រាប់អនាគតស្វាមីភរិយានេះ។ ហើយការរៀបចំនេះគឺធ្វើឡើងតាមជម្រើសជាក់ស្ដែងរបស់គូភាគី ដោយច្បាប់បានទទួលស្គាល់ផងដែរ។ ហើយការដែលរៀបចំពិធីនេះគឺអាស្រ័យទៅតាមសេដ្ឋកិច្ច និងស្ថានភាពគ្រួសាររបស់បុត្រធីតា ដែលគ្រួសារខ្លះមានជីវភាពធូរធារក៏បានរៀបចំពិធីនេះយ៉ាងអធិកអធមដូចទៅនឹងពិធីរៀបអាពាហ៍ពិពាហ៍ផងដែរ ប៉ុន្តែគ្រួសារខ្លះមានជីវភាពមធ្យម ក៏បានរៀបចំពិធីត្រឹមកម្រិតសមល្មម និងគ្រួសារខ្លះទៀតមានជីវភាពមិនសូវធូរធារ ក៏មិនធ្វើពិធីនេះសោះតែម្ដងក៏មាន

[៦] ងឹម ហ្សូរ, អរិយធម៌ខ្មែរ, ទំព័រទី ១៩៧, ឆ្នាំ២០១៤។

[៧] ងឹម ហ្សូរ, អរិយធម៌ខ្មែរ, ទំព័រ២០០, ឆ្នាំ២០១៤។

[៨] ងឹម ហ្សូរ, អរិយធម៌ខ្មែរ, ទំព័រ២០១, ឆ្នាំ២០១៤។

ដោយគ្រាន់តែមានចាស់ទុំដឹងឮប៉ុណ្ណោះ។ ចំពោះពិធីនេះគេនិយមប្រព្រឹត្តទៅពេញមួយថ្ងៃ ឬមួយព្រឹកដោយខាងបុរសលើកជំនូនទៅខាងគេហដ្ឋាននារី ព្រមទាំងមានលោកមេបាចាស់ទុំទាំងសងខាង ញាតិមិត្ត អ្នកផ្លូវចៅមហា អាជ្ញាធរ និងភ្ញៀវកិត្តិយសចូលរួមជាសាក្សីជួយដឹងជួយឮផងដែរ។ ដោយក្នុងនោះមានការបង្គាប់ថ្លៃបណ្ណាការ (ថ្លៃទឹកដោះទាំងអស់ ពាក់កណ្ដាល ឬមិនទាន់បង្គាប់) តែក៏ត្រូវមានការបំពាក់ចិញ្ចៀន ខ្សែកខ្សែដៃ ឬគ្រឿងអលង្ការផ្សេងៗប្រគល់ជូនទៅគូរអនាគតស្វាមី និងភរិយានេះ និងផ្សេងៗទៀតជាវត្ថុអនុស្សាវរីយ៍ទៅតាមការនិយម និងតាមលទ្ធភាពរបស់ពួកគេ។ ក្រោយពេលពិធីនេះបានបញ្ចប់ទៅ គេនិយមហៅអនាគតស្វាមីភរិយានេះថាជា «**គូដណ្ដឹង**»។ ប្រការសំខាន់ក្នុងដំណាក់កាលនៃកំជាប់ពាក្យនេះគឺ ពាក្យសន្យារបស់កូនប្រុសនិងកូនស្រីដែលសន្យានឹងគ្នាដោយស្ម័គ្រចិត្តថានឹងយល់ព្រមរៀបអាពាហ៍ពិពាហ៍នឹងគ្នានៅថ្ងៃអនាគត។ ក្រោយពីពិធីស៊ីស្លា ឬភ្ជាប់ពាក្យ ឬកំជាប់ពាក្យ ត្រូវបានរៀបចំឡើងរួចរាល់ទៅតាមប្រពៃណីហើយ ពិធីអាពាហ៍ពិពាហ៍កូនប្រុសស្រីក៏ចូលមកដល់។

- ❖ ត្រង់ចំណុចកំជាប់ពាក្យ ឬភ្ជាប់ពាក្យ ឬពិធីស៊ីស្លា ដែលច្បាប់បានកំណត់តម្រូវ យើងខ្ញុំនឹងលើកយកមកសិក្សានៅត្រង់ **ជំពូកទី២ របបគតិយុត្តិនៃអាពាហ៍ពិពាហ៍**។

➢ **ពិធីរៀបអាពាហ៍ពិពាហ៍**

កាលពីដើមឡើយ អាពាហ៍ពិពាហ៍ខ្មែរត្រូវបានគេប្រារព្ធឡើងក្នុងរយៈពេល ៧យប់ និង ៧ថ្ងៃ ចំណែកឯពិធីរៀបអាពាហ៍ពិពាហ៍ក្នុងសម័យព្រះពុទ្ធ គឺអាពាហ៍ពិពាហ៍របស់នាងវិសាខា មានរយៈពេលដល់ទៅ ៣ខែ។ លុះចំណេរកាលតៗមកទៀត ពិធីរៀបអាពាហ៍ពិពាហ៍នៅសល់ត្រឹមតែ ០៣ (បី) យប់ និង ០៣ (បី) ថ្ងៃ[៩] លុះមកដល់បច្ចុប្បន្នគឺនៅសល់ត្រឹមតែ ០២ (ពីរ) យប់ និង ៣ (បី) ថ្ងៃតែប៉ុណ្ណោះ។ ចំណែកក្នុងគ្រួសារខ្លះ បន្ថយនៅសល់ត្រឹមតែ ១យប់ និង១ថ្ងៃ ហើយគ្រួសារខ្លះទៀត គឺនៅសល់តែ ០១ (មួយ) ថ្ងៃ ឬ០១ (មួយ) ព្រឹកតែប៉ុណ្ណោះ។ ចំពោះដំណាក់កាលនៃការរៀបអាពាហ៍ពិពាហ៍ពីបុរាណ ហើយដែលបច្ចុប្បន្នកាត់មកនៅត្រឹម២ថ្ងៃតាមកម្មវិធីមានដូចជា៖[១០]

- ថ្ងៃទី១៖ ថ្ងៃចូលរោង គឺជាថ្ងៃដែលគេដំឡើងរោងនៅផ្ទះខាងស្រី ជាថ្ងៃដែលខាងស្រីត្រូវរៀបចំសែនក្រុងពាលីដើម្បីសុំសេចក្ដីសុខក្នុងថ្ងៃមង្គលការ ហើយតង្វាយត្រូវរៀបលក្ខណៈជាគូរៗ និងមានពិធីសូត្រមន្តនាពេលរសៀល ដើម្បីចម្រើនព្រះបរិត្ត និងបណ្ដេញពួកផ្លូវងងឹតក្នុងពិធីមង្គលផងដែរ។

---

[៩] ឆយ យីហ៊ាង, ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ, ទំព័រទី ៣២ និង៣៣, ឆ្នាំ២០០៨។

[១០] សៀវភៅសិក្សាសង្គមថ្នាក់ទី ៩ អំពីពិធីរៀបមង្គលការ របស់ក្រសួងអប់រំ, ឆ្នាំ១៩៩៩។

- ថ្ងៃទី២៖ ជាថ្ងៃដែលគេប្រារព្ធពិធីមង្គលការ កិច្ចចាប់ផ្ដើមបើកដោយពិធីហែរជំនូន។ ពិធីហែរជំនូនគេកំណត់យកម៉ោងដង្ហែរ ៧ព្រឹក ដើម្បីហែរគ្រឿងភស្តុភាបណ្ណាការ ទៅផ្ទះខាងស្រីដែលគេកំណត់យកបណ្ណាការ ៣៦មុខ ដែលបងប្អូនខ្មែរច្រទាំ្យថាផ្លែឈើ ៣៦មុខរហូតមកដល់បច្ចុប្បន្ន។ អ្នកដែលមកចូលរួមហែរជំនូន គឺចង់ដឹងពីរបៀបរៀបរយខាងប្រុសដោយហែរជំនូនត្រូវមានលក្ខណៈហែរស្រប និងទល់មុខរោងការ ហាមការហែរបញ្ច្រាសរោងការ ពីព្រោះវាអាចធ្វើឱ្យបែកបាក់គ្នា ឬរកស៊ីតឹងតែង។ ផ្លែឈើដែលហាមក្នុងថ្ងៃហែរជំនូន គឺមានតែមួយប៉ុណ្ណោះ គឺផ្លែត្របែក ព្រោះវាតំណាងឱ្យភាពបែកបាក់។ នៅមុខក្លោងទ្វារការ គេត្រូវរៀបចំអ្នកកាន់ផ្កា ២នាក់មកកាន់ខ្សែរបិទក្លោងទ្វារដើម្បីបញ្ជាក់ពីភាពបរិសុទ្ធរបស់ខាងស្រី ហើយនៅពេលខាងប្រុសមកដល់ អ្នកកំដរដែលកាន់ឆ័ត្រ ២នាក់ និងម្នាក់ទៀតដែលទំនេរ ត្រូវយកដាវហុចទៅកូនកំលោះ ដើម្បីកាត់ខ្សែរចំណងនោះ ទើបគេឱ្យកូនក្រមុំចេញមក។ បន្ទាប់មកគឺពិធីសែនមេបា និងជំនាងផ្ទះ ដោយគេដាក់ចំណីក្នុងកន្ទោងលើកដាក់ទៅក្នុងច្រម ជាកន្លែងសម្រាប់តង្វាយជូនដល់ជំនាងផ្ទះ និងរៀបចំនូវអាហារមួយតុ ឬមួយថាសដើម្បីប្រាប់ជាដំណឹងកុំឱ្យមេបា ជីដូនជីតា ប្រកាន់ខឹង។ ពិធីស៊ីស្លា ពិធីនេះគេលើកម្លូស្លាជូនលោកមេបាចាស់ទុំទាំងសងខាងពិសា ដើម្បីពិធីកាត់សក់ ជាដំបូងអាចារ្យបួងសួងសុំរបស់ទិព្វពីទេវតាដែលមានប្រុសស្រីមួយគូចេញរាំច្រៀងជាតំណាង ហើយឧបកិច្ចកាត់សក់ក្រាសមាសកន្ត្រៃប្រាក់ កញ្ចក់ផ្ទិលទឹក។ ឪពុកម្ដាយត្រូវកាត់សក់ គឺតំណាងឱ្យការកាត់ចិត្ត និងដោះលែងសិទ្ធិឃុំគ្រងលើជីវិតកូន ទាំងខាងប្រុស និងខាងស្រី។ ពិធីរាំបើកវាំងននអញ្ជើញកូនក្រមុំ ពិធីសំពះផ្ទឹម បន្ទាប់មកពិធីអុជទៀនបង្វិលប្រាំពីរជុំ បន្ទាប់មកពិធីសែនចងដៃ រួចបញ្ចប់ដោយពិធីបាចផ្កាស្លា និងពិធីតោងស្បៃចូលក្នុងបន្ទប់។ ពិធីរៀបភោជនីអាហារជូនភ្ញៀវ គឺគេនិយមរៀបចំពិធីជប់លៀងភ្ញៀវ ពេលយប់ជាមួយនឹងការច្រៀងរាំកំសាន្ត ក្រោយបញ្ចប់ពិធីមង្គលការ ទើបគូស្វាមីភរិយាសន្មតជាថ្ងៃជ័យមង្គលក្នុងការចាប់ផ្ដើមដំណើរជីវិត។

ដូចដែលបានរៀបរាប់ខាងលើនេះ ថ្វីត្បិតតែការប្រារព្ធពិធីអាពាហ៍ពិពាហ៍ មានការកាត់បន្ថយនូវចំនួនថ្ងៃក៏ពិតមែន ប៉ុន្តែប្រជាពលរដ្ឋខ្មែរនៅតែមានការឱ្យតម្លៃយ៉ាងខ្លាំងទៅលើការប្រកាន់យកនូវប្រពៃណីទំនៀមទម្លាប់ខ្មែរ ពិសេសគឺការប្រកាន់ខ្ជាប់ឱ្យបាននូវពិធីសំខាន់ៗដែលជាការគោរព និងថែរក្សាតម្លៃប្រពៃណីខ្មែរ។

មួយវិញទៀត បើយើងក្រឡេកទៅលើតាមសម័យកាលនាសម័យបុរាណទាក់ទងនឹងការចូលស្ដីដណ្ដឹងវិញ យើងឃើញថាមានលក្ខណៈខុសប្លែកពីសម័យកាលមួយទៅសម័យកាលទៀត ដោយយើងនឹងលើកយកពីរសម័យកាលមកធ្វើការបង្ហាញគឺ៖

➢ **សម័យនគរភ្នំ**

តាមប្រវត្តិសាស្ត្រ សម័យនគរភ្នំជាសម័យដែលឱ្យតម្លៃយ៉ាងខ្លាំងទៅលើ «មេនិយម» ឬយើងអាចនិយាយបានថា ស្ត្រីជាអធិបតី ដែលមានន័យថា គេបានចាត់ទុកស្ត្រីជាធំក្នុងគ្រួសារ និងក្នុងសង្គមជាតិ។ ហេតុនេះហើយបានជាស្ត្រីជាអ្នកមានអំណាច មានសិទ្ធិក្នុងការចូលទៅស្ដីដណ្ដឹងប្រុសៗ ដោយស្ត្រីមានសិទ្ធិក្នុងការជ្រើសរើសថាតើខ្លួននឹងទៅដណ្ដឹងនរណាមកធ្វើជាស្វាមី និងមានសិទ្ធិក្នុងការជ្រើសរើសដោយខ្លួនឯង។

➢ **សម័យចេនឡា**

ក្នុងសម័យចេនឡានេះផងដែរ គេនៅតែចាត់ទុកស្ត្រីជាធំនៅក្នុងគ្រួសារដដែល ប៉ុន្តែមានការខុសប្លែកទៅលើអ្នកដែលមានសិទ្ធិក្នុងការចូលទៅស្ដីដណ្ដឹង គឺផ្លាស់ប្ដូរពីស្ត្រីដណ្ដឹងបុរស ទៅជា បុរសចូលស្ដីដណ្ដឹងស្ត្រីម្ដង។ ដោយមុនដំបូងខាងប្រុសត្រូវលើកជំនូនទៅគ្រួសារខាងស្រីដែលខ្លួនពេញចិត្ត។ បន្ទាប់មកទើបខាងស្រីត្រូវរើសថ្ងៃមង្គលដើម្បីនាំកូនស្រីទៅផ្ទះខាងប្រុសតាមរយៈមេអណ្ដើកម្នាក់ ហើយគ្រួសារទាំងសងខាងស្ថិតក្នុងផ្ទះអស់រយៈពេល ៨ថ្ងៃដោយពុំមានចេញទៅណាមកណា និងមានដុតចង្កៀងទាំងថ្ងៃទាំងយប់។ លុះមានការប្រារព្ធឡើងនូវកម្មវិធីអាពាហ៍ពិពាហ៍ចប់សព្វគ្រប់ហើយនោះ កូនប្រុសទទួលនូវមត៌កពីឪពុកម្ដាយបង្កើតរបស់ខ្លួន ហើយចែកផ្ទះទៅនៅដោយឡែកជាមួយនឹងភរិយារបស់ខ្លួនដោយពុំទទួលបានមត៌កអ្វីបន្ថែមទៀតឡើយ។

## ១.៣. បទដ្ឋានគតិយុត្តនៃអាពាហ៍ពិពាហ៍

### ១.៣.១. ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០

ចំពោះអាពាហ៍ពិពាហ៍ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីចាស់នេះ បានចែងឱ្យតម្លៃខ្ពស់ទៅលើបុរសជាធំ គឺបុរស អាចយកប្រពន្ធបានច្រើននាក់ រីឯស្ត្រី អាចយកប្ដីបានតែម្នាក់គត់។ ហើយអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានរវាងបុគ្គល ដែលមានភេទផ្សេងគ្នា ដោយបុរសត្រូវមានអាយុ ១៧ឆ្នាំ និងនារីត្រូវមានអាយុ ១៤ឆ្នាំ ទើបច្បាប់អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន។[១១] មួយវិញទៀត អំណាចរបស់ប្ដី គឺរមែងតែងតែធំជាងប្រពន្ធជានិច្ច នៅក្នុងការចាត់ចែងគ្រួសារ គឺប្រពន្ធគ្មានសិទ្ធិផ្ដល់យោបល់ឱ្យប្ដីស្ដាប់ទេ បើប្ដីមិនចង់ស្ដាប់ គឺស្រេចតែចិត្តប្ដី ប៉ុន្តែបើប្ដីឱ្យដំបូន្មានប្រពន្ធត្រូវស្ដាប់ ទោះបីដំបូន្មាននោះខុស ឬត្រូវក៏ដោយ។ មានន័យថាប្រពន្ធមុននឹងធ្វើអ្វី ត្រូវឆ្លងកាត់យោបល់ប្ដីជាមុនសិន មិនអាចធ្វើឡើងស្រេចតែចិត្តបាននោះទេ សូម្បីតែការប្ដឹងផ្ដល់ទៅតុលាការ និងចុះហត្ថលេខាលើកិច្ចសន្យាផ្សេងៗ គឺទាល់តែប្ដីអនុញ្ញាតផងដែរ។

[១១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩២០, មាត្រា១១៥ និងមាត្រា១១៦។

គួយ៉ាង នេះក៏ដោយសារតែប្រទេសកម្ពុជានាសម័យនោះប្រកាន់ខ្ជាប់របបរាជាណាចក្រ ដែលស្តេចមានអំណាចជាធំ ទើបច្បាប់ក៏ចែងតម្រូវតាមផ្នត់គំនិតរបស់ថ្នាក់ដឹកនាំ និងតម្រូវតាមស្ថានភាពជាក់ស្តែងនៃសម័យនោះផងដែរ។

ដោយឡែក ជាការលើកឡើងមួយនាចុងសម័យសាធារណៈរដ្ឋខ្មែរ (១៩៧០-១៩៧៥) ឃើញថាពេលនោះកម្លាំងទ័ពព្រៃបានហ៊ុំព័ទ្ធទីក្រុង និងទីរួមខេត្តនានា។ ហេតុនេះ ការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈប្រញាប់ប្រញាល់ណាស់។ ឯការស្តីដណ្តឹងក៏មានលក្ខណៈបែបនោះដែរ។ ការប្រកាន់ប្រពៃណីក្នុងការស្តីដណ្តឹងត្រូវបានបន្ធូរបន្ថយជាច្រើន គឺសម្រួលយ៉ាងណាដើម្បីឱ្យកូនប្រុសនឹងកូនស្រីងាយស្រួលក្នុងការរស់នៅជាមួយគ្នា។ អាពាហ៍ពិពាហ៍ខ្លះមានលក្ខណៈជារបៀបសែនព្រេន។[១២] យើងសង្កេតឃើញថា ជាទូទៅអាពាហ៍ពិពាហ៍នាសម័យនេះភាគច្រើនតែមួយព្រឹក (ព្រឹកព្រលឹមរហូតដល់ម៉ោង០៩ ឬ១០យប់) ប៉ុណ្ណោះ គឺចំណាយពេលត្រឹមម៉ោង១២ថ្ងៃត្រង់ បន្ទាប់មកជប់លៀងភោជនីហារជូនភ្ញៀវកិត្តិយសមិនបានចាត់ចូលក្នុងកិច្ចពិធីមង្គលទេ។

ហេតុនេះហើយ ទោះបីជាក្រមចាស់នេះ មានលក្ខណៈលើកតម្កើនបុរសជាងស្ត្រីក៏ដោយ ក៏ប្រជាពលរដ្ឋនាសម័យនោះនៅគោរពប្រតិបតិតាមយ៉ាងខ្ជាប់ខ្ជួន។ ដោយឡែក ការរៀបពិធីអាពាហ៍ពិពាហ៍ ឬពិធីមង្គលការនាសម័យនោះ គឺមិនសូវជាបានប្រារព្ធឱ្យត្រឹមត្រូវទៅតាមស្រទាប់ដំណាក់កាលនោះទេ ដោយសារសម័យនោះជាសម័យសង្គ្រាម ទើបប្រជាពលរដ្ឋខ្លះបានរៀបចំពិធីអាពាហ៍ពិពាហ៍នេះត្រឹមតែមួយព្រឹក រីឯប្រជាពលរដ្ឋខ្លះទៀតមិនបានរៀបចំពិធីនេះឡើងក៏មាន ហើយប្រជាពលរដ្ឋទៀតនោះ មានជីវភាពធូរធារ មានឋានៈបុណ្យសក្តិខ្ពង់ខ្ពស់ ក៏បានរៀបចំពិធីនេះឡើងដោយមិនឱ្យខ្វះចន្លោះនោះទេ។

### **១.៣.២. របបនយោបាយផ្តាច់ការ (១៩៧៥-១៩៧៩)**

នៅពេលកម្ពុជាបានធ្លាក់ចូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្បួនច្បាប់ ទម្លាប់ប្រពៃណី និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗត្រូវបានបំផ្លិចបំផ្លាញអស់គ្មានសល់ ហើយត្រូវបានគ្រប់គ្រងចាត់ចែងមកតាមរបៀបរៀបចំដោយអង្គការខ្មែរក្រហមវិញ។ ចំណែកការរៀបអាពាហ៍ពិពាហ៍នាសម័យនោះ ធ្វើឡើងដោយអង្គការជាអ្នកចាប់គូរឱ្យហើយធ្វើឡើងជាច្រើនគូរក្នុងពេលតែមួយ ដោយសាមីខ្លួនមិនទាំងស្គាល់គ្នាផង និងមិនអាចប្រកែកបានឡើយ។ ពិធីនេះភាគច្រើនធ្វើឡើងនៅពេលរសៀល និងពេលយប់ បន្ទាប់ពីធ្វើការងាររួច។ ហើយគេប្រារព្ធពិធីនេះឡើងដោយស្ងាត់ៗជារបៀបប្រជុំ ជួនកាលសាមីខ្លួនទើបដឹងភ្លាមៗថា ខ្លួននឹងត្រូវបានរៀបការ។ បន្ទាប់មកអ្នកទាំងពីរ

[១២] ឆយ យីហ៊ាង, សៀវភៅដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ, ទំព័រទី១៣០, ភ្នំពេញ ៧ មករា ២០០៨។

ត្រូវប្តេជ្ញាចិត្តពីភក្តីភាពរវាងគ្នា និងគោរពដើរតាមអង្គការ នៅចំពោះមុខអង្គការ។ ប្រសិនបើមានអ្នកជំទាស់នឹងអង្គការនោះ សាមីខ្លួននិងត្រូវបានគេយកទៅសម្លាប់ ឬយកទៅធ្វើទារុណកម្មផ្សេងៗ។

យ៉ាងណាមិញ ក្រោយពីកម្ពុជាត្រូវបានរួចផុតពីសម័យដ៏ខ្មៅងងឹតនេះមក ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ លែងមានប្រសិទ្ធិភាពទៀតហើយ។ មានន័យថា ច្បាប់ដែលគ្រប់គ្រងផ្នែករដ្ឋប្បវេណីមានចាប់ពីឆ្នាំ១៩២០ មក និងមានសុពលភាពអនុវត្តហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាការមកដល់នៃរបបកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត)។

លុះមកដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាត្រូវបានរំដោះ និងបានបង្កើតជារបបថ្មីមួយគឺ **សាធារណៈរដ្ឋប្រជាមានិតកម្ពុជា** ដែលជាប្រទេសមានរបបនយោបាយ សង្គមនិយម សេដ្ឋកិច្ចផែនការ។ ហើយនៅសម័យនោះ ប្រទេសកម្ពុជាពុំបានបន្តអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ឡើយ ដោយហេតុថា មានរបបនយោបាយ និងសេដ្ឋកិច្ចខុសគ្នា។

### ១.៣.៣. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

នៅឆ្នាំ១៩៨៩ ប្រទេសកម្ពុជាបានផ្លាស់ប្តូររបបនយោបាយទៅជារដ្ឋកម្ពុជា។ សម័យកាលនេះ ជាសម័យកាលអន្តរកាលមួយដែលប្រទេសកម្ពុជាបានចាកចេញពីរបបសង្គមនិយម ដោយមូលហេតុនៃការដួលរលំរបបសង្គមនិយមរបស់អតីតសហភាពសូវៀត។ ដូចនេះហើយ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៩ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ នាសម័យប្រជុំសាមញ្ញលើកទី១៧ នីតិកាលទី១ និងប្រកាសឱ្យប្រើនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩។ ច្បាប់នេះមានអានុភាពហូតត្រូវបានជំនួសដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដាក់ឱ្យអនុវត្តនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ច្បាប់នេះបាននិរាករណ៍ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ដោយរក្សាអនុវត្តមាត្រា៧៦ មាត្រា៧៧ និងបញ្ញត្តិពីមាត្រា៧៩ ដល់មាត្រា៨១ នៃច្បាប់នេះ ដែលចែងអំពីសិទ្ធិរបស់សហព័ទ្ធក្នុងការទាមទារអាហារកាត្ចកិច្ច នៅពេលសុំលែងលះរហូតដល់ពេលកំណត់ផ្សេងដោយច្បាប់។[១៣]

ម្យ៉ាងវិញទៀត ចាប់តាំងពីមានច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ នេះមក អាពាហ៍ពិពាហ៍នាសម័យនេះត្រូវបានគោរពទៅតាមច្បាប់ថ្មី អ្វីៗត្រូវបានផ្លាស់ប្តូរនីតិវិធីច្បាប់ បុរសដែលធ្លាប់តែក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ អនុញ្ញាតឱ្យមានប្រពន្ធច្រើនត្រូវបានកាត់ផ្តាច់ទៅជា អាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ នេះត្រូវបានចែងយ៉ាងច្បាស់នៅក្នុង ច្បាប់ស្តីពីពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា៣។

[១៣] ប៊ូយ ធីតា, សៀវភៅនីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០២៤, ទំព័រទី ២០៦។

### ១.៣.៤. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់អំពីគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គលគ្រប់រូប ភាពស្មើគ្នារបស់បុរស នារី ទៅលើសិទ្ធិលើទ្រព្យសម្បត្តិ និងសិទ្ធិសេរីភាពផ្សេងៗដូចជា មាត្រា៦ នៃក្រមនេះចែង អំពីគោលការណ៍សមភាពនៃសមត្ថិភាពទទួលសិទ្ធិដោយមិនបែងចែងរវាងបុរសនារីឡើយ។ ចំពោះល័ក្ខខ័ណ្ឌ នៃអាពាហ៍ពិពាហ៍ទាក់ទងនឹងអាយុ គឺបុរស និងនារីដល់នីតិភាព ១៨ឆ្នាំដូចគ្នា[១៤] បើប្រៀបធៀបនឹងច្បាប់ អាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ មាត្រា៥ បានចែងកំណត់ បុរសអាយុ២០ឆ្នាំ និងនារីមានអាយុ១៨ឆ្នាំ។ ចំណែកឯក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ មាត្រា១១៦ វិញ អាយុដែលច្បាប់អនុញ្ញាតឱ្យរៀបការ គឺបុរស១៧ឆ្នាំ និងនារី១៨ឆ្នាំ។[១៥]

ជាការពិតណាស់ចាប់តាំងពី ឆ្នាំ១៩៧៩ រហូតមកដល់សព្វថ្ងៃនេះ អាពាហ៍ពិពាហ៍ខ្មែរមានលក្ខណៈ ចម្រុះពណ៌ ដោយសារតែការឆ្លងកាត់នូវសង្គ្រាមជាច្រើនសម័យកាល ទើបធ្វើឱ្យពិធីមួយចំនួនក្នុងការរៀប អាពាហ៍ពិពាហ៍កំពុងឈានទៅរកការបាត់បង់។ ជាក់ស្ដែងចាប់តាំងពីកម្ពុជារួចផុតពីភ្លើងសង្គ្រាមមក ប្រជា ពលរដ្ឋខ្មែរមួយចំនួនក៏ចាប់ផ្ដើមទទួលយកនូវវប្បធម៌បរទេសដែលមកពីខាងក្រៅ មកជំនួសនូវអ្វីដែលនៅខាង ក្នុង មានន័យថា យើងកំពុងធ្វើឱ្យអាពាហ៍ពិពាហ៍ឃ្លាតឆ្ងាយពីទម្រង់នឹងខ្លឹមសារដើមរបស់ដូនតា។ យើងអាច សង្កេតឃើញថាក្នុងកម្មវិធីរៀបមង្គលការ ប្រជាពលរដ្ឋខ្មែរមួយចំនួន មានបន្ថែមនៅការសែនព្រេនដូនតាចិន និង សរសេរអក្សរចិននៅលើតុសែនដូនតាខ្មែរទៅវិញ។ ជាក់ស្ដែងបច្ចុប្បន្នការរៀបមង្គលការនេះភាគច្រើននៅតែ ប្រព្រឹត្តទៅដដែល គ្រាន់តែមង្គលការខ្លះកាត់បន្ថយ នៅដំណាក់កាលមួយចំនួនដូចជា មុនរៀបអាពាហ៍ពិពាហ៍ គ្រួសារទាំងសងខាងមិនបានបង្កើតឱ្យមានកំជាប់ពាក្យ ឬពិធីស៊ីស្លានឹងគ្នាទេ គឺពួកគាត់ទុកឱកាសនោះធ្វើជា ពិធីរៀបមង្គលការឱ្យកូនប្រុសស្រីខ្លួនវិញ ខ្លះទៀតបានរៀបអាពាហ៍ពិពាហ៍គ្រប់ចំនួនតាមក្បួនតម្រា រីឯខ្លះទៀត ក៏រៀបពិធីនេះបានតែមួយព្រឹកតែប៉ុណ្ណោះ ដែលពិធីនេះគេនិយមហៅថា «ពិធីសែនព្រេន» ហើយខ្លះទៀត មិន បានរៀបពិធីអាពាហ៍ពិពាហ៍នេះឡើងទេ គឺពួកគេរស់នៅជាមួយគ្នាតាមរបៀបរបបបរទេស ក្នុងន័យច្បាប់ហៅថា «អនីតិសង្វាស» គឺជាការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ ប៉ុន្តែមិនត្រឹមត្រូវទៅតាមលក្ខណៈច្បាប់។

យ៉ាងណាមិញ នៅមុនពេលដែលមានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏មានច្បាប់មួយទៀតដែលនៅជា ធរមាន រហូតទាល់តែមានច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ចូលមកទើប ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ នោះត្រូវបាននិរាករណ៍នៅសល់តែប្បញ្ញាត្តិមួយចំនួន។ ជាក់ស្ដែងក្រមរដ្ឋប្បវេណីចាប់តាំង

[១៤] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៤៨។

[១៥] ប៊ួយ ធីតា, សៀវភៅនីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០២៤, ទំព័រទី ២។

ពី គន្ថីទី៧ ជំពូកទី២ (កំជាប់ពាក្យ) ដល់ ជំពូកទី៣(អាពាហ៍ពិពាហ៍) រហូតដល់ផ្នែកទី៣ (ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ) គឺក្រមនេះបានចែងយ៉ាងលម្អិតលម្អន់មិនឱ្យលំអៀងទៅខាងភាគីណាម្ខាងនោះឡើយ ចាប់តាំងពីនីតិវិធីមុនរៀបអាពាហ៍ពិពាហ៍ នីតិវិធីអំឡុងពេលរៀបអាពាហ៍ពិពាហ៍ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍ រហូតដល់នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរបស់គូរស្វាមីភរិយានេះ។

- ត្រង់ចំណុចអាពាហ៍ពិពាហ៍ ដែលច្បាប់បានកំណត់នេះតម្រូវ យើងខ្ញុំនឹងលើកយកមកសិក្សានៅត្រង់ **ជំពូកទី២ របបគតិយុត្តិនៃអាពាហ៍ពិពាហ៍។**
- រីឯត្រង់ចំណុច ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ និងមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍ នាងខ្ញុំទាំងពីរនាក់នឹងលើកយកមកសិក្សានៅក្នុង **ជំពូកទី៣ អានុភាពនៃអាពាហ៍ពិពាហ៍។**

# ជំពូកទី២

# នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍

# ជំពូកទី២ របបគតិយុត្តិនៃអាពាហ៍ពិពាហ៍

ក្រៅពីប្រទេសកម្ពុជាមាននូវវប្បធម៌ប្រពៃណី ដ៏ឧត្តុងឧត្តមក្នុងទំនៀមទម្លាប់នៃការរៀបអាពាហ៍ពិពាហ៍ ហើយនោះ ប្រជាជនកម្ពុជាក៏បានប្រកាន់ខ្ជាប់នូវគ្រប់ដំណាក់កាលនៃការរៀបអាពាហ៍ពិពាហ៍នេះចាប់តាំងពីមុន ពេលមានពិធីអាពាហ៍ពិពាហ៍ អំឡុងពេលរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលរៀបអាពាហ៍ពិពាហ៍ជាអាទ៍។ សម្រាប់ការអនុវត្តទៅលើវិធាននៃការរៀបអាពាហ៍ពិពាហ៍នេះផងដែរ គឺមានការចែងខុសៗគ្នាទៅតាមប្រពៃណី ទំនៀមទម្លាប់នៃប្រទេសនីមួយៗ ប៉ុន្តែគោលបំណងសំខាន់ និងចម្បងនៃការចែងបញ្ញត្តិពីកាតព្វកិច្ចទាំងអស់ នេះគឺ ដើម្បីអនុញ្ញាតឱ្យបុគ្គលមួយចំនួនអាចរៀបអាពាហ៍ពិពាហ៍បាន និងមួយចំនួនទៀតដែលច្បាប់ត្រូវហាម ឃាត់មិនតម្រូវឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ។ ទោះជាយ៉ាងណាក្តី ក៏ទំនាក់ទំនងគតិយុត្តិមុនរៀប អាពាហ៍ពិពាហ៍នេះ ដូចជាកំជាប់ពាក្យ ឬពិធីភ្ជាប់ពាក្យ គឺមិនមែនជាកាតព្វកិច្ចដែលប្រជាពលរដ្ឋខ្មែរត្រូវតែបំពេញ ជាដាច់ខាតទេ ព្រោះគ្រួសារមួយចំនួនពុំចង់ខាតពេលវេលានឹងមានពិធីធំដុំដែលត្រូវចំណាយប្រាក់កាសច្រើន។ ហេតុនេះ ដំណាក់កាលមុនរៀបអាពាហ៍ពិពាហ៍នេះក្រៅពីកំជាប់ពាក្យ ក៏មានលក្ខខណ្ឌច្បាប់នូវតែតម្រូវឱ្យភាគី ត្រូវគោរពតាមជាដាច់ខាត មុនចូលដល់ពិធីរៀបអាពាហ៍ពិពាហ៍។

## ២.១. ទំនាក់ទំនងគតិយុត្តមុនរៀបអាពាហ៍ពិពាហ៍

### ២.១.១. លក្ខខណ្ឌនៃកំជាប់ពាក្យតាមផ្លូវច្បាប់ (មិនមែនជាកាតព្វកិច្ច)

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ កំជាប់ពាក្យ គឺជាសេចក្តីសន្យាដែលជនពីរនាក់បានប្តេជ្ញាថានឹងយក គ្នាជាប្តីប្រពន្ធតាមច្បាប់។ កំជាប់ពាក្យនេះនឹងទុកជាបានការលុះតែការនេះបានធ្វើពិធីជា ឱឡារិកមួយដែលហៅ ថា «ពិធីលើកស្លា ឬពិធីស៊ីស្លា» ។ចំណែកនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ វិញ គឺមិន បានចែងកំណត់ពីពិធីនេះទេ។

ចំណែកនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងអំពីពិធីនេះឡើង ដោយសាមីខ្លួនខាងបុរស និង ខាងនារីបានសន្យាជាផ្លូវការថានឹងព្រមរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាថ្ងៃអនាគត និងដោយធ្វើពិធីកំជាប់ ពាក្យ។[១៦] ជាងនេះទៅទៀត ក្រមនេះពុំបានកំណត់អំពីលក្ខខណ្ឌផ្សេងៗនៅក្នុងការធ្វើកំជាប់ពាក្យទេដូចជា អាយុរបស់ភាគី ស្ថានភាពផ្លូវកាយ ផ្លូវចិត្ត បញ្ហាសុខភាព។ល។

[១៦] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៨៤។

### ២.១.២. ការរំលាយកំជាប់ពាក្យ

ដើម្បីកំណត់ថា កំជាប់ពាក្យនេះប្រព្រឹត្តទៅបានយ៉ាងស្របច្បាប់ ទាល់តែភាគីនោះជាបុរស និងនារី ធ្វើឱ្យមានពិធីកំជាប់ពាក្យកើតឡើង។ ពិតណាស់ ពិធីកំជាប់ពាក្យ ឬពិធីលើកស្លាត្រូវបានច្បាប់ទទួលស្គាល់ពិតមែន ប៉ុន្តែបើភាគីនៅតែមានចំណងស្នេហានឹងគ្នាដោយគ្មានឧបសគ្គមករារាំងខកដំណើរ នោះអាពាហ៍ពិពាហ៍នាថ្ងៃអនាគតរបស់គូរភាគីនឹងកើតមាន។ ប៉ុន្តែប្រសិនបើភាគីកំជាប់ពាក្យនេះមិនចុះសម្រុងគ្នា ឬមិនត្រូវគ្នា និងត្រូវបានរំលាយដោយមូលហេតុណាមួយ នោះអាពាហ៍ពិពាហ៍ក៏មិនអាចកើតមានឡើងផងដែរ។

#### ២.១.២.១ ការរំលាយកំជាប់ពាក្យដោយមូលហេតុត្រឹមត្រូវ

ប្រសិនបើកំជាប់ពាក្យត្រូវបានផ្តាច់ដោយភាគីណាមួយដោយគ្មានមូលហេតុត្រឹមត្រូវ និងនាំឱ្យប៉ះពាល់ដល់កិត្តិយស ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យ គឺអាចទាមទារឱ្យសងជំនូនវិញបាន៖[១៧]

- បើកំជាប់ពាក្យត្រូវបានផ្តាច់ដោយសារសាមីខ្លួនបានស្លាប់ សំណងជំងឺចិត្តមិនត្រូវបានសងឡើយ ប៉ុន្តែអ្នកដែលនៅរស់នឹងអាចទាមទារជំនូនមកវិញបាន។[១៨]
- ទោះបីជាកំជាប់ពាក្យត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរបស់គូរភាគីហើយក៏ដោយ ប៉ុន្តែក៏មានករណីមួយចំនួនកំជាប់ពាក្យត្រូវបានរលាយទៅវិញ ដោយការព្រមព្រៀងរបស់គូភាគីខ្លួនឯងផងដែរ។ ក្នុងករណីនេះ យើងអាចនិយាយបានថា ភាគីខាងបុរសយល់ថាខ្លួនមិនអាចរួមរស់នៅជាមួយនារី និងមិនអាចទទួលយកនូវអត្តចរិតរបស់ភាគីខាងនារីបាន។ ចំណែកឯភាគីខាងនារីក៏មិនទុកចិត្ត និងគិតថាខ្លួនមិនអាចរួមរស់នៅជាមួយបុរសនោះទៅអនាគតបាន។ ហេតុនេះភាគីទាំងសងខាងអាចព្រមព្រៀងគ្នាក្នុងការរំលាយកំជាប់ពាក្យនេះបាន។

- ពាក្យថា «**ជំនូន**» គឺសំដៅទៅលើប្រទានកម្ម (អំណោយ) ដែលភាគីម្ខាងបានជូនទៅភាគីម្ខាងទៀតដោយសារតែកំជាប់ពាក្យ។ **ឧទាហរណ៍**៖ ចិញ្ចៀនភ្ជាប់ពាក្យ ខ្សែក ក្រវិល ឬ ខ្សែដៃជាដើម។ ចំណែកឯប្រាក់ដែលភាគីម្ខាងបានផ្តល់ឱ្យភាគីម្ខាងទៀត ដើម្បីរៀបចំពិធីកំជាប់ពាក្យ គឺមិនគួរចាត់ទុកថាជាជំនូននោះទេ ព្រោះថាប្រាក់ទាំងនេះត្រូវយកមកធ្វើការចាត់ចែងធ្វើពិធីកំជាប់ពាក្យដើម្បីជាប្រយោជន៍ដល់ភាគីទាំងសងខាងអស់ទៅហើយ។
- គួរធ្វើការកត់សម្គាល់ថា ភាគីដែលបានទទួលជំនូន គឺត្រូវតែសងជំនូននេះទៅភាគីម្ខាងទៀតវិញ។ ដូច្នេះបើភាគីទាំងសងខាងបានទទួលជំនូនពីគ្នាទៅវិញទៅមក គឺត្រូវសងជំនូននេះឱ្យគ្នាទៅវិញទៅមក

---

[១៧] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤៥។

[១៨] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០, មាត្រា ១១២។

ដូចគ្នាដែរ។[19] **ឧទាហរណ៍៖** បុរស **ក** និងនារី **ខ** បានរៀបចំកំជាប់ពាក្យជាមួយគ្នាតាមប្រពៃណីដូនតា។ បីខែក្រោយមក នារី **ខ** បានដឹងពីទំនាក់ទំនងស្នេហារវាង បុរស **ក** និង នារី **គ** ហើយក៏សម្រេចចិត្តផ្ដាច់កំជាប់ពាក្យវិញ។ ដូច្នេះ ការរំលាយកំជាប់ពាក្យមានមូលហេតុត្រឹមត្រូវ។ ហេតុនេះ បុរស **ក** អាចទាមទារឱ្យ នារី **ខ** សងជំនូនមកខ្លួនវិញតែប៉ុណ្ណោះ ដោយមិនអាចទាមទារឱ្យ នារី **ខ** សងសំណងជម្ងឺចិត្តណាមួយ ព្រោះថាការទាមទារឱ្យរំលាយកំជាប់ពាក្យនេះទេ ពីព្រោះតែខាងបុរសបានក្បត់ពាក្យសន្យាទៅមានស្នេហាជាមួយនារីម្នាក់ផ្សេងទៀត។

### ២.១.២.២ ការរំលាយកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ

ក្នុងករណីដែលភាគីណាម្ខាងបានធ្វើការបដិសេធកំជាប់ពាក្យចោលដោយមូលហេតុមិនត្រឹមត្រូវ ឬមិនសមស្របភាគីម្ខាងទៀតអាចទាមទារសំណង់នៃការខូចខាតបាន[20] ដូចជា៖

- សំណងនៃការខូចខាតនេះអាចរួមមានសំណងជម្ងឺចិត្តសមរម្យតាមថ្លៃជំនូន និងភស្តុភារ បណ្ដាការដែលភាគីមិនមានកំហុសក្នុងការរៀបចំពិធីកំជាប់ពាក្យនោះ។
- ភាគីដែលត្រូវបានគេផ្ដាច់កំជាប់ពាក្យដោយគ្មានកំហុស អាចប្ដឹងទៅតុលាការដើម្បីទាមទារឱ្យសងជំនូនមកវិញ និងសំណងការខូចខាតក្នុងរយៈពេល ០១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃកំជាប់ពាក្យត្រូវបានរលាយ ហើយក្នុងករណីនៃអំឡុងពេលនោះ ភាគីមិនបានដាក់ពាក្យបណ្ដឹង នោះភាគីដែលមានសិទ្ធិប្ដឹងនោះ ត្រូវរលត់សិទ្ធិប្ដឹងទាមទារជំនូន ឬសំណងជំងឺចិត្តនេះ។[21] **ឧទាហរណ៍ទី១៖** បុរស **ក** និង នារី **ខ** បានព្រមព្រៀងភ្ជាប់ពាក្យជាមួយគ្នាដោយបានធ្វើពិធីកំជាប់ពាក្យតាមប្រពៃណី។ ក្រោយមក បុរស **ក** ក៏អស់ចិត្តស្រលាញ់ នារី **ខ** ដោយមូលហេតុ បុរស **ក** បានស្រលាញ់នារី **គ** ហើយបានផ្ដាច់កំជាប់ពាក្យជាមួយនារី **ខ** វិញ។ ដូច្នេះ នារី ខ អាចទាមទារឱ្យ បុរស **ក** សងនូវជំនូនដែលបានទទួលនៅក្នុងពេលភ្ជាប់ពាក្យដូចជា ចិញ្ចៀន ជាដើម។ នារី **ខ** ក៏អាចទាមទារសំណងថ្លៃចំណាយផ្សេងៗក្នុងការរៀបចំពិធីកំជាប់ពាក្យ រួមទាំងការបាត់បង់កិត្តិយសជាដើម។ ពីព្រោះការរំលាយកំជាប់ពាក្យបែបនេះ គឺជាការរំលាយកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ ហើយបណ្ដឹងទាមទារឱ្យសងសំណងខាងលើត្រូវប្ដឹងក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះបានរលាយ។ **ឧទាហរណ៍ទី២៖** បុរស **ក** និងនារី **ខ** បានព្រមព្រៀងគ្នារៀបពិធីកំជាប់ពាក្យជាមួយគ្នា ដោយបានរៀបពិធីកំជាប់

[19] រុនពណ្ណារិទ្ធ និង ចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងគ្រួសារ, ទំព័រទី ៣១៤ , បោះពុម្ពលើកទី២, ឆ្នាំ២០២២។

[20] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤៦។

[21] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤៧។

ពាក្យនេះឡើងមក។ ប៉ុន្មានខែបន្ទាប់មក បុរស **ក** ក៏បានជាប់ចិត្តស្រលាញ់ នារី **គ** ហើយបានសម្រេចចិត្តរំលាយកំជាប់ពាក្យជាមួយនារី **ខ** នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២។ ក្នុងករណីនេះ នារី **ខ** ត្រូវធ្វើបណ្តឹងទាមទារ ក្នុងអំឡុងពេល១ឆ្នាំ គឺមិនឱ្យហួសថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៣ បានឡើយ។ បើមិនដូច្នោះទេ បណ្តឹងរបស់ នារី **ខ** បានផុតអាជ្ញាយុកាល បានសេចក្តីថា តុលាការមិនសម្រេចសេចក្តីលើបណ្តឹងទាមទាររបស់ នារី **ខ** ពាក់ព័ន្ធនឹងការសងជំនូន និងសំណងជម្ងឺចិត្តផ្សេងៗបានឡើយ។

## ២.២. លក្ខខណ្ឌគតិយុត្តិដើម្បីរៀបអាពាហ៍ពិពាហ៍

ជាក់ស្តែង ដើម្បីក្លាយជាប្តីប្រពន្ធស្របច្បាប់ លុះត្រាណាតែបុរស និងនារីដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាស្របតាមប្រពៃណីទំនៀមទម្លាប់ខ្មែរហើយនោះ បានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវជូនដំណឹងជាសាធារណៈ និងចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ជាដើម។ មិនតែប៉ុណ្ណោះ ការដែលបុគ្គលពីរនាក់អាចប្រារព្ធ ក៏ដូចជាធ្វើការរៀបអាពាហ៍ស្របច្បាប់ជាមួយគ្នាបាន ច្បាប់បានដាក់ចេញនូវលក្ខខណ្ឌធំៗពីរយ៉ាងនៅក្នុងការរៀបអាពាហ៍ពិពាហ៍ ដូចជា ចំពោះបុគ្គលដែលអាចរៀបអាពាហ៍ពិពាហ៍បាន ច្បាប់តម្រូវឱ្យមានអាយុ ១៨ ឆ្នាំឡើង ជាអាយុដល់នីតិភាពដែលកំណត់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែបុគ្គលដែលមានអាយុមិនតិចជាង ១៦ ឆ្នាំ ដល់ក្រោមអាយុ ១៨ ឆ្នាំ ក៏អាចរៀបអាពាហ៍ពិពាហ៍បានដែរ ប្រសិនបើមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលនៃ អនីតិជននោះ និងគោរពតាមលក្ខខណ្ឌច្បាប់ផ្សេងៗដែលបានបញ្ញត្តិ។ ចំណែកឯលក្ខខណ្ឌផ្សេងៗទៀតក៏មានលក្ខណៈស្មុគស្មាញផងដែរ ព្រោះថា ការរៀបអាពាហ៍ពិពាហ៍ ក៏ដូចជាការកសាងគ្រួសារនៅក្នុងសង្គមមួយពុំមែនជារឿងងាយស្រួលនោះទេ ពោលគឺទាមទារឱ្យមានការបង្ហាញឆន្ទៈក្នុងការរួមរស់នៅជាមួយគ្នា ការដល់នូវនីតិភាពនៃការគិត ការពិចារណាក៏ដូចជាការជ្រើសរើសដៃគូរដោយខ្លួនឯងជាដើម។ ហើយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ធ្វើយ៉ាងណាមិនឱ្យមានការភិតភ័យ ការលួចលាក់ ដែលនាំឱ្យមានបញ្ហារកាំរកូសក្នុងគ្រួសារឈានដល់ការលែងលះ និងអសន្តិសុខក្នុងសង្គមឡើយ។ ទាំងនេះគ្រាន់តែជាលក្ខខណ្ឌគ្រឹះដែលនាំឱ្យមានការរៀបអាពាហ៍ពិពាហ៍កើតឡើង ចំណែកឯលក្ខខណ្ឌដែលនាំឱ្យអាពាហ៍ពិពាហ៍នោះស្របតាមច្បាប់គឺមានជាច្រើនដែរ ដែលទាំងនេះជាអ្វីដែលប្រជាពលរដ្ឋមានការភាន់ច្រឡំ និងអាចបណ្តាលឱ្យកើតមាននូវការរស់នៅបែបអនីតិសង្វាស។ ជាក់ស្តែងប្រជាពលរដ្ឋមួយចំនួន ជាពិសេសនៅតាមជនបទហាក់មានទំនោរយ៉ាងខ្លាំងទៅលើការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីទំនៀមទម្លាប់ ដោយមិនមានការចាប់អារម្មណ៍ទៅលើការចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលប្រជាពលរដ្ឋមួយចំនួនតែងនិយមហៅថា «អេតាស៊ីវិល» ដែលជាពាក្យរបស់បារាំង។

ដើម្បីអាចរៀបអាពាហ៍ពិពាហ៍តាមលក្ខណៈច្បាប់ សាមីខ្លួនបុរស និងនារី ត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនជាមុនសិនដូចជា៖ **លក្ខខណ្ឌភេទរបស់ភាគី លក្ខខណ្ឌអាយុរបស់ភាគី ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ ការរៀបអាពាហ៍ពិពាហ៍របស់ជនដែលត្រូវបានកម្រិតសមត្ថភាព គោលការណ៍ស្ម័គ្រចិត្ត** ជាមុនសិន។

### ២.២.១. លក្ខខណ្ឌភេទរបស់ភាគី

ការរៀបអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរតាំងពីសម័យបុរាណមក គឺប្រកាន់យកភេទផ្ទុយគ្នា ដោយបុរស ត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនារី។ សូម្បីសង្គមនាពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជាពុំទាន់មានការផ្លាស់ប្តូរអ្វីនៅឡើយទេ ដោយនៅតែប្រកាន់យកភេទផ្ទុយគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដដែល។ ជាក់ស្តែងក្នុងប្រទេសមួយចំនួនមានការទទួលស្គាល់ ក៏ដូចជាអនុញ្ញាតឱ្យមានការរៀបការរវាងបុគ្គលដែលមានភេទស្របគ្នា ឬដូចគ្នាដោយស្របច្បាប់ ប៉ុន្តែប្រទេសកម្ពុជាពុំទាន់មានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក៏ដូចជាការធ្វើការនិរាករណ៍ចំពោះមាត្រាណាមួយនៃក្រមរដ្ឋប្បវេណីទាក់ទងនឹងលក្ខខណ្ឌភេទក្នុងការរៀបអាពាហ៍ពិពាហ៍នោះឡើយ។ ខ្លឹមសារនៃរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា[២២] ក៏ដូចជាច្បាប់ឯកពន្ធភាព[២៣] ក៏បានបញ្ញត្តិយ៉ាងច្បាស់ថា ជនដែលអាចមានចំណងអាពាហ៍ស្របច្បាប់ជាមួយគ្នាបានលុះត្រាតែបុគ្គលនោះមានភេទផ្ទុយគ្នា គឺ «បុរស» និង «ស្ត្រី»។ ជាក់ស្តែង ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារចាស់ក៏បានបញ្ញត្តិយ៉ាងច្បាស់ទាក់ទងទៅនឹងភេទដែលមិនអាចរៀបអាពាហ៍ពិពាហ៍បានគឺ ភេទដូចគ្នា[២៤] ដែលនេះមានន័យថា បុគ្គលដែលមានភេទដូចគ្នានៅកម្ពុជាពុំអាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាននោះទេ គឺច្បាប់អនុញ្ញាតតែចំពោះបុគ្គលដែលមានភេទដូចគ្នាតែប៉ុណ្ណោះ។ ទាក់ទងនឹងបញ្ហានេះដែរ បច្ចុប្បន្ននេះនៅប្រទេសកម្ពុជាក៏មានបុគ្គលដែលមានភេទដូចគ្នាដែលបានរៀបការតាមប្រពៃណីទំនៀមទម្លាប់ខ្មែរ ក៏ដូចគ្នារស់នៅជាមួយគ្នាជាប្តីប្រពន្ធ ទោះបីជាប្រទេសកម្ពុជាមិនអនុញ្ញាតឱ្យមានការចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ និងគ្មានការទទួលស្គាល់ពីអាជ្ញាធរនៅក្នុងភូមិ ឃុំក៏ដោយ ដែលនេះគឺជាការរស់នៅជាមួយគ្នាដោយអនិតិសង្វាសដែរមួយចំនួនធំ មានការទទួលស្គាល់ពីក្រុមគ្រួសារ និងសង្គម តែមួយចំនួនទៀតពុំមានការទទួលស្គាល់ឡើយ។

---

[២២] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ១៩៩៣, មាត្រា ៤៥។

[២៣] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី ០១ កញ្ញា ២០០៦, មាត្រា ២។

[២៤] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា៦។

### ២.២.២. លក្ខខណ្ឌអាយុរបស់ភាគី

មូលហេតុនៃការកំណត់អាយុនេះ គឺជាការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់រដ្ឋាភិបាលលើសុខភាព និង សុខុមាលភាពរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ដែលមានបំណងកសាងគ្រួសារឲ្យបានរឹងមាំ មានសុភមង្គល និង ធានាការចិញ្ចឹមបីបាច់ថែរក្សាអប់រំកូនរបស់គេបានល្អប្រសើរ ព្រោះថាការរៀបការពុំមែនជារឿងដែលលំបាកនោះ ឡើយ ប៉ុន្តែបញ្ហាដែលសំខាន់គឺ ការរក្សាចំណងអាពាហ៍ពិពាហ៍ឱ្យស្ថិតស្ថេរ និងមានសុភមង្គលតរៀងទៅ។

បុរស និង ស្ត្រីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវតែមានអាយុ១៨ឆ្នាំឡើងទៅ ដែលជាអាយុ ពេញលេញតាមការកំណត់របស់ច្បាប់។[២៥] សូមបញ្ជាក់ផងដែរថា ភាគីណាដែរបានដល់នីតិភាព គឺមានន័យថា គាត់បានដល់អាយុ ១៨ឆ្នាំ ឬទទួលបាននូវអត្តាធីនភាព។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារចាស់ដែលអស់សុពលភាពហើយនោះ បានកំណត់ថា បុរស ត្រូវ មានអាយុយ៉ាងតិច ២០ឆ្នាំ ហើយស្ត្រីត្រូវមានអាយុយ៉ាងតិច ១៨ឆ្នាំ។[២៦] ក្រមរដ្ឋប្បវេណីសង្គមចាស់ បាន កំណត់ថា បុរស ត្រូវមានអាយុយ៉ាងតិច ១៧ឆ្នាំ និងស្ត្រីត្រូវមានអាយុយ៉ាងតិច ១៤ឆ្នាំឡើងទៅ ទើបអាចរៀប អាពាហ៍ពិពាហ៍បាន។[២៧] យើងឃើញថា ការកំណត់អាយុនាសម័យនោះ បុរសតែងមានអាយុបង ឬលើសអាយុ ខាងនារី។ មូលហេតុនៃការកំណត់អាយុខុសគ្នា រវាងបុរស និងនារីនេះ ដោយសារតែនៅក្នុងផ្នត់គំនិតខ្មែរយើង យល់ឃើញថា បុរសជាមេគ្រួសារជាអ្នកមើលការខុសត្រូវភរិយាក៏ដូចជាសមាជិកគ្រួសារដទៃទៀត។ ហេតុនេះ ល័ក្ខខ័ណ្ឌអាយុបុរសត្រូវតែមានច្រើនជាងនារី អាចនិយាយបានថា បុរសចាស់ចិត្តគំនិតជាងនារី។ សូម្បីតែការ ហៅ គេតែងតែហៅបុរសថា « បង» ចំណែកបុរសហៅនារីថា «អូន»។ អូន មកពីពាក្យថា ប្អូន គឺមានន័យថា មានអាយុតិចជាង។ ចំណែកឯនៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ វិញបានផ្តល់សមភាពរវាងបុរស និងនារីក្នុងការ រៀបអាពាហ៍ពិពាហ៍ លើកលែងតែករណីភាគីម្ខាងដល់ ១៦ឆ្នាំ។ មួយវិញទៀត ក្រមរដ្ឋប្បវេណី ២០០៧ បាន កំណត់អាយុស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍រវាងបុរសនារីបែបនេះ មកពីក្រមមួយនេះប្រសូតឡើងដោយត្រូវ មានធម្មនុញ្ញភាពនៃច្បាប់កំពូល ហើយប្រសិនបើយើងពិនិត្យមើល មាត្រា៤៥ កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ចែងថា៖ « បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជា ពិសេសក្នុងអាពាហ៍ពិពាហ៍ » នេះបញ្ជាក់នូវការគោរពសេចក្តីថ្លែងការណ៍ជាសាកលអំពីសិទ្ធិមនុស្សនៅកម្ពុជា

---

[២៥] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ១៧។

[២៦] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា ៥។

[២៧] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩២០, មាត្រា១១៦។

ឆ្នាំ១៩៤៨ ពាក់ព័ន្ធទៅនឹងសមភាពបុរសនារី ដោយច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។[២៨] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិជាថ្មីថា បុរស និងនារី មិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។[២៩]

កាលណាយុវជនមានអាយុដល់ ១៨ឆ្នាំ ដែលជាអាយុអតិប្បរមាដែលអាចប៉ាន់ស្មានថា បុគ្គលនោះបានដល់នូវការយល់ដឹង ព្រមទាំងអាចចាកចេញពីផ្ទះសម្បែង ឬលំនៅដ្ឋានដែលប្រជាជននៃប្រទេសជិតខាងនិយមធ្វើ ក្នុងគោលបំណងចាកចេញទៅស្វែងរកចំណេះដឹង បទពិសោធន៍ជីវិត និងអាចប្រកបរបរចិញ្ចឹមជីវិតបានដោយខ្លួនឯង។ ហេតុនេះ កាលណាបុរស ឬស្ត្រីនោះ បានដល់វ័យ ១៨ឆ្នាំ ហើយនោះ មានន័យថាពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការត្រិះរិះពិចារណា ការសម្រេចចិត្ត និងអាចរស់នៅដោយពុំចាំបាច់ពឹងផ្អែកលើក្រុមគ្រួសារទៀតឡើយ។

### ២.២.២.១. អាពាហ៍ពិពាហ៍របស់ជនដែលទទួលបានអត្តាធីនភាព

អត្តាធីនភាព គឺជាស្ថានភាពមួយដែលឱ្យអនីតិជនឱ្យបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។[៣០] ការទទួលបានអត្តាធីនភាព បានធ្វើឱ្យអនីតិជននោះ ក្លាយជានីតិជន ដែលចាត់ទុកថាបានដល់នីតិភាព។[៣១]

នៅក្នុងប្រទេសកម្ពុជា ការអនុញ្ញាតឱ្យអនីតិជនទទួលបានអត្តាធីនភាពបាន ក្នុងករណីដែលអនីតិជននោះបានដល់អាយុ ១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពខ្លួនឯងបាន ដោយឯករាជ្យ ទើបតុលាការអាចប្រកាសនូវអត្តាធីនភាពតាមពាក្យសុំរបស់អនីតិជននោះ។[៣២] ក្នុងករណីដែលតុលាការយល់ឃើញថា អត្តាធីនភាពនោះស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ហើយតុលាការក៏ត្រូវធ្វើការសាកសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា

---

[២៨] ប៊ួយ ធីតា, សៀវភៅនីតិរដ្ឋប្បវេណី, ទំព័រទី ២៣៤ បោះពុម្ពលើកទី១, ខែមករា ឆ្នាំ២០២៤។

[២៩] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤៨។

[៣០] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ២៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[៣១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ២២។

[៣២] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ចុះថ្ងៃទី ១០ កក្កដា ២០១០។

ផងដែរ។ អនីតិជនដែលទទួលបានអត្តាធីនភាព និងអនីតិជនធម្មតាអាចរៀបអាពាហ៍ពិពាហ៍បានចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជនធម្មតានោះសិន។[៣៣]

អនីតិជនដែលទទួលបានអត្តាធីនភាព និងអនីតិជនដែលទទួលបានអត្តាធីនភាពដូចគ្នាអាចរៀបអាពាហ៍ពិពាហ៍បានដោយពុំត្រូវការការយល់ព្រមពីអាណាព្យាបាល ឬឪពុកម្តាយឡើយ។

**ឧទាហរណ៍ទី១៖** បុរស **ក** មានអាយុ ១៦ឆ្នាំ និងនារី **ខ** មានអាយុ ១៦ឆ្នាំ ហើយដោយទទួលបាននូវអត្តាធិនភាពដូចគ្នា ត្រង់ចំណុចនេះប្រសិនបើអ្នកទាំងពីមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃខាងមុខ លុះត្រាតែមានការយល់ព្រមពីឪពុកម្តាយទាំងសងខាងជាមុនសិន។ ទោះបីជាភាគីខាងបុរស **ក** មានការយល់ព្រមតែម្តាយ គ្មានការយល់ព្រមពីឪពុក និងភាគីខាងនារី **ខ** មានការយល់ព្រមឪពុក គ្មានការយល់ព្រមពីម្តាយក៏ដោយ ក៏អនីតិជននោះអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ។ យ៉ាងណាមិញប្រសិនបើមានការមិនព្រមពីឪពុកម្តាយទាំងសងខាង បុរស **ក** និងនារី **ខ** អាចទាមទារទៅអាជ្ញាធរមានសមត្ថកិច្ចឱ្យជួយសម្រេចជំនួសឪពុកម្តាយរបស់គេបាន។

**ឧទាហរណ៍ទី២៖** បុរស **ក** មានអាយុ១៦ឆ្នាំ (បានទទួលអត្តាធីនភាព) មានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយ នារី **ខ** ដែរមានអាយុ ១៦ឆ្នាំ ដូចគ្នា (មិនមានអត្តាធិនភាព) ករណីនេះទាល់តែមានការយល់ព្រមពីឪពុកម្តាយរបស់នាងជាមុនសិន។ ប៉ុន្តែប្រសិនបើនារី **ខ** ទទួលបានអត្តាធិនភាពដែលនោះ គឺមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយរបស់នាងនោះទេ។

### ២.២.២.២. អាពាហ៍ពិពាហ៍របស់នីតិជន និងអនីតិជន

ភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនអាចរៀបអាពាហ៍ពិពាហ៍ តែអនីតិជននោះត្រូវតែមានអាយុមិនក្រោម ១៦ឆ្នាំ ឡើយ ដោយៈ

- ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតីជននោះ។[៣៤]

[៣៣] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤៨, វាក្យខណ្ឌទី២។

[៣៤] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥៣, កថាខណ្ឌទី១។

- បើអ្នកដែលមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាណាម្ខាង ជាការគ្រប់គ្រាន់ហើយ។[៣៥]
- ប៉ុន្តែបើករណីអ្នកមានអំណាចមេបា ឬអាណាព្យាបាលបដិសេធការព្រមដោយគ្មានមូលហេតុសមរម្យ នោះអនីតិជន ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារទៅតុលាការឱ្យសម្រេចជំនួសការយល់ព្រមនោះបាន។[៣៦] ឧទាហរណ៍៖ ខែ ឆ្នាំមិនត្រូវគ្នា ឬផ្សេងទៀត អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន។[៣៧]

**តារាងសង្ខេបសម្រាប់បញ្ជាក់ពីការយល់ព្រម ឬមិនយល់ព្រមលើការរៀបអាពាហ៍ពិពាហ៍៖**[៣៨]

| ករណី | អាយុភាគី | | ការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាល |
|---|---|---|---|
| | អាយុភាគីម្ខាង | អាយុភាគីម្ខាងទៀត | |
| ១ | នីតិជន (អាយុចាប់ពី១៨ឆ្នាំឡើងទៅ) | នីតិជន (អាយុចាប់ពី១៨ឆ្នាំឡើងទៅ) | មិនចាំបាច់យល់ព្រម |
| ២ | នីតិជន (អាយុចាប់ពី១៨ឆ្នាំឡើងទៅ) | អនីតិជន (អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) | ភាគីអនីតិជនចាំបាច់មានការយល់ព្រម |
| ៣ | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) | នីតិជន (អាយុចាប់ពី១៨ឆ្នាំឡើងទៅ) | មិនចាំបាច់យល់ព្រម |
| ៤ | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) | អនីតិជន (អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) | ភាគីអនីតិជនចាំបាច់មានការយល់ព្រម |

[៣៥] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥៣, កថាខណ្ឌទី២។

[៣៦] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥៣, កថាខណ្ឌទី៣។

[៣៧] ប៊ួយ ធីតា, សៀវភៅនីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ខែមករា ឆ្នាំ២០២៤, ទំព័រទី ២៣៣។

[៣៨] ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រទី៣៨ , ឆ្នាំ២០២១, ភ្នំពេញ។

| | | | |
|---|---|---|---|
| ៥ | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) | មិនចាំបាច់យល់ព្រម |

## ២.២.៣. ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

បុគ្គលណាម្នាក់ដែលមាន ប្តី ឬប្រពន្ធរួចហើយ ហើយចំណងអាពាហ៍ពិពាហ៍របស់ពួកគេគឺជាចំណងអាពាហ៍ពិពាហ៍មួយដ៏ស្របច្បាប់ ព្រមទាំងនៅមានសុពលភាពនៅឡើយ ពួកគេមិនអាចទៅលួចលាក់រៀបអាពាហ៍ពិពាហ៍ ឬបង្កើតចំណងអាពាហ៍ពិពាហ៍ប្តី ឬប្រពន្ធថ្មីមួយទៀតបាននោះឡើយ។[៣៩] ដូចគ្នានេះផងដែរ រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃប្រទេសកម្ពុជា ក៏បានបញ្ញត្តិទាក់ទងនឹងបញ្ហានេះផងដែរ ដោយប្តីប្រពន្ធត្រូវគោរពនូវគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ។[៤០] បើយើងក្រឡេកទៅមើលក្រមរដ្ឋប្បវេណីចាស់វិញ យើងឃើញមានភាពមិនស្មើគ្នារវាងបុរស និងនារី ដែលបុរសអាចរៀបការលើកទី១បានហើយ គេក៏អាចរៀបការជាលើកទី២ជាមួយនារីផ្សេងបានទោះបីខ្លួននៅមានចំណងអាពាហ៍ពិពាហ៍មិនក៏ដោយ ចំណែកឯនារីវិញអាចមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយបុរសតែម្នាក់ប៉ុណ្ណោះ។[៤១] យ៉ាងណាមិញ បច្ចុប្បន្ននេះពុំមែនមានតែក្រមរដ្ឋប្បវេណីប៉ុណ្ណោះទេដែលមានការកែប្រែលើកស្ទួយសិទ្ធិបុរស និងនារីឱ្យមានភាពស្មើគ្នា ដូចជាច្បាប់ស្តីពីឯកពន្ធភាពជាដើមគឺជាច្បាប់មួយដែលបញ្ញត្តិទាក់ទងនឹងរឿងនេះផ្ទាល់តែម្តង។ ឯកពន្ធភាព គឺជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធមួយ ឯស្ត្រីវិញក៏មានប្តីតែមួយដូចគ្នា។ ហេតុនេះប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវតែគោរពតាមគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានតាមលក្ខខណ្ឌនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ។[៤២]

ទោះបីជារដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន បានហាមឃាត់មិនឱ្យបុរស ឬស្ត្រីមានប្តី ឬប្រពន្ធ ២ ឬ ៣យ៉ាងដូច្នេះក៏ដោយ ប៉ុន្តែការរស់នៅក្នុងសង្គមជាក់ស្តែង មានបុរសដែលបានរស់នៅក្នុងពេលតែមួយជាមួយប្រពន្ធ ២ ឬលើសនេះក៏មាន ដែលអ្នកខ្លះបានរៀបអាពាហ៍ពិពាហ៍ តែអ្នកខ្លះទៀតមិនបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ ហើយភាគីខាងស្ត្រីព្រមព្រៀងរស់នៅជាមួយគ្នា ដោយមិនប្តឹងផ្តល់។ ការដែលច្បាប់

[៣៩] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤៩។

[៤០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ១៩៩៣, មាត្រា ៤៥ វាក្យខណ្ឌទី៤។

[៤១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០, មាត្រា ១៣៩។

[៤២] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី ២១តុលា ២០០៦, មាត្រា ០២។

បានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងប្ដីមួយប្រពន្ធច្រើននាក់ ឬប្ដីច្រើននាក់ប្រពន្ធមួយនេះ គឺហាមចំពោះអាជ្ញាធរ មិនត្រូវចេញលិខិតអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍របៀបនេះឡើយ ប៉ុន្តែក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាធ្វើរបៀបនេះ អាស្រ័យលើភាគីអាចរស់នៅជាមួយគ្នាបាន តែច្បាប់មិនមានចែងថា ការមានប្ដី ឬ ប្រពន្ធច្រើនជាការខុសច្បាប់ ហើយត្រូវមានទោសឡើយ លើកលែងតែមានការប្ដឹងផ្ដល់ពីភរិយាដើម។ ប៉ុន្តែប្រសិនបើមានភាគីណាមួយមិនសុខចិត្តនឹងការមានប្ដីច្រើន ឬប្រពន្ធច្រើន ភាគីនោះអាចប្ដឹង ដើម្បីផ្ដន្ទាទោសភាគីម្ខាងទៀត ដោយយោងទៅតាមការមានចែងនៅក្នុងច្បាប់ស្ដីពីឯកពន្ធភាព។[៤៣]

### ២.២.៤. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

អាពាហ៍ពិពាហ៍មួយ ពិតណាស់មិនអាចមានភាពឋិតថេរគង់វង្សបានគ្រប់ក្រុមគ្រួសារនោះទេ។ ជាក់ស្ដែង ក្នុងករណីដែលអាពាហ៍ពិពាហ៍មួយបានបញ្ចប់ក្នុងមូលហេតុណាក៏ដោយដែលនាំឱ្យបុគ្គលទាំងពីរលែងមានអានុភាពគតិយុត្តិតាមផ្លូវច្បាប់ជាស្វាមី ភរិយានឹងគ្នា នោះបុគ្គលទាំងពីរនេះអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយមានលក្ខខណ្ឌរៀងៗខ្លួន។ ចំពោះបុរស នៅពេលដែលខ្លួនបានបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍រួចហើយនោះ គេនឹងអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានភ្លាមៗដោយពុំមានរយៈពេលកំណត់ដែលតម្រូវឱ្យបុរសរង់ចាំនោះឡើយ។ ដោយឡែក ភាគីខាងនារីវិញ នៅពេលដែលខ្លួនបានផ្ដាច់ទំនាក់ទំនងអាពាហ៍ពិពាហ៍រួចហើយនោះ ច្បាប់បានកំណត់នូវអំឡុងពេលមួយដែលត្រូវរង់ចាំទម្រាំតែមានរៀបអាពាហ៍ពិពាហ៍ថ្មីបាន គឺរយៈពេល១២០ (មួយរយម្ភៃ) ថ្ងៃ។[៤៤] យើងអាចយល់ឃើញថា ការធ្វើបែបនេះអាចជាការបង្កើតឱ្យមានភាពមិនស្មើគ្នារវាងបុរស និងស្ត្រី ប៉ុន្តែហេតុផលដែលច្បាប់តម្រូវឱ្យភាគីខាងនារីរង់ចាំឱ្យផុតរយៈពេលនេះ ព្រោះតែច្បាប់បានគិតគូរដល់កូន មានន័យថា ក្នុងអំឡុងពេលនេះគេត្រូវរង់ចាំមើលថាតើនារីនោះនឹងមានផ្ទៃពោះដែរឬទេ។ កាលណាយើងអនុញ្ញាតឱ្យនារីអាចរៀបអាពាហ៍ពិពាហ៍បានភ្លាមៗដូចបុរសដែរ នោះពេលដែលស្ត្រីនោះមានផ្ទៃពោះ យើងពិបាកក្នុងការដឹងថាតើ កូននោះជាកូនរបស់ចំណងអាពាហ៍ពិពាហ៍មុន ឬក្រោយ ដែលយើងនឹងពិបាកក្នុងការកំណត់ពីបិតុភាពរបស់កូនក្នុងផ្ទៃនោះ ហើយវាក៏ជះផលប៉ះពាល់ដល់កូននោះផងដែរ។

ទាក់ទងនឹងការកំណត់អំឡុងពេលនៃការហាមឃាត់មិនឱ្យស្ត្រីមានអាពាហ៍ពិពាហ៍ថ្មីនេះដែរ ច្បាប់ក៏បានកំណត់នូវលក្ខខណ្ឌលើកលែងចំនួនពីរចំណុចផងដែរ៖[៤៥]

---

[៤៣] គន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រទី ៤៩, ឆ្នាំ២០២១, ភ្នំពេញ។

[៤៤] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥០ កថាខណ្ឌទី១។

[៤៥] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥០ កថាខណ្ឌទី២។

- **ចំណុចទី១៖** ក្នុងករណីដែលស្ត្រីនោះមានផ្ទៃពោះមុនពេលមានការលែងលះ ឬមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់ និងបានសម្រាលកូនរួច នោះស្ត្រីនោះអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយមិនចាំបាច់រង់ចាំរយៈពេល១២០ (មួយរយម្ភៃ) ថ្ងៃឡើយ ព្រោះបិតុភាពនៃកូននោះជាប្តីមុន។
- **ចំណុចទី២៖** ក្នុងករណីដែលស្ត្រីមានលិខិតបញ្ជាក់ពីខាងវេជ្ជបណ្ឌិត ថាខ្លួនគ្មានផ្ទៃពោះ នោះស្ត្រីនោះអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយមិនចាំបាច់រង់ចាំរយៈពេល១២០ (មួយរយម្ភៃ) ថ្ងៃទេ។

## ២.២.៥. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិ

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងបញ្ញត្តិ ហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍រវាងថ្នាក់ញាតិជិតគ្នា។ ការរៀបអាពាហ៍ពិពាហ៍ជាមួយថ្នាក់ញាតិជិតគ្នាបែបនេះត្រូវបានច្បាប់ហាមឃាត់ដាច់ខាត ដោយមូលហេតុនៃ សុជាតិវិទ្យា និង សីលធម៌សង្គម។[៤៦] បើយោងទៅតាមមូលហេតុ សុជាតិវិទ្យា គឺការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នានេះ ងាយនឹងបណ្តាលឱ្យកូនដែលកើតមកនោះ មានអាការៈសុខភាពខ្សោយ ប្រឈមនឹងជម្ងឺផ្សេងៗ ហើយលទ្ធភាពនៃពិការភាពចំពោះកូនដែលកើតមកកើនឡើងខ្ពស់ជាងកុមារធម្មតាទូទៅ។ រីឯមូលហេតុសីលធម៌សង្គមវិញ ក៏ជាបញ្ហាមួយធំផងដែរ ពីព្រោះវាផ្ទុយពីសីលធម៌សង្គម ហើយសង្គមមិនទទួលស្គាល់អាពាហ៍ពិពាហ៍បែបនេះដែរ។

- **ញាតិលោហិត** សំដៅបុគ្គលដែលមានទំនាក់ទំនងសាច់ញាតិលោហិតពីកំណើតជាមួយបុគ្គលម្នាក់ទៀត (ញាតិលោហិតពីកំណើត និងញាតិលោហិតដែលកំណត់ដោយច្បាប់)។
- **ញាតិលោហិតខ្សែផ្ទាល់** សំដៅដល់ ញាតិដែលមានឈាមជាមួយគ្នា ហើយកើតតគ្នាពីមួយទៅមួយទៀតតាមលំដាប់។
- **សាខាញាតិ៖** សំដៅដល់ ញាតិដែលចែកជាមែកធាងពីអ្នកបង្កើតរួម ដូចជា បងប្អូនបង្កើត មីងមា ក្មួយ បងប្អូនជីដូនមួយជាដើម។

លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ង់ចំណុចនេះគឺ បុរស និងនារីដែលនឹងរៀបអាពាហ៍ពិពាហ៍នឹងគ្នាមិនត្រូវមានជាប់ចំណងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣។ ហើយទោះបីជាមានការផ្តាច់ទំនាក់ទំនង ឬការកាត់កាល់គ្នារវាងឪពុកម្តាយ និងកូន[៤៧] ឬឪពុកម្តាយ និងកូនសុំក៏ដោយ[៤៨] ក៏

---

[៤៦] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០០៩ - ២០១០, មាត្រា៩៥១។

[៤៧] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ១០១៤។

[៤៨] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ១០១៦។

លក្ខខណ្ឌនេះនៅតែអនុវត្តជានិច្ច។ ក្រមរដ្ឋប្បវេណីបានហាមមិនឱ្យមានអាពាហ៍ពិពាហ៍កើតឡើងចំពោះញាតិដែលមានទំនាក់ទំនងគ្នា ចំពោះករណីមួយចំនួនដូចខាងក្រោម៖

### ២.២.៥.១. ការហាមឃាត់ចំពោះញាតិលោហិតក្នុងខ្សែផ្ទាល់

អាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់គ្រប់ថ្នាក់ទាំងអស់ត្រូវបានហាមឃាត់ដែលមានដូចជា៖[៤៩]

- រវាងចុងគល់ ឬចុងកុល ជាមួយចៅចុងកុល (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៧)
- រវាងជីប៉ា ជាមួយចៅប៉ា (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៦)
- រវាងជីលា ជាមួយចៅលា (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៥)
- រវាងជីលួត ជាមួយចៅលួត (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៤)
- រវាងជីទួត ជាមួយចៅទួត (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៣)
- រវាងជីតា ឬជីដូន ជាមួយចៅ (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី២)
-ររវាងឪពុកម្ដាយ ជាមួយកូន (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី១)។

### ២.២.៥.២. ការហាមឃាត់ចំពោះសាខាញាតិលោហិត

អាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិតក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទីបីនេះផង ដែលមានដូចជា៖[៥០]

- រវាងបងប្អូនបង្កើត (សាខាញាតិថ្នាក់ទី២)
- រវាងពូ ឬមីង និងក្មួយ (សាខាញាតិថ្នាក់ទី៣)។

ក្នុងករណីនេះផងដែរ ចំពោះសាខាញាតិលោហិតចាប់ពីថ្នាក់ទី៤ទៅ អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដូចជា បងប្អូនជីដូនមួយ ឬបងប្អូនជីទួតមួយជាដើម។

## ២.២.៦. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

បុរស និងស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវមានជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជានៅថ្នាក់ណាក៏ដោយ ដែលក្រមរដ្ឋប្បវេណីបានហាមឃាត់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ទេ។[៥១] ទោះបីជាញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឱ្យញាតិ

[៤៩] គន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ទំព័រទី ៥៤, ភាគ ១, ឆ្នាំ២០២២។

[៥០] គន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ទំព័រទី ៥៤, ភាគ ១, ឆ្នាំ២០២២។

[៥១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥២។

ពន្ធខ្សែផ្ទាល់នោះ អាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានដែរ។ ច្បាប់ក៏បានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ រហូតដល់ថ្នាក់ទី៣ ផងដែរ។ ទោះបីក្នុងករណីដែលទំនាក់ទំនងរវាងញាតិពន្ធត្រូវបញ្ចប់ហើយក៏ដោយ ច្បាប់នៅតែមិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ដែរ។

- **ញាតិពន្ធ៖** សំដៅដល់ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត ឬហៅថា «សាច់ថ្លៃ »។

  **ឧទាហរណ៍៖** ឪពុកម្តាយក្មេក និងកូនប្រសា បងថ្លៃប្អូនថ្លៃ (ខាងប្តី ឬប្រពន្ធ)។

- **ញាតិពន្ធខ្សែផ្ទាល់៖** សំដៅដល់ ញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃដែលកើតតពីមួយទៅមួយតាមលំដាប់ ដូចជាជីដូនជីតាក្មេក ឪពុកម្តាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត (ប៉ុន្តែជាកូនចុងរបស់សហព័ទ្ធម្ខាងទៀត)។

### ២.២.៦.១. ការហាមឃាត់ចំពោះញាតិពន្ធក្នុងខ្សែផ្ទាល់

ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់ត្រូវបានច្បាប់ហាមឃាត់ ហើយទោះបីទំនាក់ទំនងញាតិពន្ធខ្សែផ្ទាល់នោះត្រូវបានបញ្ចប់ហើយក៏ដោយ ក៏ច្បាប់ពុំអនុញ្ញាតដែរ។[៥២]

ញាតិពន្ធក្នុងខ្សែផ្ទាល់មានដូចជា៖[៥៣]

- រវាងឪពុកម្តាយក្មេក និងកូនប្រសា
- រវាងជីដូនជីតាក្មេក និងចៅប្រសា
- រវាងជីដូនជីតាទួតក្មេក និងចៅទួតប្រសា
- រវាងជីលួតក្មេក និងចៅលួតប្រសា
- រវាងជីលាក្មេក និងចៅលាប្រសា
- រវាងអតីតឪពុកម្តាយក្មេក និងអតីតកូនប្រសា
- រវាងអតីតជីដូនជីតាក្មេក និងអតីតចៅប្រសា
- រវាងអតីតជីដូនជីតាទួតក្មេក និងអតីតចៅទួតប្រសា
- រវាងអតីតជីលួតក្មេក និងអតីតចៅលួតប្រសា
- រវាងអតីតជីលាក្មេក និងអតីតចៅលាប្រសា។

[៥២] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥២ កថាខណ្ឌទី១។

[៥៣] គន់ យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ទំព័រទី ៦០, ភាគ ១, ឆ្នាំ២០២២។

យើងគួរធ្វើការកត់សម្គាល់ផងដែរថា ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែផ្ទាល់គ្រប់ថ្នាក់ និងញាតិពន្ធខ្សែផ្ទាល់គ្រប់ថ្នាក់នេះ ដូចគ្នាទៅនឹងក្រមរដ្ឋប្បវេណីពីសង្គមចាស់ផងដែរ។ ច្បាប់បានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬញាតិពន្ធនឹងគ្នាក្នុងក្រសែផ្ទាល់គ្រប់ថ្នាក់ទោះជាចំណងមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬសាច់ចិញ្ចឹមក្តី។[៥៤] **ឧទាហរណ៍៖** លោក **ក** បានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រី **ខ**។ ប៉ុន្តែក្រោយមកលោក **ក** ជាប្តី បានទទួលមរណភាព។ ទោះបីជាយ៉ាងនេះក្តីក៏លោកស្រី **ខ** មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយនឹង ឪពុករបស់លោក **ខ** បានដែរ ព្រោះថាលោកស្រី **ខ** និងឪពុកក្មេក ជាទំនាក់ទំនង ឪពុកក្មេក និងកូនប្រសារ (ញាតិពន្ធនៃខ្សែផ្ទាល់ថ្នាក់ទី១)។

### ២.២.៦.២. ការហាមឃាត់ចំពោះសាខាញាតិពន្ធ

ច្បាប់បានហាមមិនឱ្យមានការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធនៅក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣នេះផង ហើយទោះបីទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ហើយក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានដែរ។[៥៥] សាខាញាតិពន្ធនោះមានដូចជា៖[៥៦]

- រវាងបងថ្លៃប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី២)
- រវាងអតីតបងថ្លៃ និងអតីតប្អូនថ្លៃ
- រវាងពូ ឬមីងក្មេក ជាមួយក្មួយប្រសា (សាខាញាតិពន្ធថ្នាក់ទី៣)
- រវាងអតីតពូមីងក្មេក ជាមួយអតីតក្មួយប្រសា
- រវាងបងប្អូនបង្កើតរបស់ប្តី ជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ
- រវាងអតីតបងប្អូនបង្កើតរបស់ប្តី ជាមួយអតីតបងប្អូនបង្កើតរបស់ប្រពន្ធ។

យើងអាចធ្វើការសម្គាល់បានផងដែរថា ដោយសាខាញាតិពន្ធនេះ មាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួមដែលមានលក្ខណៈជិតស្និទ្ធស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិលោហិតដែរ។ ប៉ុន្តែដោយសារនៅក្នុងប្រទេសកម្ពុជា មានករណីការរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬប្អូនថ្លៃដូចជាករណីប្តីបានទទួលមរណភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬប្អូនប្រុសដែលនៅលីវរបស់សព្វប្តី ឬករណីដែលប្រពន្ធបានទទួលមរណភាពទៅ បងស្រី ឬប្អូនស្រីរបស់សព្វប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយ

[៥៤] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០, មាត្រា១១៨។

[៥៥] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥២ កថាខណ្ឌទី២។

[៥៦] ឥន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ទំព័រទី ៦១, ភាគ ១, ឆ្នាំ២០២២។

បងថ្លៃ ឬប្អូនថ្លៃប្រុសនោះ ដើម្បីមើលថែទាំកូនរបស់បុគ្គលដែលទទួលមរណភាពជាដើម។ ប៉ុន្តែប្រសិនបើករណីដែលទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ដោយមូលហេតុលែងលះក៏ដោយ នៅតែមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានឡើយ។

អាពាហ៍ពិពាហ៍ក៏ពុំអាចធ្វើបានដែរ ចំពោះសាខាញាតិពន្ធនៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផង ហើយទោះបីបានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ។ ប៉ុន្តែប្រសិនបើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់បាន។[៥៧] ប៉ុន្តែការបញ្ចប់ដោយមូលហេតុលែងលះ ក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ រវាងសាខាញាតិពន្ធរហូតដល់ថ្នាក់ទី ៣ (បី) ដោយរាប់ទាំងថ្នាក់ទី ៣ (បី) ផងដែរ។ **ឧទាហរណ៍ទី១៖** អតីតមីង ឬមាបានរៀបអាពាហ៍ពិពាហ៍ជាមួយអតីតក្មួយប្រសា ពេលដែលក្មួយបង្កើតរបស់ខ្លួនបានទទួលមរណភាព។ ត្រង់ករណីនេះច្បាប់បានអនុញ្ញាតឱ្យពួកគេរៀបអាពាហ៍ពិពាហ៍បាន។ **ឧទាហរណ៍ទី២៖** អតីតមីង ឬមាបានរៀបអាពាហ៍ពិពាហ៍ជាមួយអតីតក្មួយប្រសា នៅពេលដែលក្មួយបង្កើតរបស់ខ្លួន បានលែងលះគ្នាតាមផ្លូវច្បាប់។ ត្រង់ចំណុចនេះច្បាប់បានហាមឃាត់មិនអនុញ្ញាតឱ្យពួកគេរៀបអាពាហ៍ពិពាហ៍បានឡើយ។

## ២.២.៧. ការរៀបអាពាហ៍ពិពាហ៍របស់ជនដែលត្រូវបានកម្រិតសមត្ថភាព

### ២.២.៧.១. អាពាហ៍ពិពាហ៍របស់ជនស្ថិតក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ ឬគេអាចហៅថាជាជនវិកលចរិតដែលជានីតិជននោះ ក៏ត្រូវបានច្បាប់អនុញ្ញាតឱ្យធ្វើការរៀបអាពាហ៍ពិពាហ៍បានដែរ។ ជននៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិបញ្ញាស្មារតីដូចជា ដូចជាជនវិកលចរិត ឬជនដែលពុំអាចប្រកបនូវសកម្មភាពជារៀងរាល់ថ្ងៃបានដោយត្រូវការជំនួយពីអ្នកដទៃ ជាដើម។ ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅអាចប្រព្រឹត្តទៅបាន ក្នុងករណីដែលជននោះមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអតិបរមាដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ដែលអាចទទួលយកបានហើយក្នុងករណីនេះ ការសម្រេចចិត្តរបស់ជននេះ ពុំចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលឡើយ។[៥៨] **ឧទាហរណ៍៖** លោក **ក** មានអាយុ ២៧ឆ្នាំ និងគូដណ្ដឹងមានអាយុ ២៥ឆ្នាំ ដែលមានគម្រោងរៀបការជាមួយគ្នានៅឆ្នាំក្រោយ។ ជាអកុសល នៅក្នុងអំឡុងឆ្នាំ

[៥៧] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥២ កថាខណ្ឌទី២។

[៥៨] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៥៤។

នេះ លោក **ក** បានជួបនឹងគ្រោះថ្នាក់ចរាចរណ៍ដែលបានបណ្តាលឱ្យប៉ះទង្គិចដល់បញ្ញាស្មារតីរបស់គាត់ដែល គាត់ពុំអាចប្រកបសកម្មភាពប្រចាំថ្ងៃដែលគាត់ធ្លាប់ធ្វើបាននោះឡើយ។ ដោយសារមូលហេតុនេះហើយ លោក **ក** ត្រូវការដាក់ឱ្យស្ថិតនៅក្រោមការដាក់ឱ្យនៅក្រោមអាណាព្យាបាលទូទៅដែលប្រកាសដោយដីកាសម្រេចរបស់ តុលាការ ដែលកំណត់ឱ្យពួរបស់គាត់ជាអាណាព្យាបាលទូទៅ។ មិនយូរប៉ុន្មាន ស្ថានភាពរបស់លោក **ក** មាន លក្ខណៈល្អប្រសើរឡើងវិញបន្តិចម្តងៗ។ ចំណុចនេះមានន័យថា លោក **ក** មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ខ្លួននៅក្នុងការរៀបអាពាហ៍ពិពាហ៍បានហើយ ហេតុនេះ លោក **ក** អាចបង្ហាញឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ បានដោយការសម្រេចចិត្តរបស់ខ្លួនឯង មិនចាំបាច់មានការយល់ព្រមពីអាណាព្យាបាលទូទៅឡើយ។

### ២.២.៧.២. អាពាហ៍ពិពាហ៍របស់ជនស្ថិតក្រោមហិតូបត្ថម្ភ

ចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ (ជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី) អាចរៀប អាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ (មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី មិនតម្រូវឱ្យមានការយល់ព្រមបែបនេះទេ)។[៥៩] **ឧទាហរណ៍៖** លោក **សំភី** មានអាយុ ៣០ឆ្នាំ។ ក្រោយពីជួប ប្រទះនូវគ្រោះថ្នាក់ចរាចរណ៍ដែលមានការប៉ះទង្គិចត្រង់ក្បាលរួចមក លោក **សំភី** បានក្លាយជាមនុស្សដែលមិន សូវដឹងខុសត្រូវដូចពីមុនទេ ប៉ុន្តែវេជ្ជបណ្ឌិតជំនាញបានបញ្ជាក់ថា គាត់មិនមែនមិនដឹងខុសត្រូវទាំងស្រុងទេ គ្រាន់តែដឹងខុសត្រូវតិចតួចតែប៉ុណ្ណោះ។ ក្នុងករណីបែបនេះ គឺគេអាចស្នើសុំឱ្យតុលាការសម្រេចដាក់លោក **សំភី** ឱ្យស្ថិតនៅក្រោមហិតូបត្ថម្ភតាម ដីកាសម្រេច (ដោយជ្រើសតាំងនរណាម្នាក់ឱ្យធ្វើជាហិតូបត្ថម្ភកៈ (អ្នក គ្រប់គ្រង) របស់លោក **សំភី**។ ទោះបីជាក្នុងករណីយ៉ាងនេះក៏ដោយ លោក **សំភី** នៅតែអាចរៀបការបាន ដោយ មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។

### ២.២.៨. គោលការណ៍ស្ម័គ្រចិត្ត

សង្គមខ្មែរនាសម័យបុរាណប្រកាន់យកផ្នត់គំនិត នំមិនធំជាងនាឡិ ដែលមានឪពុកម្តាយជាអ្នកមាន អំណាចលើការជ្រើសរើសគូស្រករឱ្យកូន ជាពិសេសគឺកូនស្រី ដែលពុំមានសិទ្ធិក្នុងការប្រកែកនៅពេលដែលខ្លួន មិនពេញចិត្តចំពោះការលើកទុកដាក់របស់ឪពុកម្តាយរបស់ខ្លួន។ យ៉ាងណាមិញ បច្ចុប្បន្ននេះ សង្គមខ្មែរមានការ ផ្លាស់ប្តូរយ៉ាងខ្លាំង ដោយមិនថាបុរស ឬស្ត្រីមានសិទ្ធិស្មើៗគ្នាក្នុងការជ្រើសរើសគូស្រករ ឬគូរជីវិតសម្រាប់ជីវិត របស់ពួកគេ។ បុរស និងស្ត្រីដែលបានសម្រេចចិត្តថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវឈរលើគោលការណ៍

[៥៩] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួយ នីតិព្រហ្មទណ្ឌ និងគ្រួសារ, ទំព័រទី ៣២០, បោះពុម្ពលើកទី២, ឆ្នាំ២០២០។

ស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំពីឪពុកម្ដាយ ឬអាណាព្យាបាល ហើយភាគីណាមួយមិនអាចបង្ខំភាគីម្ខាងទៀតបានឡើយ រីឯតតិយជនរឹតតែគ្មានសិទ្ធិក្នុងការបង្ខំឱ្យភាគីណាមួយរៀបអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួនបានឡើយ។ ការរៀបអាពាហ៍ពិពាហ៍ដែលកើតឡើងផ្ទុយពីឆន្ទៈរបស់សាមីខ្លួនត្រូវបានហាមឃាត់ដាច់ខាតក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ដោយសារតែវាខុសពីរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស។

គោលការណ៍ស្ម័គ្រចិត្តនេះត្រូវបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយអាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ។[៦០]

ជាគោលការណ៍ ការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ ត្រូវតែជាការព្រមព្រៀងដោយសេរី ពោលគឺមិនត្រូវមានការបង្ខំ ការគំរាម ការឆបោក ឬ ការភាន់ច្រឡំលើមនុស្សឡើយ។ យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីមិនបានកំណត់និយមន័យឱ្យបានច្បាស់លាស់នៃពាក្យទាំងអស់នេះក៏ដោយ ប៉ុន្តែយើងអាចសន្មតបានថា៖[៦១]

- **ការបង្ខំ**៖ សំដៅដល់ការបង្ខិតបង្ខំឱ្យសាមីខ្លួនដែលមិនមានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍សោះឱ្យធ្វើការយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍នេះ ឯភាគីវិញ ព្រោះតែត្រូវបានគេបង្ខំ និងខ្លួនពុំមានជម្រើសក្នុងការជ្រើសរើស ក៏ព្រមតាមការបង្ខិតបង្ខំនោះដោយខ្លួនពុំមានឆន្ទៈសោះឡើយ
- **ការភ័ន្តច្រឡំលើមនុស្ស**៖ សំដៅលើករណីនៃការភ័ន្តច្រឡំទៅលើអត្តសញ្ញាណរបស់មនុស្ស។ **ឧទាហរណ៍**៖ មានការភ័ន្តច្រឡំអាចកើតមានឡើងលើកូនភ្លោះជាដើម។
- **ការគំរាមកំហែង**៖ មានន័យថា សាមីខ្លួនធ្វើការយល់ព្រមដោយសារតែភាពភ័យខ្លាចពីសំណាក់បុគ្គលណាម្នាក់ដែលបានជូនដំណឹងអាក្រក់ណាមួយមកឱ្យភាគី ដែលធ្វើឱ្យភាគីមានការភ័យខ្លាច និងត្រូវតែធ្វើការយល់ព្រមចំពោះការគំរាមកំហែងឱ្យរៀបអាពាហ៍ពិពាហ៍នេះ។ **ឧទាហរណ៍**៖ កញ្ញា **ក** ត្រូវបានម្ដាយរបស់នាងគំរាមថានឹងកាត់កាល់នាងចោល ប្រសិនបើនាងមិនយល់ព្រមរៀបការជាមួយនឹងលោក **ខ** តាមការជ្រើសរើសរបស់គាត់ទេនោះ។
- **ការឆបោក**៖ គឺជាការបោកប្រាស់ឱ្យជនណាម្នាក់ធ្លាក់ទៅក្នុងការភ័ន្តច្រឡំ និងយល់ព្រមរៀបការ។ **ឧទាហរណ៍៖** កញ្ញា **ក** បានយល់ព្រមរៀបការជាមួយនឹងលោក ខ ដោយសារតែលោក **ខ** បានធ្វើឱ្យនាងជឿជាក់ថា គាត់គឺជាសេដ្ឋីម្នាក់តាមរយៈពាក្យសម្ដី និងការបង្ហាញពីភាពហ៊ឺហារ និងមានអង្គរក្ស មានអ្នកបម្រើជាច្រើនរបស់លោក។

[៦០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ១៩៩៣, មាត្រា ៤៥ វាក្យខណ្ឌទី៤។
[៦១] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, សៀវភៅជំនួសស្មារតី នីតិព្រហ្មទណ្ឌ និងគ្រួសារ, ទំព័រទី ៣២១, បោះពុម្ពលើកទី២, ឆ្នាំ២០២២។

## ២.៣. នីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍ច្រើនតែធ្វើជាពីរដំណាក់កាល គឺការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទំលាប់ប្រពៃណី ឬសាសនា និងការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ អាពាហ៍ពិពាហ៍នឹងមានអានុភាពនៅពេលដែលភាគីនោះបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[៦២]

### ២.៣.១. ដំណាក់កាលនៃការដាក់ពាក្យស្នើសុំ

#### ២.៣.១.១. ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍

ជាការពិតណាស់ ពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា មុននឹងពិធីអាពាហ៍ពិពាហ៍អាចកើតឡើងបាន ភាគីទាំងសងខាងនៃអាពាហ៍ពិពាហ៍ ត្រូវធ្វើលិខិតបញ្ជាក់ពីភាពនៅលីវ ឬមេម៉ាយពី ឃុំ សង្កាត់ខាងលំនៅដ្ឋានរបស់ភាគីទាំងសងខាងរៀងៗខ្លួនជាមុនសិន។ ការធ្វើបែបនេះគឺដើម្បីភាពប្រាកដថា បុគ្គលទាំងសងខាងនៃអាពាហ៍ពិពាហ៍ មិនមានការជាប់ជំពាក់ជាមួយបុគ្គលណាផ្សេងឡើយ និងដើម្បីបង្កានូវបញ្ហាដែលនឹងកើតឡើងនាពេលអនាគតដូចជាការលែងលះ ការជាប់ជំពាក់ចំណងអាពាហ៍ពិពាហ៍ដែលមិនដាច់ស្រឡះ ឬមានចំណងអាពាហ៍ពិពាហ៍ច្រើនដែលនាំឱ្យមានវិវាទកើតឡើងនៅតុលាការជាដើម។ មួយវិញទៀត ការរៀបអាពាហ៍ពិពាហ៍គឺជាការកសាងគ្រួសារ ហេតុនេះហើយច្បាប់គឺត្រូវធ្វើយ៉ាងណាដើម្បីធានាការពារដល់សិទ្ធិ និងកាតព្វកិច្ច បុគ្គលដែលត្រូវក្លាយជាអាណាព្យាបាលយ៉ាងត្រឹមត្រូវដល់ក្មេងដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍នោះនាពេលអនាគត។ មេឃុំ ចៅសង្កាត់ដែលបានចេញលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយនេះ ត្រូវមានបិទរូបថតថ្មីទំហំ ៤គុណនឹង៦មួយសន្លឹកផង ហើយលិខិតនេះមានសុពលភាពត្រឹម០៣ខែប៉ុណ្ណោះ។[៦៣]**(ឧបសម្ព័ន្ធទី៣)**

ក្រោយពីបានលិខិតបញ្ជាក់នេះហើយ បុរសម្នាក់ និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយបានយោងតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ មាត្រា២៨ បានកំណត់ថា បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់នារី។ ប៉ុន្តែច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា

[៦២] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៥៥ កថាខណ្ឌទី១។

[៦៣] ឥន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រ ៧០, ឆ្នាំ២០២១, ភ្នំពេញ។

ឆ្នាំ២០២៣ មាត្រា៦៧ ក្រោយពីបានលិខិតបញ្ជាក់នេះហើយ បុរសម្នាក់ និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបុរស ឬនារីនោះរស់នៅ។

### ២.៣.១.២. ដំណាក់កាលត្រួតពិនិត្យរបស់មន្ត្រីអត្រានុកូលដ្ឋាន

បន្ទាប់មក ក្រោយពីមេឃុំ ឬចៅសង្កាត់បានទទួលពាក្យស្នើសុំនោះហើយ ហើយក្នុងឋានៈខ្លួនជាមន្ត្រីអត្រានុកូលដ្ឋានដែលមានតួនាទីក្នុងដំណើរការនៃការរៀបអាពាហ៍ពិពាហ៍នេះ ត្រូវចេញលិខិតអនុញ្ញាតឱ្យភាគីទាំងសងខាងនេះរៀបអាពាហ៍ពិពាហ៍នឹងគ្នាបាន និងចេញបណ្ណប្រកាសដើម្បីយកទៅបិទផ្សាយជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍នេះទៀតផង។ បើយោងទៅលើល័ក្ខខ័ណ្ឌរៀបអាពាហ៍ពិពាហ៍ បុរសនារីត្រូវមានឯកសារដូចជា៖[៦៤]

- សំបុត្រកំណើតឬអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួននៃសាមីភាគី។
- សំបុត្របញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ មេម៉ាយ។
- សាលក្រម ឬសេចក្តីសម្រេចឱ្យលែងលះ សម្រាប់ភាគីពោះម៉ាយ ឬមេម៉ាយដោយការលែងលះ។
- សំបុត្រមរណភាពនៃសហព័ទ្ធ ក្នុងករណីភាគីពោះម៉ាយ ឬ មេម៉ាយដោយសហព័ទ្ធទទួលមរណភាព ឬ មានការប្រកាសបាត់ខ្លួន។
- ចំពោះនារីដែលមានស្ថានភាពមេម៉ាយត្រូវរង់ចាំរយៈពេល ១២០ (មួយរយម្ភៃ)ថ្ងៃក្រោយស្វាមីទទួលមរណភាព ឬ សាលក្រម ដីកាសម្រេចចូលជាស្ថាពរ ឬ សំបុត្រពេទ្យបញ្ជាក់ថានារីនោះមិនមានផ្ទៃពោះ។ ក្នុងករណីមិនទាន់គ្រប់១២០(មួយរយម្ភៃ)ថ្ងៃ ឬ បានសម្រាលកូនដែលមានស្វាមីមុនជាឪពុក។
- ត្រូវពិនិត្យមើលឯកសារ ឬ សួរបន្ថែមដើម្បីបញ្ជាក់ថា បុរសនិងនារីនោះមិនមែនជាញាតិនឹងគ្នាដែលច្បាប់ហាមឃាត់រៀបអាពាហ៍ពិពាហ៍។
- ភាគីត្រូវតែមិនធ្លាប់ជាញាតិនៃស្មុំកូនដែលក្រោយមកបានកាត់កាល់។
- ជាចុងក្រោយគឺត្រូវប្រាកដថាបុរសនិងនារីនោះបានស្គាល់គ្នាច្បាស់ ចៀសវាងការភាន់ច្រឡំ និងបញ្ជាក់ថាពិតជាមានឆន្ទៈរួមរស់ជាមួយគ្នាជាប្តី ប្រពន្ធពិតប្រាកដមែន។

[៦៤] ប៊ួយ ធីតា, សៀវភៅនីតិរដ្ឋប្បវេណី បោះពុម្ពលើកទី១, ទំព័រទី ២៣៩, ខែមករា ឆ្នាំ២០២៤។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថាអាពាហ៍ពិពាហ៍នោះផ្ទុយនឹងបញ្ញត្តិ ចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ)។[៦៥]

### ២.៣.២. ការចេញបណ្ណប្រកាសជាសាធារណៈ

បន្ទាប់ពីមេឃុំ ចៅសង្កាត់ដែលមានមុខងារជាមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់នារីបានពិនិត្យទៅលើសំណុំឯកសាររបស់ភាគីដែលបានដាក់ពាក្យស្នើសុំនោះ[៦៦] ឃើញថាត្រឹមត្រូវតាមបញ្ញត្តិច្បាប់ហើយនោះ លោកជាអ្នកមានសិទ្ធិក្នុងការចេញសេចក្តីសម្រេចអនុញ្ញាតឱ្យភាគីទាំងពីររៀបអាពាហ៍ពិពាហ៍នឹងគ្នាបាន និងជាអ្នកចេញបណ្ណប្រកាសការរៀបអាពាហ៍ពិពាហ៍។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញបណ្ណប្រកាសអាពាហ៍ពិពាហ៍នេះចំនួន ០៤ (បួន) ច្បាប់ដូចជា៖[៦៧] **(ឧបសម្ព័ន្ធទី១២)**

- ០១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅឋានខាងនារី
- ០១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ ឬសង្កាត់ខាងនារី
- ០២ (ពីរ) ច្បាប់ ផ្ញើជូនមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយជាសាធារណៈនៅលំនៅឋានខាងបុរសចំនួន ០១ (មួយ) ច្បាប់ និងនៅសាលាឃុំ ឬសង្កាត់នោះចំនួន ០១ (មួយ) ច្បាប់។

បណ្ណប្រកាសជាសាធារណៈនៃការរៀបអាពាហ៍ពិពាហ៍ ត្រូវតែបិទផ្សាយក្នុងរយៈពេល១០ថ្ងៃ នៅលំនៅឋានខាងនារី និងនៅសាលាឃុំ សង្កាត់ខាងនារី ព្រមទាំងលំនៅឋាន និងសាលាឃុំ សង្កាត់ខាងបុរសដូចគ្នា ដើម្បីឱ្យអ្នកមានផលប្រយោជន៍ក្នុងអាពាហ៍ពិពាហ៍អាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នេះបាន។

#### ២.៣.២.១. រយៈពេលរង់ចាំ

ដូចដែលបានលើកឡើងខាងលើ បណ្ណប្រកាសអាពាហ៍ពិពាហ៍គឺមានគោលបំណងក្នុងការប្រកាសឱ្យបានដឹងឮដល់អ្នកដែលមានប្រយោជន៍នៃការរៀបអាពាហ៍ពិពាហ៍នេះឱ្យពួកគេអាចប្ដឹងជំទាស់បាន។ ភាគីទាំងពីរដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ ត្រូវរង់ចាំរយៈពេលយ៉ាងតិច ១០ថ្ងៃ បន្ទាប់ពីថ្ងៃបិទប្រកាសអាពាហ៍ពិពាហ៍

[៦៥] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៥៦។

[៦៦] អនុក្រឹត្យលេខ ១០៣ អនក្រ.បក.ស្តីពីអត្រានុកូលដ្ឋាន, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា ២៨ វាក្យខណ្ឌទី២។

[៦៧] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា ៦៩។

ហើយប្រសិនបើផុតរយៈពេលនេះ ពុំមាននរណាម្នាក់ជំទាស់លើអាពាហ៍ពិពាហ៍របស់ពួកគេទេនោះ គម្រោងនៃការរៀបអាពាហ៍ពិពាហ៍របស់ពួកគេនឹងអាចប្រព្រឹត្តទៅបានដោយស្របតាមច្បាប់។

យោងតាមមាត្រា៦៩ នៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣បានចែងថា៖ ក្រោយរយៈពេល ១០ (ដប់) ថ្ងៃ ដែលបានបិទផ្សាយជាសាធារណៈ ការជូនដំណឹងអាពាហ៍ពិពាហ៍កន្លងផុតទៅ ហើយគ្មានការប្ដឹងជំទាស់ទេនោះ អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលានៅក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ក្នុងអំឡុងពេលនេះប្រសិនបើបុរសនារីដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ មិនបានមកចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចរំលឹកដោយការជូនដំណឹងទៅបុរស និង នារីនោះបាន។[៦៨]

### ២.៣.២.២. អ្នកដែលមានសិទ្ធិធ្វើបណ្ដឹងជំទាស់

ដោយយោងទៅតាមមាត្រា ៣០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃអនុក្រឹត្យលេខ១០៣ អនប្រ.បក ស្ដីពីអត្រានុកូលដ្ឋាន ពុំបានចែងបញ្ជាក់ច្បាស់លាស់ថា ជនដែលមានប្រយោជន៍ដែលអាចប្ដឹងជំទាស់នឹងគម្រោងអាពាហ៍ពិពាហ៍នេះបានមានបុគ្គលណាខ្លះនោះទេ។ ប៉ុន្តែយើងអាចធ្វើការសន្និដ្ឋានបានថា ការប្ដឹងផ្ដល់គ្នាពុំមែនជាការល្អប្រសើរនោះឡើយ ដោយឡែកអ្នកដែលនឹងបង្កើតឱ្យមាននូវបណ្ដឹងជំទាស់នេះ ពួកគេច្បាស់ជាចង់ទាមទារចង់បានផលប្រយោជន៍ណាមួយពីការរៀបអាពាហ៍ពិពាហ៍នេះ។ មួយវិញទៀត យើងឃើញថា បុគ្គលណាម្នាក់អាចមានសិទ្ធិក្នុងការចូលខ្លួនមកធ្វើបណ្ដឹងជំទាស់ក្នុងគម្រោងអាពាហ៍ពិពាហ៍នេះ លុះត្រាតែបុគ្គលនោះមានទំនាក់ទំនងណាមួយ ជាមួយនឹងជនដែលមានគម្រោងនឹងរៀបអាពាហ៍ពិពាហ៍នោះជាក់ជាមិនខាន។ ដូច្នេះ អ្នកដែលមានសិទ្ធិធ្វើបណ្ដឹងជំទាស់ទៅលើគម្រោងអាពាហ៍ពិពាហ៍នោះបាន អាចជាបុគ្គលដែលមានផលប្រយោជន៍ដូចជា សាច់ញាតិ ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ឬតតិយជនណាម្នាក់ដែលអាចមានការពាក់ព័ន្ធជាមួយនឹងអាពាហ៍ពិពាហ៍ដោយផ្ទាល់តែម្ដង ដូចជាភាគីដែលគ្រោងរៀបអាពាហ៍ពិពាហ៍ធ្លាប់ជាប្ដីឬប្រពន្ធរបស់ខ្លួន ប៉ុន្តែបែរជាមកលួចរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយអ្នកផ្សេងដោយលួចលាក់ ឬធ្លាប់រស់នៅជាមួយគ្នាពីមុនដោយមិនបានរៀបអាពាហ៍ពិពាហ៍ជាដើម។[៦៩] បុគ្គលទាំងអស់នេះហើយជាបុគ្គលដែលមានប្រយោជន៍ និងមានសិទ្ធិក្នុងការប្ដឹងជំទាស់លើគម្រោងអាពាហ៍ពិពាហ៍នេះបាន ក្នុងអំឡុងពេល១០ថ្ងៃនៃការបិទប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងនឹងប្រព្រឹត្តទៅនេះ។ ចំពោះបុគ្គលដែលមានបំណងក្នុងការប្ដឹងជំទាស់ទៅលើ

---

[៦៨] ប៊ួយ ធីតា, សៀវភៅនីតិរដ្ឋប្បវេណី បោះពុម្ពលើកទី១, ទំព័រទី ២៤១, ខែមករា ឆ្នាំ២០២៤។

[៦៩] គន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រទី ៧២, ឆ្នាំ២០២១, ភ្នំពេញ។

គម្រោងអាពាហ៍ពិពាហ៍នេះត្រូវដាក់ពាក្យបណ្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់ពីមូលហេតុនៃការប្ដឹងជំទាស់ឱ្យបានច្បាស់លាស់ ព្រមទាំងហត្ថលេខារបស់សាមីខ្លួនដោយផ្ទាល់ដៃ[៧០] និងដាក់បណ្ដឹងជំទាស់នោះជូនទៅសាលាឃុំ ឬសង្កាត់ខាងលំនៅឋានរបស់ភាគីដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ។

### ២.៣.២.៣. មូលហេតុជំទាស់នឹងគម្រោងអាពាហ៍ពិពាហ៍

មូលហេតុនៃការប្ដឹងជំទាស់ទៅលើគម្រោងអាពាហ៍ពិពាហ៍ ព្រមទាំងជាមូលហេតុដែលនាំឱ្យមន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិបដិសេធមិនទទួលយកសំណើរអាពាហ៍ពិពាហ៍នោះបានផងដែរ ដែលមានដូចជា៖[៧១]

- អនាគតប្ដី ឬប្រពន្ធមិនទាន់ដល់នីតិភាព (អាយុក្រោម១៨ឆ្នាំ) ឬក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតមានអាយុក្រោម ១៦ ឆ្នាំ
- ករណីភាគីមានសហព័ទ្ធហើយ (មានប្ដី ឬប្រពន្ធ)
- អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត
- ក្នុងករណីដែលនារីត្រូវបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍មុនរួចហើយ ប៉ុន្តែនៅមិនទាន់គ្រប់រយៈពេល១២០ថ្ងៃ
- ករណីដែលអាពាហ៍ពិពាហ៍បានធ្វើឡើងរវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតរហូតដល់ថ្នាក់ទី ៣ និងរាប់ទាំងថ្នាក់ទី ៣ ផង
- ករណីដែលអាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងញាតិពន្ធនៃខ្សែផ្ទាល់ ឬអាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងសាខាញាតិពន្ធរហូតថ្នាក់ទី ៣ និងរាប់ទាំងថ្នាក់ទី ៣ ផង
- អាពាហ៍ពិពាហ៍របស់អនីតិជនដែលមិនមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន
- អាពាហ៍ពិពាហ៍របស់ជនវិកលចរិត (ជននៅក្រោមអាណាព្យាបាលទូទៅ) ដែលមិនមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាបាន។

បើគម្រោងនៃការរៀបអាពាហ៍ពិពាហ៍នោះមានចំណុចណាមួយដូចដែលមាននៅក្នុងចំណុចទាំងអស់ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិក្នុងការបដិសេធមិនចេញនូវលិខិតប្រកាសឱ្យរៀបអាពាហ៍ពិពាហ៍ ឬ

[៧០] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា ១៦។

[៧១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥៦។

បានចេញរួចហើយក្តី ក៏ភាគីដែលមានផលប្រយោជន៍អាចធ្វើការប្តឹងជំទាស់ដោយលើកយកមូលហេតុណាមួយពីមូលហេតុទាំងអស់ខាងលើនេះបាន។

### ២.៣.២.៤. ការសម្រេចលើបណ្តឹងជំទាស់

នៅពេលដែលបណ្តឹងជំទាស់បានដាក់ជូនដល់ដៃនៃមន្រ្តីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់អ្នកដែលដាក់ពាក្យសុំដែលកើតចេញពីគម្រោងនៃអាពាហ៍ពិពាហ៍នោះហើយឃុំ សង្កាត់នោះត្រូវតែពិនិត្យ និងធ្វើសេចក្តីសម្រេចលើបណ្តឹងនេះក្នុងរយៈពេល ០៣ (បី) ថ្ងៃគិតចាប់ពីថ្ងៃទទួលបានបណ្តឹង។ បើមេឃុំ ឬចៅសង្កាត់បានដំណើរការនៃការសម្រេចលើបណ្តឹងនេះបានទាន់ពេលវេលាហើយនោះ ប៉ុន្តែអ្នកប្តឹងជំទាស់ ឬអនាគតប្តី ប្រពន្ធនោះ មិនសុខចិត្តនឹងសេចក្តីសម្រេចនេះទេ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ ត្រូវបញ្ជូនសំណុំរឿងនេះបន្តទៅតុលាការប្រជាជនក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹងជំទាស់ដើម្បីសម្រេច។[៧២] តុលាការប្រជាជន ត្រូវសម្រេចសេចក្តីលើបណ្តឹងជំទាស់នេះក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ គិតពីថ្ងៃដែលបានទទួលសំណុំរឿងពីគណៈកម្មាធិការប្រជាជនឃុំ សង្កាត់។ នៅពេលដែលតុលាការប្រជាជនបានពិនិត្យ ក៏ដូចជាបានចេញសាលក្រមលើបណ្តឹងនោះហើយនោះ មិនអាចមានប្តឹងតវ៉ាបានឡើយ ទោះបីសាលក្រមនោះជាសាលក្រមកំបាំងមុខក៏ដោយ[៧៣] ពោលគឺភាគីនៃបណ្តឹងមិនអាចប្តឹងបន្តទៅឧទ្ធរណ៍បានទេ។ ប្រសិនបើតុលាការប្រជាជនបានបដិសេធទៅលើបណ្តឹងទាស់នោះចោលហើយនោះ អនាគតប្តី ប្រពន្ធ ដែលមានគម្រោងរៀបអាពាហ៍ពិពាហ៍នោះអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន ។ ប៉ុន្តែប្រសិនបើតុលាការប្រជាជនចាត់ទុកបណ្តឹងជំទាស់នោះថាពិតជាត្រឹមត្រូវ នោះមន្រ្តីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ខាងលំនៅឋានរបស់អនាគតភរិយានោះត្រូវតែបញ្ឈប់មិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ។[៧៤]

ពាក់ព័ន្ធនឹងករណីនៃការប្តឹងជំទាស់ទៅលើគម្រោងនៃការរៀបអាពាហ៍ពិពាហ៍នេះដែរ មានបញ្ហាចោទឡើងនៅត្រង់ថា អ្នកដែលរស់នៅជាមួយគ្នារបៀបអនីតិសង្វាសមានសិទ្ធិប្តឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍បានដែរឬទេ? បើពួកគេមានមេភូមិ អ្នកជិតខាងដឹងឮថាបានរស់នៅជាមួយគ្នាក្នុងនាមជាប្តីប្រពន្ធ ប៉ុន្តែមិនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងមិនបានរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល (ចុះសំបុត្រអាពាហ៍ពិពាហ៍)។ ភាគីមិនអាចប្តឹងទៅមេឃុំ ចៅសង្កាត់ ដើម្បីជួយទប់ស្កាត់គម្រោងរៀបអាពាហ៍ពិពាហ៍បានឡើយ ហើយបើទោះបីពួកគេអាចប្តឹងជំទាស់បាន ប៉ុន្តែនៅពេលមេឃុំ ឬចៅសង្កាត់សួររកឯកសារបញ្ជាក់ថា អ្នក

---

[៧២] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា ១៧។

[៧៣] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា ១៨។

[៧៤] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា ១៩។

ទាំងពីរធ្លាប់ជាប្ដីប្រពន្ធនឹងគ្នាដោយយកសំបុត្រអាពាហ៍ពិពាហ៍ជាភស្តុតាង នោះពួកគេពុំមានឯកសារណាមួយយកមកឱ្យមេឃុំបានឡើយ។ ប្រសិនបើគ្មានភស្តុតាងទេ មេឃុំ ឬចៅសង្កាត់នឹងមិនទទួលពាក្យបណ្ដឹងទេ ហើយមិនអាចចេញការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍បានដែរ ហើយទោះបីមានការប្ដឹងដល់តុលាការក៏តុលាការនឹងធ្វើដូចគ្នានេះដែរ ព្រោះថាឯកសារនៃសំបុត្រអាពាហ៍ពិពាហ៍ពិតជាមានសារៈសំខាន់ណាស់។

ទោះបីនៅក្នុងករណីដែលអ្នកទាំងពីរមានសំបុត្រស្នាក់នៅជាមួយគ្នា ឬមានសំបុត្រគ្រួសារបញ្ជាក់ ដើម្បីធ្វើជាភស្តុតាងបង្ហាញទៅមេឃុំ ឬចៅសង្កាត់ ឬទៅតុលាការ។ សំបុត្រស្នាក់នៅជាមួយគ្នា ឬសំបុត្រគ្រួសារ មិនមែនជាសំបុត្រអាពាហ៍ពិពាហ៍ដែលបញ្ជាក់ច្បាស់ថា ភាគីទាំងពីរជាប្ដីប្រពន្ធនឹងគ្នាទេ សំបុត្រនោះគ្រាន់តែបញ្ជាក់អំពីការស្នាក់នៅនឹងអត្តសញ្ញាណគ្រួសារប៉ុណ្ណោះ ។ មេឃុំ ឬចៅសង្កាត់ ឬតុលាការ នៅតែមិនមានភស្តុតាងសម្រាប់ការសម្រេចសេចក្ដីជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍ដដែល។ បញ្ហានេះហើយដែលនៅតែមិនមានវិធានច្បាប់ដោះស្រាយទេ ហើយនៅក្នុងទម្លាប់អនុវត្តនៃការអនុវត្តរបស់មេឃុំ ឬចៅសង្កាត់ ឬតុលាការក្ដី គឺនឹងធ្វើដូចអ្វីដែលបានរៀបរាប់ខាងលើនេះ។ គោលការណ៍នេះ មិនសមស្របឡើយ សម្រាប់ភាគី ព្រោះថាពួកគេមិនទទួលបានដំណោះស្រាយអ្វីឡើយសម្រាប់ខ្លួនពួកគេ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ច្បាប់ក៏បានបញ្ញត្តិមកហើយថា ការរៀបអាពាហ៍ពិពាហ៍ និងការមាននូវសំបុត្រអាពាហ៍ពិពាហ៍ពិតជាមានសារៈសំខាន់ណាស់ ជាពិសេសនៅពេលដែលមានបញ្ហាណាមួយកើតឡើងដូចដែលបានលើកឡើងខាងលើនេះ។ មេឃុំ ឬចៅសង្កាត់ ឬតុលាការមិនធ្វើការទទួលការដោះស្រាយចំពោះការរស់នៅជាមួយគ្នាតាមរបៀបអនីតិសង្វាសនេះទេ ព្រោះជាគោលការណ៍ច្បាប់ទទួលស្គាល់អាពាហ៍ពិពាហ៍ស្របច្បាប់ ប៉ុន្តែមិនទទួលស្គាល់អាពាហ៍ពិពាហ៍មិនស្របច្បាប់នោះឡើយ។ ហេតុនេះ នៅពេលមានការប្ដឹងជំទាស់ទៅលើគម្រោងនៃអាពាហ៍ពិពាហ៍នេះចំពោះអ្នកដែលអះអាងថាខ្លួនជាសហព័ទ្ធនឹងគ្នា ដោយមិនមានសំបុត្រអាពាហ៍ពិពាហ៍ ឬហៅថាទំនាក់ទំនងអនីតិសង្វាសច្បាប់នៅតែពុំមានដំណោះស្រាយសម្រាប់ពួកគេនោះឡើយ។

### ២.៣.៣. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

លុះដំណាក់កាលទាំងអស់ខាងលើនេះ ដូចជាការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ដំណាក់កាលនៃការប្ដឹងជំទាស់បានឆ្លងផុតហើយនោះ ភាគីទាំងសងខាងនៃគម្រោងអាពាហ៍ពិពាហ៍នេះ នឹងអាចធ្វើការរៀបអាពាហ៍ពិពាហ៍បានហើយ។ បន្ទាប់ពីពួកគេបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចរាល់ហើយនោះ ដំណាក់កាលបន្ទាប់នៃការធ្វើឱ្យអាពាហ៍ពិពាហ៍របស់ពួកគេស្របតាមច្បាប់នោះគឺ ការចុះបញ្ជីសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅលំនៅឋានដែលបានដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍នោះ ឬយើងតែងតែហៅថា « អេតាស៊ីវិល » នេះឯង។

### ២.៣.៣.១. ការចុះបញ្ជីអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ត្រូវចាត់ទុកថាស្របច្បាប់ លុះត្រាណាតែបុរស និងនារីបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ។[៧៥]

#### ក. ការចុះបញ្ជីអាពាហ៍ពិពាហ៍របស់សហព័ទ្ធដែលទើបរៀបការរួច

ការចុះបញ្ជីអាពាហ៍ពិពាហ៍ត្រូវធ្វើឡើង ទៅតាមការកំណត់របស់អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ដោយបុរស និងស្ត្រីដែលបានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍នឹងគ្នាជាប្តី ប្រពន្ធ នោះត្រូវបញ្ជាក់ប្រាប់មន្ត្រីអត្រានុកូលដ្ឋានបន្ថែមថាការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន គឺធ្វើឡើងដោយស្ម័គ្រចិត្ត បន្ទាប់មកទើបត្រូវចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននោះ ខាងលំនៅឋាននារី។ ព័ត៌មាន ឬចំណុចដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ត្រូវបញ្ចូលទៅក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងចុះហត្ថលេខាឬផ្តិតស្នាមមេដៃដោយបុគ្គលដែលមានបំណងធ្វើជាសហព័ទ្ធ និងដោយមានសាក្សីចំនួន ២ (ពីរ) រូបជានីតិជន។[៧៦] នេះមានន័យថា អនាគត ប្តីប្រពន្ធ រួមទាំងសាក្សីដែលឈានដល់នីតិភាពចំនួនពីរនាក់ ត្រូវចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមួយរូប ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះកិច្ចសន្យានោះក្នុងសៀវភៅអាពាហ៍ពិពាហ៍ របស់មេឃុំ សង្កាត់ ហើយភាគីត្រូវផ្តិតមេដៃ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រាលើសៀវភៅនោះផងដែរ។[៧៧]

។នៅពេលដែលសាមីខ្លួនជាអនាគតប្តី និងប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយនោះ និងបានមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួន ប្តី ប្រពន្ធ នោះនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម០១(មួយ)សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួនផងដែរ។[៧៨] **(ឧសម្ព័ន្ធទី១៥ និងទី១៦)**

#### ខ. ការចុះបញ្ជីអាពាហ៍ពិពាហ៍របស់សហព័ទ្ធដែលរស់នៅជាមួយគ្នាបែបអនីតិសង្វាស

[៧៥] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៧០ កថាខណ្ឌទី១។

[៧៦] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៧០ កថាខណ្ឌទី២។

[៧៧] ឥន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រទី ៧៩, ឆ្នាំ២០២១, ភ្នំពេញ។

[៧៨] អនុក្រឹត្យលេខ ១០៣ អនក្រ.បក.ស្តីពីអត្រានុកូលដ្ឋាន, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា ៣១ ។

ពិតណាស់ នៅក្នុងសង្គមបច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរដែលរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្ដីប្រពន្ធ ដោយបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក្ដី និងមិនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក្ដី ប៉ុន្ដែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ គឺនៅតែមានមកដល់បច្ចុប្បន្ន។ ហេតុនេះហើយ ចំពោះប្រជាពលរដ្ឋទាំងឡាយណាដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណី ឬរស់នៅជាមួយគ្នាបែបអនីតិសង្វាសក្ដី អាចធ្វើការប្ដឹងទៅមន្ត្រីអត្រានុកូលដ្ឋានដើម្បីសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលយើងអាចហៅបានថាការរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល ដែលការរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិលនេះត្រូវធ្វើឡើងនៅចំពោះមុខមេឃុំ ឬចៅសង្កាត់នៃទីលំនៅនៃសាមីខ្លួនទាំងពីរស់នៅពិតប្រាកដ។ ចំពោះឯកសារភ្ជាប់ដែលភាគីទាំងពីរចាំបាច់ត្រូវមានដើម្បីសុំចុះបញ្ជីអាពាហ៍ពិពាហ៍ គឺត្រូវធ្វើតាមលំដាប់លំដោយ ដូចទៅនឹងប្រជាពលរដ្ឋដែលមានបំណងរៀបអាពាហ៍ពិពាហ៍ថ្មីនឹងគ្នាដូច្នោះដែរ ពោលគឺត្រូវធ្វើឡើងតាមដំណាក់កាលដូចជា៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ **(ឧបសម្ព័ន្ធទី១)**
- លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ **(ឧបសម្ព័ន្ធទី២)**
- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន (ប្រសិនបើមាន) **(ឧបសម្ព័ន្ធទី៥ និងទី៧)**
- ឬសៀវភៅគ្រួសាររបស់សាមីខ្លួន ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន **(ឧបសម្ព័ន្ធទី៨)**

ដូចគ្នានេះដែរ អំឡុងពេលបិទផ្សាយបណ្ណអាពាហ៍ពិពាហ៍១០ថ្ងៃ បើគ្មានការប្ដឹងជំទាស់ណាមួយលើការរៀបឱ្យអាពាហ៍ពិពាហ៍នេះទេ សាមីខ្លួនទាំងពីរអាចទៅសុំចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់សាមី ដោយនាំសាក្សីពីររូបដែលមានអាយុដល់នីតិភាព និងមានទីលំនៅពិតប្រាកដទៅជាមួយផងដែរ ហើយមន្ត្រីអត្រានុកូលដ្ឋាននឹងចេញសំបុត្រអាពាហ៍ពិពាហ៍ជូនសាមីជនទាំងពីរនាក់។

### ២.៣.៣.២. ការចេញសំបុត្រអាពាហ៍ពិពាហ៍

ក្រោយពេលចុះបញ្ជីអាពាហ៍ពិពាហ៍រួចរាល់ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម១ (មួយ) ច្បាប់ជូនប្ដីប្រពន្ធនោះដោយឥតគិតថ្លៃ។[៧៩]

[៧៩] ច្បាប់ស្ដីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៧១។

បុគ្គលដែលអាចស្នើសុំសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍បានរួមមានៈ[៨០]

ក- សាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍

ខ- ញាតិលោហិតផ្ទាល់នៃសាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍

គ- អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គលខាងលើ ដូចមានចែងក្នុងចំណុច ក និង ខ

ឃ- បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានយល់ឃើញថាបុគ្គលស្នើសុំសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍មិនមែនជាបុគ្គលដែលបានកំណត់នៅក្នុងចំណុចខាងលើ ឬការស្នើសុំនោះត្រូវបានធ្វើឡើងក្នុងគោលបំណងមិនត្រឹមត្រូវដូចជាគោលបំណងធ្វើឱ្យមាននូវផលប៉ះពាល់ភាពឯកជនរបស់សាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍នោះ មន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធសំណើនោះ និងត្រូវផ្តល់មូលហេតុសម្រាប់ការបដិសេធនោះ។[៨១] ចំណែកឯការបដិសេធនេះអាចប្ដឹងមិនសុខចិត្តបាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី១៣(បណ្ដឹងមិនសុខចិត្ត)។[៨២]

អាជ្ញាធរមានសមត្ថកិច្ចឬតុលាការអាចស្នើសុំជាលាយលក្ខណ៍អក្សរនូវសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ឬសម្រង់បញ្ជីអាពាហ៍ពិពាហ៍ ក្នុងករណីដែលមានការចាំបាច់ដើម្បីបំពេញកិច្ចការរបស់ខ្លួនដោយផ្អែកលើច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ ក្នុងករណីដែលមានការស្នើសុំបែបនេះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្តល់ឯកសារដែលបានស្នើសុំឱ្យបានឆាប់រហ័សដោយឥតគិតថ្លៃ។[៨៣]

---

[៨០] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា ៧២ កថាខណ្ឌទី១។

[៨១] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា ៧២ កថាខណ្ឌទី២។

[៨២] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, ផ្នែកទី១៣ បណ្តឹងមិនសុខចិត្ត នៃជំពូកទី២។

[៨៣] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា ៧២ កថាខណ្ឌទី ៣។

- ទម្រង់នៃសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍៖[៩៤]
  - សំបុត្រអាពាហ៍ពិពាហ៍ និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវមានលក្ខណៈសម្គាល់ជានាសុវត្ថិភាព ដើម្បីការពារការក្លែងបន្លំ
  - ទម្រង់នៃសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ **(ឧបសម្ព័ន្ធទី១៥ និងទី១៦)**

នៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋាននោះ ត្រូវមានចុះឈ្មោះរបស់សហព័ទ្ធ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ថ្ងៃខែឆ្នាំចុះសំបុត្រអាពាហ៍ពិពាហ៍ និងទីកន្លែងចុះសំបុត្រអាពាហ៍ពិពាហ៍ផងដែរ។ សំបុត្រអាពាហ៍ពិពាហ៍នេះ ថ្វីត្បិតតែត្រូវការរយៈពេលយូរ និងស៊ាំញ៉ាំទម្រាំតែអាចទទួលបានវាក៏ពិតមែន ប៉ុន្តែវាពិតជាមានសារៈសំខាន់ណាស់ដើម្បីបញ្ជាក់ពីធម្មានុរូបប្ដីប្រពន្ធ ដែលកើតចេញពីអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់យ៉ាងពិតប្រាកដ។[៩៥]

---

[៩៤] ច្បាប់ស្ដីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា ៧៣។

[៩៥] គន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រទី ៧៩, ឆ្នាំ២០២១, ភ្នំពេញ។

# ជំពូកទី៣

# អានុភាពនៃអាពាហ៍ពិពាហ៍

# ជំពូកទី ៣

# អានុភាពនៃអាពាហ៍ពិពាហ៍

បុរស និងនារីដែលបានរៀបអាពាហ៍ពិពាហ៍ ស្របតាមប្រពៃណីនឹងលក្ខខណ្ឌច្បាប់រួចរាល់ហើយនោះ បុគ្គលទាំងពីរនឹងក្លាយជាសហព័ទ្ធនឹងគ្នាយ៉ាងស្របច្បាប់។ ហើយការចុះសំបុត្រអាពាហ៍ពិពាហ៍ គឺធ្វើឱ្យជីវិតរបស់ប្តីប្រពន្ធនោះកាន់តែមានអានុភាពចំពោះមុខច្បាប់។ ចំណែកអានុភាពនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ក៏ត្រូវបានបង្កើតឡើងបន្ទាប់ពីភាគីបុរសនឹងនារីរៀបអាពាហ៍ពិពាហ៍នឹងគ្នារួច ដែលនេះបានកំណត់នូវសិទ្ធិ និងកាតព្វកិច្ច របស់សហព័ទ្ធទាំងពីរ។

យ៉ាងណាមិញ បុរស និងនារីដែលបានសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃអនាគត ឬភាគីដែលបានរៀបអាពាហ៍ពិពាហ៍រួច បុគ្គលទាំងពីរនោះគួរតែជ្រើសរើសនូវការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិមួយដែលបានបញ្ញត្តិដោយច្បាប់។

## ៣.១. ទំនាក់ទំនងគតិយុត្តនៃសាមីប្តីប្រពន្ធ

### ៣.១.១. ការប្រើប្រាស់នាមត្រកូលប្តីប្រពន្ធ

នាសម័យដែលប្រទេសកម្ពុជាបានទទួលឥទ្ធិពលពីវប្បធម៌អឺរ៉ុបមក ប្រជាជនកម្ពុជាមួយចំនួនស្របទៅតាមច្បាប់កំណត់នៅពេលរៀបអាពាហ៍ពិពាហ៍រួច ប្តី ប្រពន្ធ អាចប្រើប្រាស់នាមត្រកូលខាងប្តី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន។[៨៦] ជាគោលការណ៍ ការប្រើប្រាស់នាមត្រកូលខុសៗគ្នានេះ គឺជាការបង្ហាញឱ្យឃើញពីតំណខ្សែរលោហិត និងឫសគល់នៃដូនតាឪពុកម្តាយ ហើយក៏មានតួនាទីសម្គាល់អត្តសញ្ញាណ និងនាមខ្លួនរបស់បុគ្គលនីមួយៗ ទើបការសម្រេចជ្រើសរើសនាមត្រកូលនេះធ្វើឡើងដោយសេរី បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។

ទិដ្ឋភាពជាក់ស្តែងក្នុងសង្គមបច្ចុប្បន្ន គេសង្កេតឃើញថាភាគច្រើនការប្រើប្រាស់នាមត្រកូលនេះ គឺមានតែភាគីខាងប្រពន្ធតែប៉ុណ្ណោះដែលយកនាមត្រកូលរបស់ប្តីមកប្រើ ពិសេសអ្នកដែលមានឋានន្តរសិក្តិខ្ពង់ខ្ពស់។

**ឧទាហរណ៍៖ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន ដែលភរិយារបស់លោកមាននាម សម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន។**

[៨៦] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៦៥។

### ៣.១.២. ករណីយកិច្ចរបស់សហព័ទ្ធ

អាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពផ្លូវកាយផ្លូវចិត្ត និងសេដ្ឋកិច្ចនៃប្តីប្រពន្ធ ដូច្នេះប្តីប្រពន្ធត្រូវរួមរស់ជីវភាពនឹងគ្នា ហើយត្រូវសហការ និងសង្គ្រោះគ្នាទៅវិញទៅមក។[៨៧] ប្តី និងប្រពន្ធ មានករណីកិច្ចស្រឡាញ់ គោរពគ្នា ថែរក្សាគ្នា និងជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល[៨៨] ចេះជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក និងចូលរួមដោះស្រាយបញ្ហាទាំងអស់ជាមួយគ្នា។ នៅក្នុងគ្រួសារមួយប្តីប្រពន្ធក៏ត្រូវមានសិទ្ធិស្មើគ្នាទៅលើគ្រប់ទស្សនៈទាំងអស់ផងដែរ។[៨៩]

### ៣.១.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។[៩០] ចំពោះប្តីប្រពន្ធ គឺមានសិទ្ធសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គមរៀងៗខ្លួន។[៩១] ទោះបីជាការរៀបអាពាហ៍ពិពាហ៍ជាចំណងភ្ជាប់កាតព្វកិច្ចរវាងប្តីប្រពន្ធយ៉ាងណាក៏ដោយ ក៏ប្តីមានសិទ្ធិធ្វើការងារដែលពេញចិត្ត និងប្រពន្ធមានសិទ្ធិរើសយកការងារដែលខ្លួនឯងស្រឡាញ់ ចំណែកឯជំនឿ សាសនាវិញក៏ដូចគ្នាដែរ។ លើសពីនេះការងារទាំងនោះមិនត្រូវមានការបង្ខិតបង្ខំពីសហព័ទ្ធណាម្ខាង ឱ្យសហព័ទ្ធម្ខាងទៀត ធ្វើការងារ ឬលក់ដូរអ្វីមួយដែលគេមិនចង់ធ្វើនោះទេ ហើយការចូលរួមសកម្មភាពនយោបាយ អ្នកទាំងពីរមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសគណបក្សខុសពីគ្នាបានផងដែរ។ ប៉ុន្តែទោះបីជាច្បាប់បានផ្តល់នូវសេរីភាពឱ្យទៅភាគីយ៉ាងណាក្តី ក៏ស្ថានភាពជាក់ស្តែង ប្តីនៅតែមានឥទ្ធិពលលើការសម្រេចចិត្តរបស់ភរិយាជានិច្ច។ **ឧទាហរណ៍៖** ប្តីហាមឃាត់ប្រពន្ធរបស់ខ្លួនមិនឱ្យទៅធ្វើការនៅស្រុកឆ្ងាយពីផ្ទះសម្បែង ទុកឱ្យប្តីជាអ្នកទៅធ្វើការរកប្រាក់ចិញ្ចឹមគ្រួសារវិញ។

### ៣.១.៤ ទំនាក់ទំនងសហព័ទ្ធ និងញាតិ

ក្រោយពីការរៀបអាពាហ៍ពិពាហ៍ចប់សព្វគ្រប់ហើយ គូភាគីនៃអាពាហ៍ពិពាហ៍បានក្លាយទៅជាសហព័ទ្ធ និងបានក្លាយទៅជាសមាជិករបស់គ្រួសារម្ខាងទៀត។ ទោះបីជាសហព័ទ្ធម្ខាងមិនមែនជាសមាជិកដែលកើតចេញពីញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ ក៏សហព័ទ្ធម្ខាងនោះត្រូវតែគោរព ស្រឡាញ់ ឱ្យតម្លៃ

[៨៧] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៦៦។

[៨៨] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា៣០។

[៨៩] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩. មាត្រា២៩។

[៩០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ១៩៩៣, មាត្រា៣៥ កថាខណ្ឌទី១។

[៩១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៦៧។

និងយល់ពីទុក្ខធុរៈរបស់សាច់ញាតិរបស់សហព័ទ្ធម្ខាងទៀតនោះផងដែរ។ ជាងនេះទៅទៀត ការដែលគ្រួសារទាំងសងខាងបានផ្សំផ្គុំឱ្យកូនប្រុសស្រីរៀបអាពាហ៍ពិពាហ៍នឹងគ្នាហើយ ភាគច្រើនឃើញថាលោកមេបាតែងតែផ្ដែផ្ដាំទៅកូនៗឱ្យចេះស្រឡាញ់គ្នា ហើយកូនប្រុសត្រូវចេះជួយថែរក្សាការពារប្អូនផង។ យ៉ាងណាវិញសមាជិកម្នាក់ៗនៅក្នុងគ្រួសារ ត្រូវបង្ការកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ និងត្រូវធ្វើយ៉ាងណាកុំឱ្យកើតមានឡើងនូវការរំលោភសិទ្ធិមនុស្ស[៦២]ជាដាច់ខាត។

### ៣.១.៥. សិទ្ធិ និងករណីកិច្ចរបស់អ្នកមានអំណាចមេបា

ឪពុកម្ដាយគ្រប់រូបត្រូវមានសិទ្ធិ និងករណីកិច្ច បីបាច់ថែរក្សា និងអប់រំកូនៗឱ្យទៅជាកូនល្អ ពលរដ្ឋល្អនៅក្នុងសង្គម។ ចំពោះកូនៗវិញត្រូវមានករណីកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា តាមទំនៀមទម្លាប់ខ្មែរ[៦៣] ដែលចាស់ៗជំនាន់មុនរមែងតែងតែមានប្រសាសន៍ជារឿយៗតគ្នាថា « **ធ្វើបុណ្យទាន់ខែភ្លឺ** »។ ដោយឡែកប្រសិនបើឪពុកម្ដាយនោះបានបង្កើតកូនហើយ មិនបានថែរក្សា ដោយយកកូននោះទៅបោះបង់ចោល ឬយកទៅធ្វើអាជីវកម្ម ឬកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ នោះឪពុកម្ដាយរបស់កូននោះ និងត្រូវបានទទួលខុសត្រូវចំពោះមុខច្បាប់។ រីឯកូនវិញ បើបានប្រព្រឹត្តអំពើល្មើសណាមួយដែលច្បាប់បានហាមឃាត់ទៅលើឪពុកម្ដាយ នោះគេនឹងត្រូវទទួលខុសត្រូវមុខច្បាប់ដូចគ្នា គ្រាន់តែច្បាប់មានបញ្ញត្តិចែងត្រូវផ្ដន្ទាទោស ឬមិនផ្ដន្ទាទោសទៅតាមកម្រិតនៃអាយុរបស់ពួកគេ។

## ៣.២. ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ

យោងទៅតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្នបានបែងចែងប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនេះឡើងជាពីរគឺ **ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា** និង **ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់**។ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ត្រូវចែកចេញជាពីរប្រភេទទៀត គឺ **ទ្រព្យសម្បត្តិដោយឡែក** និង**ទ្រព្យសម្បត្តិរួម**។

### ៣.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺត្រូវទាមទារឱ្យមានការចុះបញ្ជី និងត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីទប់ស្កាត់វិវាទទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីកំណត់អំពីទំនាក់ទំនងសិទ្ធិ និងករណីកិច្ចរបស់ប្ដីប្រពន្ធ ឬការតតាំងចំពោះតតិយជន ដែលមានការពាក់ព័ន្ធណាមួយ។[៦៤] ជាក់ស្ដែងទំនាក់ទំនងប្ដីប្រពន្ធមានលក្ខណៈ

---

[៦២] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៤៣ កថាខណ្ឌទី២។

[៦៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ១៩៩៣, មាត្រា៤៧ កថាខណ្ឌទី២។

[៦៤] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧០។

ច្រើនបែបច្រើនយ៉ាងណាស់ ហើយបញ្ញត្តិនេះផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមស្ថានភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ មួយវិញទៀតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីអនាគតប្តីប្រពន្ធផងដែរ។[៩៥]

ក្នុងក្រមរដ្ឋប្បវេណីក៏បានអនុញ្ញាតឱ្យអ្នកដែលមានបំណងរៀបអាពាហ៍អាពាហ៍ អាចចុះកិច្ចសន្យាលើទ្រព្យសម្បត្តិនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ក៏បានដែរ។ ហើយការចុះកិច្ចសន្យាលើទ្រព្យសម្បត្តិប្តីប្រពន្ធនេះផងដែរ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅ**ក្រសួងយុត្តិធម៌** តាមពាក្យស្នើសុំចុះបញ្ជីរបស់ប្តីប្រពន្ធ ឬបុគ្គលដែលនឹងរៀបអាពាហ៍ពាហ៍ជាមួយគ្នា។

### ៣.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្រៅពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា សហព័ទ្ធដែលមិនបានចុះប្រព័ន្ធកិច្ចសន្យានោះ ត្រូវបានអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

#### ៣.២.២.១. ចំណែកបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកទទួលបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗ។[៩៦] បន្ទុកនេះ គឺជាចំណាយផ្សេងៗនៅក្នុងគ្រួសារដូចជា ថ្លៃឈ្នួលផ្ទះ ការហូបចុក សម្លៀកបំពាក់ ការបង់ថ្លៃទឹក ថ្លៃភ្លើង និងការចិញ្ចឹមកូន។ល។ ដែលបច្ចុប្បន្នបុរស និងនារីភាគច្រើនបានចេញទៅប្រកបការងារទាំងពីរនាក់។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅមាននារីជាភរិយាមួយចំនួនជាស្ត្រីមេផ្ទះដែរ។[៩៧]

#### ៣.២.២.២. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់សហព័ទ្ធម្ខាង ដោយមិនមែនជាកម្មសិទ្ធិរបស់សហព័ទ្ធម្ខាងទៀតទេ។ ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលមានមុនរៀបអាពាហ៍ពិពាហ៍ និងជាទ្រព្យសម្បត្តិដែលបានទទួលក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដោយឡែកដែលទទួលបានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ដូចជា ទទួលបានតាមរយៈ**ប្រទានកម្ម** (ជាកិច្ចសន្យា ដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យទៅភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល)

[៩៥] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០០៩-២០១០, មាត្រា៩៦៩។

[៩៦] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៧១។

[៩៧] ប៊ួយ ធីតា, នីតិរដ្ឋប្បវេណី, ទំព័រទី២៥០, បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០២៤។

**សន្តតិកម្ម** (ជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មរតជនឱ្យទៅសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់) **អច្ច័យទាន** (ជាប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើឱ្យទៅមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមកតសាសន៍) ឬ**ទ្រព្យសម្បត្តិជាតម្លៃតប** (ជាទ្រព្យសម្បត្តិ ដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិ ដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍) ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកខាងលើ។[៦៨] នៅពេលដែលជីវភាពអាពាហ៍ពិពាហ៍បន្តកាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់នោះថា តើជាទ្រព្យដោយឡែក (ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គល) ឬជាទ្រព្យរួម (ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍)ហើយក៏ក្លាយទៅជាវិវាទ។ ដូច្នេះ វាជាការល្អក្នុងការធ្វើជាបញ្ជីទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដើម្បីបញ្ជាក់ឱ្យច្បាស់ជាមុនថា តើទ្រព្យសម្បត្តិណាខ្លះដែលជាទ្រព្យសម្បត្តិដោយឡែក ហើយទ្រព្យសម្បត្តិណាខ្លះទៀតជាទ្រព្យសម្បត្តិរួម។ **ឧទាហរណ៍ទី១៖** លោក **ក** បានទិញរថយន្តទំនើបមួយគ្រឿង កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។ ក្រោយមកនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ លោក **ក** បានរៀបការជាមួយនារី **ខ** ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នានៅពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៅលំនៅដ្ឋានខាងកូនស្រី។ ហេតុនេះរថយន្តទំនើបនោះជាកម្មសិទ្ធិទ្រព្យសម្បត្តិដោយឡែករបស់លោក **ក**។ **ឧទាហរណ៍ទី២៖** ក្រោយពីលោក **ក** បានរៀបការជាមួយនារី **ខ** ហើយ មួយឆ្នាំក្រោយមក ឪពុករបស់លោក **ក** បានប្រគល់ដីមួយកន្លែងខេត្តបាត់ដំបងឱ្យទៅឈ្មោះលោក **ក** ដែលជាកូនបង្កើតរបស់គាត់ មុននិងគាត់ស្លាប់បាត់បង់ជីវិត។ ករណីបែបនេះ ក៏ចាត់ទុកថាជាទ្រព្យសម្បត្តិដោយឡែកផងដែរ។

- **ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិដោយឡែក**

ជាគោលការណ៍ សហព័ទ្ធជាម្ចាស់ទ្រព្យមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដោយសេរី។ ប៉ុន្តែ មាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណីចែងថា៖

១- ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន។

[៦៨] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៧២។

២- ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅលើអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលវត្ថុនោះបានដែរ។

ទន្ទឹមនឹងនេះ គឺខុសប្លែកពីច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ដោយមាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណីបានបង្កើតនូវសិទ្ធិអាស្រ័យនៅ សម្រាប់សហព័ទ្ធនៅលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែក របស់សហព័ទ្ធម្ខាងទៀត។ កាលបើអចលនវត្ថុនោះ ត្រូវបានប្រើប្រាស់សម្រាប់ជាការអាស្រ័យនៅរបស់គ្រួសារ។ មិនតែប៉ុណ្ណោះ សិទ្ធិនេះអាចអះអាងបានចំពោះគ្រប់បុគ្គលទាំងអស់ ទោះបីមានការផ្ទេរសិទ្ធិលើអចលនវត្ថុឱ្យទៅតតិយជនរួចហើយក៏ដោយ។ **ឧទាហរណ៍៖** ក្រោយពីបានរៀបការរួចហើយ លោកស្រី **ចិន្តា** បានមករស់នៅជាមួយនឹងលោក **ដារីត** ជាប្តីរបស់នាង នៅលើផ្ទះដែលជាកម្មសិទ្ធិរបស់លោក **ដារីត**។ ក្នុងករណីនេះមានន័យថា ផ្ទះខាងលើត្រូវបានប្រើប្រាស់សម្រាប់ការអាស្រ័យនៅរបស់គ្រួសារ។ ជាងនេះទៅទៀត រយៈពេល ០៣ (បី) ឆ្នាំ នៃការរួមរស់ជាមួយគ្នា អ្នកទាំងពីរមានកូនបីនាក់។ លុះបានបន្តិចក្រោយមក អ្នកទាំងពីរក៏មានទំនាស់នឹងគ្នា។ នៅទីបំផុតលោក **ដារីត** បានសម្រេចចិត្តលក់ផ្ទះខាងលើទៅឱ្យឈ្មោះ **មុនី**។ ការចាត់ចែងលក់ដូចនៅខាងលើនេះអាចធ្វើបានដោយត្រឹមត្រូវទៅតាមច្បាប់ ពីព្រោះថា ផ្ទះនេះគឺជាទ្រព្យសម្បត្តិដោយឡែករបស់លោក **ដារីត**។ ក៏ប៉ុន្តែ ដរាបណាមិនទាន់មានការលែងលះគ្នាទេ លោកស្រី **ចិន្តា** នៅតែជាសហព័ទ្ធរបស់លោក **ដារីត** ហើយនាងមានសិទ្ធិអាស្រ័យនៅលើផ្ទះនោះ ស្របតាមអត្ថន័យនៃមាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី ពោលគឺ សិទ្ធិរបស់លោកស្រី **ចិន្តា** អាចយកទៅអះអាងចំពោះលោកស្រី **មុនី** បាន។ និយាយមួយបែបផ្សេងទៀតថា ក្រោយពីបានទិញផ្ទះខាងលើរួចហើយ លោកស្រី **មុនី** មិនអាចបណ្តេញលោកស្រី **ចិន្តា** និងកូនរបស់នាងឱ្យចុះចេញពីផ្ទះដោយសំអាងថា នាងមានកម្មសិទ្ធិលើផ្ទះនោះបានឡើយ ពីព្រោះថា បទប្បញ្ញត្តិនៃមាត្រា ៩៧៧ បានផ្តល់សិទ្ធិអាស្រ័យនៅឱ្យលោកស្រី **ចិន្តា** និងកូនៗ ទោះបីជាលោក **ដារីត** បានលក់ផ្ទះនេះឱ្យអ្នកដំទៃហើយក៏ដោយ។

ទោះបីជាយ៉ាងនេះក៏ដោយ សិទ្ធិរបស់លោកស្រី **ចិន្តា** ដូចខាងលើនេះ គួរត្រូវចាត់ទុកថារលត់ នៅពេលដែលលោកស្រី **ចិន្តា** លែងជាសហព័ទ្ធរបស់លោក **ដារីត** តទៅទៀត។[៩៩]

[៩៩] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, ទំព័រ ៣៦៤ និង៣៦៥, បោះពុម្ពលើកទី២, ឆ្នាំ ២០២២។

### ៣.២.២.៣. ប្រព័ន្ធទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលជាទ្រព្យសម្បត្តិដោយឡែក។[១០០]

នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ត្រង់បញ្ញត្តិមាត្រា៣៣ បានចែងថា ទ្រព្យសម្បត្តិរួម គឺជាអ្វីៗទាំងអស់ដែលសហព័ទ្ធទាំងពីររកបានជាមួយគ្នា ឬសហព័ទ្ធណាម្នាក់រកបានក្នុងរយៈពេលនៃចំណងអាពាហ៍ពិពាហ៍។ **ឧទាហរណ៍៖** លោក **ក** បានរៀបការជាមួយនារី **ខ** នៅពេលរៀបអាពាហ៍ពិពាហ៍ ដីតារបស់លោក **ក** បានប្រគល់ដីមួយកន្លែង ជាចំណងដៃក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ដល់កូនទាំងពីរ នេះត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិរួម។

- **ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិរួម**

ជាគោលការណ៍នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា៩៧៤ បានចែងថា៖

១- ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗមានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រង ទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។

២- សហព័ទ្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។

៣- សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។

៤- បើការពិភាក្សាអំពីការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។

**ឧទាហរណ៍៖** លោក **ក** បានទិញដីមួយកន្លែងក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ជាមួយនារី **ខ** ដោយលោក **ក** បានដាក់ឈ្មោះរបស់ខ្លួនក្នុងការចុះបញ្ជីកម្មសិទ្ធិលើដីមួយកន្លែងនោះ តែនារី **ខ** មិនយល់ព្រម នាងក៏ទាមទារទៅតុលាការដើម្បីឱ្យតុលាការជួយសម្រេចសេចក្តីឱ្យនាង។

- **ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ**

[១០០] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៣។

ការចាត់ចែងអ្វីមួយនៅក្នុងទ្រព្យសម្បត្តិរួម គឺត្រូវមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង។ ប្រសិនបើមិនមានការយល់ព្រមនោះទេ ទ្រព្យសម្បត្តិប្ដីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបានទេ។

ប៉ុន្តែប្រសិនបើមានស្ថានភាពចាំបាច់មិនអាចជៀសវាងណាមួយបាននោះ សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅ នោះប្ដីប្រពន្ធណាម្ខាង អាចលក់ ឬធ្វើការចាត់ចែងផ្សេងៗទៀតនូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ។

ក្នុងករណីដែលប្ដី ឬប្រពន្ធណាម្ខាងបានលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និងគ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រម អាចប្ដឹងទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការនៅក្នុងអំឡុងពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ និង នៅក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង[១០១]។ **ឧទាហរណ៍**៖ លោក **ក** បានរៀបការជាមួយនារី **ខ** ហើយពួកគេទាំងពីរនាក់ក៏បានទិញផ្ទះមួយល្វែងនៅខេត្តបាត់ដំបងជាមួយគ្នា ដែរនេះជាទ្រព្យសម្បត្តិរួម។ ក្រោយមកអ្នកស្រី **ខ** ក៏បានទៅរៀនបន្តនៅបរទេស ហើយលោក **ក** ក៏បានសម្រេចចិត្តលក់ផ្ទះនោះទៅឱ្យលោកស្រី **គ** ដោយមិនបានសុំការអនុញ្ញាតពីអ្នកស្រី **ខ** នោះទេ។ ដូច្នេះហើយ ផ្ទះល្វែងនោះគឺជាអចលវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ ហេតុនេះលោកស្រី **ខ** អាចប្ដឹងទាមទារទៅតុលាកាឱ្យលុបចោលនូវការចាត់ចែងនោះ រហូតដល់ទៅ ០២ (ពីរ) ឆ្នាំ គិតពីថ្ងៃដែលលោកស្រី **ខ** បានដឹងអំពីការលក់នោះ។

ការប្រព្រឹត្តទៅនៃជីវភាពរស់នៅ អាចធ្វើឱ្យប្ដីប្រពន្ធមានកាតព្វកិច្ច (បំណុល)។ ដូចនេះក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានដាក់បន្ទុកថាតើបំណុលណាខ្លះ ដែលត្រូវធ្លាក់ជាការទទួលខុសត្រូវរួមគ្នា (ដោយសាមគ្គី)។ បំណុលទាំងនោះមានជាអាទិ៍៖

- សោហ៊ុយហូបចុក ស្លៀកពាក់ ស្នាក់នៅ។
- សោហ៊ុយដើម្បីការអប់រំ ឬព្យាបាល ថែទាំកូន។
- បំណុលដែលប្ដី និងប្រពន្ធបានធ្វើកិច្ចសន្យាជាមួយម្ចាស់បំណុលក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
- បំណុលដែលប្ដី ឬប្រពន្ធម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬប្ដីម្ខាងទៀតក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

[១០១] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៦។

- សោហ៊ុយដើម្បីគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរួម។
- បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។

ករណីខាងលើអាចលើកលែងបាន ប្រសិនបើមានស្ថានភាពមិនអាចចៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីថែរក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាងអាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនៅទ្រព្យសម្បត្តិរួមបាន ដោយគ្មានការអនុញ្ញាតពីតុលាការ។ ក្នុងករណីដែលសហព័ទ្ធណាតែម្ខាងធ្វើការចាត់ចែងទ្រព្យសម្បត្តិរួមដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬមិនមានការអនុញ្ញាតពីតុលាការទេនោះ សហព័ទ្ធម្ខាងទៀតនោះអាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបានក្នុងអំឡុងពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងពីការចាត់ចែងទ្រព្យនោះ បើទ្រព្យនោះជាអចលនវត្ថុ។ ប៉ុន្តែបើទ្រព្យនោះជាចលនវត្ថុវិញមានអំឡុងពេល ០១ (មួយ) ឆ្នាំ ប៉ុណ្ណោះ គិតចាប់ពីពេលដែលបានដឹង។[១០២]

## ៣.៣. មោឃភាពនៃអាពាហ៍ពិពាហ៍

**អាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកជាមោឃៈ៖** ក្នុងករណីគូភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមានមូលហេតុផ្សេងទៀត។[១០៣]

**អាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកជាមោឃៈ៖** ក្នុងករណីគូភាគីមិនបានបំពេញតាមបែបបទច្បាប់ ដូចជាការដែលគូភាគីមិនបានធ្វើការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មិនបានជូនដំណឹងជាសាធារណៈ មិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាដើម។ ប៉ុន្តែ ប្រសិនបើមានវិការៈលើនីតិវិធីតែបន្តិចបន្តួចនោះ អានុភាពនៃអាពាហ៍ពិពាហ៍មិនត្រូវបានរារាំងឡើយ។[១០៤]

### ៣.៣.១. មូលហេតុនៃការមោឃភាពអាពាហ៍ពិពាហ៍

#### ៣.៣.១.១. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុភាន់ច្រឡំលើមនុស្ស

ក្នុងករណីដែលភាគីម្ខាងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភាគីម្ខាងទៀតរួចទៅហើយនោះ ប៉ុន្តែអាពាហ៍ពិពាហ៍នោះបែរជាត្រូវមានការភាន់ច្រឡំលើ ឈ្មោះ ឬលើភាន់ច្រឡំទៅលើ រូបរាងទៅវិញ។ ការភាន់ច្រឡំលើអត្តសញ្ញាណរបស់មនុស្សដែលជាកម្មវត្ថុដ៏សំខាន់បែបនេះ ភាគីមានសិទ្ធិអាចស្នើសុំរំលាយកិច្ចសន្យា

[១០២] ប៊ួយ ធីតា, នីតិរដ្ឋប្បវេណី, ទំព័រទី ២៥២, បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០២៤។

[១០៣] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥៨ កថាខណ្ឌ ក។

[១០៤] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥៨ កថាខណ្ឌ ខ។

អាពាហ៍ពិពាហ៍នោះបាន។ **ឧទាហរណ៍៖** បុរស **ក** បានរៀបអាពាហ៍ជាមួយនារី **ខ** ដោយមានការភាន់ច្រឡំទៅលើរូបរាង ព្រោះថា នារី **ខ** ជាកូនភ្លោះ។

ការរៀបអាពាហ៍ពាហ៍ដែលគ្មានឆន្ទៈជាមួយមនុស្សដែលខ្លួនឯងមិនបានស្រឡាញ់ ដោយមូលហេតុភាគីម្ខាងទៀតជាកូនភ្លោះ មានមុខមាត់ដូចគ្នានោះ ភាគីដែលមានការយល់ច្រឡំ អាចដាក់ពាក្យស្នើសុំរំលាយកិច្ចសន្យាបាន។

ប៉ុន្តែប្រសិនបើការភាន់ច្រឡំទៅអត្តចរិក ឬអកប្បកិរិយារបស់មនុស្សទៅវិញនោះ គឺការភាន់ច្រឡំបែបនេះភាគីមិនអាចសុំមោឃភាពនៃអាពាហ៍ពិពាហ៍បាននោះទេ។ **ឧទាហរណ៍៖** បុរស **ក** បានភាន់ច្រឡំទៅលើនារី **ខ** ថាមានទឹកចិត្តល្អ ស្លូតបូត ជានារីដែលមានចរិយាល្អ។ ក្រោយរៀបអាពាហ៍ពិពាហ៍រួចហើយ នារីនោះបែរជាមានចិត្តមិនល្អទៅវិញ ខុសប្លែកពីមិនទាន់រៀបអាពាហ៍ពិពាហ៍កាលដំបូង។

ករណីនេះភាគីមានការយល់ច្រឡំ មិនអាចស្នើសុំរំលាយកិច្ចសន្យាបានទេ។

### ៣.៣.១.២ ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុការបង្ខិតបង្ខំ

ការបង្ខិតបង្ខំ គឺជាស្ថានភាពមួយដែលបុគ្គលនោះត្រូវបានគេបង្ខំ ដោយសាមីខ្លួនមិនបានបង្ហាញឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងដោយសារស្ថានភាពនៃការបង្ខំនោះ ក្នុងករណីនេះអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាមោឃៈ។ **ឧទាហរណ៍៖** បុរស **ក** មានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយនារី **ខ** ដែលជាសង្សារ។ ប៉ុន្តែឪពុកម្តាយរបស់បុរស **ក** មិនយល់ព្រម ហើយតែងតែស្តីបន្ទោស និងបានប្រើវិធីសាស្ត្រគ្រប់យ៉ាងឱ្យបុរស **ក** ទៅរៀបការជាមួយ នារី **គ** ដែលខ្លួនមិនបានស្រឡាញ់ និងបានបង្ខំឱ្យបុរស **ក** ចុះសំបុត្រអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានទៀតផង។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍កើតឡើងរវាងបុរស **ក** និងនារី **គ** ត្រូវបានចាត់ទុកជាមោឃៈ ដោយមូលហេតុ **ក** គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

### ៣.៣.១.៣. ភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយមូលហេតុផ្សេងទៀត

ក្រៅពីអាពាហ៍ពិពាហ៍ដោយការភាន់ច្រឡំ ឬការបង្ខិតបង្ខំ ក៏មានមូលហេតុផ្សេងទៀតដែលត្រូវចាត់ទុកថា ជាមោឃៈផងដែរដូចជា ក្នុងករណីការរៀបអាពាហ៍ពិពាហ៍ដើម្បីទទួលបានសញ្ជាតិជាដើម។ **ឧទាហរណ៍៖** លោក **ក** ព្រោះតែចង់បានសញ្ជាតិទៅរស់នៅបរទេសក៏បានបង្កើតអាពាហ៍ពិពាហ៍ជាមួយនារី **ខ** (ជាជនជាតិបរទេស) ទាំងដែរលោក **ក** មានសង្សារទៅហើយ ហើយលោក **ក** បានគិតថាពេលទទួលបានសញ្ជាតិរួចលោក និងលែងលះគ្នាជាមួយនារី **ខ** រួចលោកនឹងត្រលប់មកយកសង្សាររបស់ខ្លួនទៅរស់នៅប្រទេសគេវិញ។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាងលោក **ក** និងនារី **ខ** ត្រូវបានចាត់ទុកថាជាមោឃៈ ដោយមូលហេតុលោក **ក** គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

### ៣.៣.១.៤. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ប្រសិនបើភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅឃុំ សង្កាត់ដែលបុរស ឬនារីនោះនៅរស់ទេនោះ អ្នកមានសិទ្ធិមោឃភាពអាចស្នើសុំមោឃភាពបាន ឬក៏មិនស្នើសុំមោឃភាពអាពាហ៍ពិពាហ៍ក៏បានដែរ។ **ឧទាហរណ៍៖** បុរស **ក** និងនារី **ខ** បានរួមរស់ជាមួយគ្នាជាអនីតិសង្វាស ដោយនារី **ខ** ចង់រៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ នាងក៏បានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តែម្នាក់ឯង ហើយចុងក្រោយមន្ត្រីអត្រានុកូលដ្ឋានក៏បានចុះឈ្មោះ បុរស **ក** និងនារី **ខ** ជាប្តីប្រពន្ធស្របច្បាប់ក្នុងបញ្ជីអាពាហ៍ពិពាហ៍ ដោយគ្មានហត្ថលេខារបស់បុរស **ក** នោះទេ។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាងបុរស **ក** និងនារី **ខ** ត្រូវចាត់ទុកជាមោឃៈដោយមូលហេតុបុរស **ក** មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាអាទិ៍ ហេតុនេះ ច្បាប់មិនទទួលស្គាល់ការចុះឈ្មោះបុរស **ក** នៅក្នុងបញ្ជីអាពាហ៍ពិពាហ៍នោះឡើយ។

### ៣.៣.១.៥. ភាគីមិនបានជូនដំណឹងជាសាធារណៈ

នៅពេលភាគីទាំងសងខាង ទទួលបានការអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ដោយមន្ត្រីអត្រានុកូលដ្ឋានរួចហើយ ប៉ុន្តែគូភាគីមិនបានបិទប័ណ្ណប្រកាសរៀបអាពាហ៍ពិពាហ៍ដូចការកំណត់របស់ច្បាប់ គឺរយៈពេល ១០ ថ្ងៃ នៅមុនពេលរៀបអាពាហ៍ពិពាហ៍នោះទេ ការខកខានប្រកាសដំណឹងនេះ អ្នកមានសិទ្ធិមោឃភាពអាចស្នើសុំមោឃភាពបាន។ **ឧទាហរណ៍៖** បុរស **ក** និងនារី **ខ** បានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍រួចហើយ ហើយមេឃុំចៅសង្កាត់ខាងនារីក៏បានចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ឱ្យទៅ បុរស និងស្ត្រីដែលត្រូវរៀបការនាថ្ងៃខាងមុខយកទៅបិទផ្សាយតាមនីតិវិធីច្បាប់។ ប៉ុន្តែភាគីខាងបុរស **ក** មិនបានបិទផ្សាយតាមការកំណត់នោះទេ។

### ៣.៣.១.៦. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ហើយ នឹងចាត់ទុកជាការត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយមានសាក្សីពេញនីតិភាព ០២ (ពីរ) នាក់ ផងដែរ។ ប្រសិនបើភាគីមិនបានបំពេញតាមនីតិវិធីទេ អ្នកមានសិទ្ធិមោឃភាពអាចស្នើសុំមោឃភាពបាន។ **ឧទាហរណ៍៖** បុរស **ក** និងនារី **ខ** បាននាំគ្នាទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ដោយមានសាក្សីពេញវ័យចំនួន ០២ (ពីរ) រូប ក្នុងពេលការចុះកិច្ច

សន្យាអាពាហ៍ពិពាហ៍ ដោយសាក្សីទី១ឈ្មោះ **គ** ភេទប្រុស និងសាក្សីទី២មានឈ្មោះ **ឃ** ភេទស្រី។ មន្ត្រីអត្រានុកូលដ្ឋានក៏បានចុះឈ្មោះសាក្សីទី១ឈ្មោះ **គ** ក្នុងក្រឡោនឈ្មោះភាគីនៃអាពាហ៍ពិពាហ៍ ដែលតាមពិតបុរស **គ** មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទេ។

ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាងនារី **ខ** និងបុរស **គ** ត្រូវបានចាត់ទុកជាមោឃៈ ពីព្រោះបុរស **គ** មិនបានដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ជាអាទិ៍។

**ឧទាហរណ៍៖** ភាគីបុរស **ក** កើតថ្ងៃទី២៤ ខែមិថុនា ២០០១ និងភាគីខាងនារី **ខ** កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០១ ប៉ុន្តែមន្ត្រីអត្រានុកូលដ្ឋានបានចុះថ្ងៃខែឆ្នាំកំណើតរបស់ភាគីខាងបុរសខុស ដោយចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០១។

ការចុះឈ្មោះ ខុសអក្ខរាវិរុទ្ធ ឬខុសថ្ងៃខែឆ្នាំកំណើត ត្រូវបានចាត់ទុកថា ជាវិការៈបន្តិចបន្តួចក្នុងនីតិវិធី ហេតុនេះ មិនបានធ្វើឱ្យអាពាហ៍ពិពាហ៍ត្រូវបានមោឃភាពនោះទេ ក្នុងករណីនេះអាពាហ៍ពិពាហ៍មានអានុភាព។

#### ៣.៣.១.៧. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍

នៅពេលដែលសហព័ទ្ធទាំងពីរបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ហើយក្តី ក៏ប៉ុន្តែពួកគេមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ នៅក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់មន្ត្រីអត្រានុកូលដ្ឋានទេនោះ អ្នកមានសិទ្ធិមោឃភាពអាចស្នើសុំមោឃភាពបាន។

### ៣.៣.២. អ្នកដែលមានសិទ្ធិមោឃភាពអាពាហ៍ពិពាហ៍

ដោយយោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា២៦ អ្នកដែលមានសិទ្ធិទាមទារឱ្យមោឃភាពអាពាហ៍ពិពាហ៍ មានតែសហ័ពទ្ធ រដ្ឋអាជ្ញា និងជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍នេះទេ ទើបអាចដាក់ពាក្យប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន។ ចំណែកឯក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ គឺពុំបានចែងបញ្ញត្តិអំពីអ្នកមានសិទ្ធិធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍នោះទេ អាចបកស្រាយបានថា ជនណាក៏អាចធ្វើបានផងដែរ។

**ឧទាហរណ៍៖** បុរស **ក** និងនារី **ខ** បាននាំគ្នាទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ដោយមានសាក្សីចំនួន ០២ (ពីរ) រូប នៅក្នុងពេលការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ សាក្សីទី១ឈ្មោះ **គ** ភេទប្រុស និងសាក្សីទីឈ្មោះ **ឃ** ភេទស្រី។ មន្ត្រីអត្រានុកូលដ្ឋានក៏បានចុះឈ្មោះសាក្សីទី១ឈ្មោះ **គ** ក្នុងក្រឡោនឈ្មោះភាគីនៃអាពាហ៍ពិពាហ៍ ដែលតាមពិតបុរស **គ** មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទេ។

ក្នុងករណីនេះ អ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធជានារី ខ គឺនារី ខ អាចធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពអាពាហ៍ពិពាហ៍ ដើម្បីអាចរៀអាពាហ៍ពិពាហ៍ថ្មីបាន។

### ៣.៣.៣. អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍

ប្រសិនបើអាពាហ៍ពិពាហ៍មោឃៈ អាពាហ៍ពិពាហ៍មិនមានអានុភាពទាល់តែសោះ ចាប់តាំងពីពេលបង្កើតអាពាហ៍ពិពាហ៍មក។ ដូចនេះ បណ្តឹងនៅតុលាការ គឺគ្រាន់តែជាបណ្តឹងទាមទារឱ្យបញ្ជាក់ពីមោឃភាពអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ មិនមែនជាបណ្តឹងទាមទារមោឃភាពអាពាហ៍ពិពាហ៍ឡើយ។ មួយវិញទៀត បណ្តឹងទាមទារឱ្យបញ្ជាក់ពីមោឃភាពនៃអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងដោយអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុង ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដោយតុលាការសម្រេចចេញជា **សាលក្រម**។ យ៉ាងណាមិញសម្រាប់បណ្តឹងប្រភេទនេះ ក្រមរដ្ឋប្បវេណីមិនបានកម្រិតពីបុគ្គលដែលអាចប្តឹងបាន និង អំឡុងពេលអាជ្ញាយុកាល (រយៈពេលមួយដែលកំណត់ដោយច្បាប់) ឡើយ។ ហេតុដូចនេះ អាចមានការទាមទារបកស្រាយថា

គ្រប់ជនដែលមានប្រយោជន៍សុទ្ធតែអាចប្តឹងទាមទារឱ្យមោឃភាពអាពាហ៍ពិពាហ៍បានទាំងអស់ ដោយពុំមានកម្រិតអំឡុងពេលអាជ្ញាយុកាលឡើយ។[១០៥]

## ៣.៤. ការលុបចោលនៃអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវ មិនស្របច្បាប់ ឬអាពាហ៍ពិពាហ៍នោះធ្វើផ្ទុយពីលក្ខន្តិកៈនៃការរៀបអាពាហ៍ពិពាហ៍របស់ច្បាប់។ ការលុបចោលអាពាហ៍ពិពាហ៍ត្រូវយោងតាមទៅតាមបញ្ញត្តិដែលបានចែង ព្រោះជាការធ្វើឱ្យប៉ះពាល់ជាខ្លាំងទាំងផ្លូវកាយ ផ្លូវចិត្ត និងកិត្តិយសដល់គូភាគី ឪពុកម្តាយ និងញាតិសន្តានទាំងសងខាងទៀតផង។

### ៣.៤.១. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍

#### ៣.៤.១.១. អាពាហ៍ពិពាហ៍របស់ជនមិនទាន់គ្រប់អាយុរៀបការ

ជាគោលការណ៍ ដើម្បីរៀបអាពាហ៍ពិពាហ៍បានទាល់តែ បុរស និងនារី ដល់នីតិភាព (គ្រប់អាយុ១៨ឆ្នាំ) ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែប្រសិនបើភាគីម្ខាងមានអាយុ ១៨ឆ្នាំ ហើយភាគីម្ខាងទៀតមានអាយុ

[១០៥] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, ទំព័រ ៣៣៤, បោះពុម្ពលើកទី២, ឆ្នាំ ២០២២។

មិនតិចជាង ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានដោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។[១០៦]

- **អាជ្ញាយុកាលនៃការសុំលុបចោលនូវអាពាហ៍ពិពាហ៍៖** គឺសម្រាប់ជនណាដែលមិនទាន់ដល់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ ជននោះក៏នៅតែអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ ក្នុងអំឡុងពេល ០៣ (បី) ខែ ចាប់ពីពេលជននោះបានគ្រប់អាយុ។ លើកលែងតែក្នុងអំឡុងពេលនេះ បុគ្គលនោះបានធ្វើសច្ចានុម័ត បន្ទាប់ពីគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ។[១០៧] **ឧទាហរណ៍១៖** លោក **ក** មានអាយុ១៧ឆ្នាំ និងនារី **ខ** មានអាយុ ១៦ឆ្នាំ ពួកគេបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយលួចលាក់មិនឱ្យឪពុកម្តាយអ្នកទាំងពីរដឹងនោះទេ។ ក្រោយរៀបការបាន ០២ (ពីរ) ខែ ស្រាប់តែឪពុកម្តាយរបស់ពួកគេបានដឹង ហើយបានទៅប្តឹងទៅតុលាការដើម្បីឱ្យលុបចោលអាពាហ៍ពិពាហ៍នោះ។ **ឧទាហរណ៍២៖** បុរស **ក** មានអាយុ ១៨ឆ្នាំ និង **ខ** មានអាយុ ១៧ឆ្នាំ នៅពេលឪពុកម្តាយរបស់ **ក** បានប្តឹងទៅតុលាការ ពេលនោះ **ក** បដិសេធពាក្យបណ្តឹងរបស់ឪពុកម្តាយលោក ដោយគេចង់រក្សាចំណងអាពាហ៍ពិពាហ៍នោះទុកនៅដដែល។

### ៣.៤.១.២. ទ្វេពន្ធភាព

អាពាហ៍ពិពាហ៍ធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ។[១០៨] បុគ្គលដែលមានប្តី ឬប្រពន្ធរួចហើយ ដោយអាពាហ៍ពិពាហ៍មុននៅតែមានសុពលភាពនៅឡើយ ហើយបុគ្គលប្តី ឬប្រពន្ធនោះបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត ក្នុងករណីនេះបុគ្គលនោះត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព ហើយអ្នកដែលសមគំនិតនៅក្នុងរឿងនេះ ក៏ត្រូវមានទោសដូចគ្នាផងដែរ។[១០៩] អ្នកមានសិទ្ធិលុបចោល អាចស្នើសុំលុបចោលអាពាហ៍ពិពាហ៍នោះបាន។

ចំពោះអាពាហ៍ពិពាហ៍ដែលជាប់ក្នុងបទទ្វេពន្ធភាព បុគ្គលដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិនេះ ត្រូវជាប់ទោសព្រហ្មទណ្ឌដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ខែ ដល់ ០១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ។

[១០៦] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤៨។

[១០៧] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៦១។

[១០៨] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ២៤ កញ្ញា ឆ្នាំ១៩៩៣, មាត្រា៤៥។

[១០៩] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ០១ កញ្ញា ២០០៦, មាត្រា៤។

#### ៣.៤.១.៣. អាពាហ៍ពិពាហ៍ខាងញាតិលោហិត

បុរស និងនារី ជាភាគីនៃអាពាហ៍ពិពាហ៍ដែលបានដល់នីតិភាពហើយក្តី ក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ប្រសិនបើភាគីទាំងសងខាងជាញាតិលោហិតខ្សែផ្ទាល់ ឬសាខាញាតិលោហិត ក្នុង ០៣ (បី) ថ្នាក់រាប់ទាំងថ្នាក់ទី ០៣ (បី) ផង។[១១០] ម្យ៉ាងវិញទៀត ការបញ្ចប់ញាតិភាពរវាងឪពុកម្ដាយចិញ្ចឹម ចំពោះកូនសុំពេញលេញ ឬកូនសុំធម្មតា ក៏ច្បាប់ហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍នោះដែរ។ ទោះបីមានការកាត់ផ្ដាច់នូវទំនាក់ទំនងរវាងកូនសុំ និងឪពុកម្ដាយបង្កើតកូនសុំពេញលេញក៏ដោយ ក៏ទំនាក់ទំនងខ្សែលោហិតតាមធម្មជាតិមិនត្រូវបានកាត់ផ្ដាច់ឡើយ។ **ឧទាហរណ៍៖** ការរៀបអាពាហ៍ពិពាហ៍រវាងឪពុកម្ដាយ និងកូនបង្កើត ឬឪពុកម្ដាយចិញ្ចឹម និងកូនសុំ ហើយទោះបីក្នុងករណីមានការបញ្ចប់នូវទំនាក់ទំនងរវាងឪពុកម្ដាយ និងកូនបង្កើត ឬការកាត់កាល់ឪពុកម្ដាយចិញ្ចឹម និងកូនសុំហើយ ក៏អាពាហ៍ពិពាហ៍ទាំងអស់នេះត្រូវបានលុបចោលផងដែរ។[១១១]

#### ៣.៤.១.៤. អាពាហ៍ពិពាហ៍ខាងញាតិពន្ធ

ក្នុងក្រមរដ្ឋប្បវេណីបានចែងបញ្ញត្តិ អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់ និងអាពាហ៍ពិពាហ៍ពុំអាចធ្វើឡើងរវាងសាខាញាតិពន្ធ នៅក្នុង ០៣ (បី) ថ្នាក់រាប់ទាំងថ្នាក់ទី ០៣ (បី) ផងដែរ។[១១២] ប៉ុន្តែប្រសិនបើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ០៣ (បី) ថ្នាក់បាន។[១១៣] ដូច្នេះការៀបអាពាហ៍ពិពាហ៍ធ្វើឡើងរវាងឪពុកក្មេក ឬម្ដាយក្មេក ជាមួយនិងកូនប្រសារ បងថ្លៃ ជាមួយនិងប្អូនថ្លៃ -ល- ទាំងនេះនឹងត្រូវបានលុបចោល។ **ឧទារហណ៍៖** លោក **ក** បានរៀបអាពាហ៍ពិពាហ៍និងបានចុះបញ្ជីអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយ នារី **ខ** រហូតទទួលបានចំណងដៃកូនប្រុសម្នាក់។ ក្រោយមកនារី **ខ** មានជម្ងឺយ៉ាងធ្ងន់ធ្ងរដោយមិនអាចសង្គ្រោះជីវិតបាន។ ពិធីបុណ្យសព្វក៏កន្លងផុតទៅអស់រយៈពេលមួយឆ្នាំ លោក **ក** ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនារី **គ** ដែលជាប្អូនបង្កើតរបស់នារី **ខ**។ ក្នុងករណីនេះច្បាប់មានការលើកលែងដោយអនុញ្ញាតឱ្យលោក **ក** និងនារី **គ** អាចមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន ដើម្បីឱ្យអ្នកទាំងពីរមើលថែកូនរបស់បុគ្គលដែលបានទទួលមរណភាពទៅហើយនោះ។

---

[១១០] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា៩៥១។

[១១១] គន យឿន, សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ១, ទំព័រទី ៩៨, ឆ្នាំ២០២១, ភ្នំពេញ។

[១១២] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥២។

[១១៣] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥២ ចំណុចទី២ វាក្យខណ្ឌទី៣។

### ៣.៤.១.៥. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

នៅក្នុងករណីដែលអាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់ដោយមរណភាព លែងលះ ឬមោឃភាព នៃអាពាហ៍ពិពាហ៍នោះ បុរសម្នាក់អាចរៀបអាពាហ៍ពិពាហ៍ថ្មីម្តងទៀតនៅពេលណាក៏បាន ក្រោយការបញ្ចប់អាពាហ៍ពិពាហ៍មុន។ ដោយឡែក នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ក៏ប៉ុន្តែត្រូវស្ថិតក្នុងភាពជាស្ត្រីមេម៉ាយរយៈពេល ៣០០ (បីរយ) ថ្ងៃ គិតពីពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ដោយមូលហេតុប្តីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមដែលតុលាការសម្រេចពីមោឃភាពអាពាហ៍ពិពាហ៍ ឬពីថ្ងៃដែលប្រកាសសាលក្រមស្ថាពរ នៃការលែងលះ។[114] ទោះជាយ៉ាងណាក្តី ក្រមរដ្ឋប្បវេណីបច្ចុប្បន្ននេះ បានកែប្រែរយៈពេលនៃការហាមឃាត់រៀបអាពាហ៍ពិពាហ៍ថ្មីមកត្រឹមតែ ១២០ (មួយរយម្ភៃ) ថ្ងៃ តែប៉ុណ្ណោះ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។[115]

ច្បាប់តម្រូវឱ្យស្ត្រីរង់ចាំរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃនេះ គឺដើម្បីកំណត់បិតុភាពនៃកូនដែលកើតមកនៅក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ចាស់នេះ។ ការកំណត់រយៈពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីនេះ គឺដើម្បីចៀសវាងការប្រកួតប្រជែងទាក់ទងទៅនឹងការសន្មតបិតុភាពរបស់កូន មានន័យថា តើកូនដែលកើតមកគួរត្រូវសន្មតថាជាកូនរបស់ប្តីមុន ឬប្តីក្រោយ។

- **អាជ្ញាយុកាលនៃការសុំលុបចោលរូវអាពាហ៍ពិពាហ៍៖** សម្រាប់នារីដែលអាពាហ៍ពិពាហ៍ចាស់មិនទាន់រំលាយ ឬលុបចោល រយៈពេលនៃការប្តឹងសុំលុបអាពាហ៍ពិពាហ៍ក្រោយនេះមានរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនបានរំលាយ ឬលុបចោល។ ករណីលើកលែងប្រសិនបើនារីនោះមានផ្ទៃពោះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។

### ៣.៤.១.៦. អាពាហ៍ពិពាហ៍ដោយការឆបោក

អាពាហ៍ពិពាហ៍រវាងគូស្រករទាំងពីរនាក់កើតឡើងដោយការឆបោករបស់ភាគីម្ខាង ឬតតិយជនបានប្រើប្រាស់មធ្យោបាយបោកបញ្ឆោត ទៅភាគីម្ខាងទៀតឱ្យមានការភាន់ច្រឡំ និងយល់ព្រមរៀបការជាមួយ នោះភាគីដែលត្រូវបានភាគីម្ខាងទៀតបោកបញ្ឆោតអាចស្នើសុំទៅតុលាការឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។[116]

[114] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យ/ច្បាប់/លេខ៥៦/ក្រ, ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ១៩៨៩, មាត្រា ៩។

[115] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥០ ចំណុចទី១។

[116] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៦៣ កថាខណ្ឌទី១។

- **អាជ្ញាយុកាលនៃការសុំលុបចោលរូវអាពាហ៍ពិពាហ៍៖** សម្រាប់អាពាហ៍ពិពាហ៍ដោយការឆបោកនេះត្រឹមតែ ០៣ (បី) ខែតែប៉ុណ្ណោះ ចាប់តាំងពីពេលដែលភាគីបានរកឃើញការឆបោកនោះ។ ការដែលផុតរយៈពេលនេះ ភាគីដែលមានសិទ្ធិប្ដឹងមិនបានប្ដឹងសុំលុបចោលអាពាហ៍ពិពាហ៍ទេ ឬសុខចិត្តទទួលស្គាល់អាពាហ៍ពិពាហ៍ដោយការឆបោកនោះ សិទ្ធិប្ដឹងសុំឱ្យលុបអាពាហ៍ពិពាហ៍ត្រូវបានរលត់ហើយ។

#### ៣.៤.១.៧. អាពាហ៍ពិពាហ៍ដោយការគំរាមកំហែង

អាពាហ៍ពិពាហ៍ដែលកើតចេញពីការគំរាមកំហែងរបស់ភាគីណាម្ខាង ឬតតិយជនតាមគ្រប់មធ្យោបាយដែលធ្វើឱ្យភាគីម្ខាងទៀតភិតភ័យ និងសុខចិត្តទទួលយកការរៀបអាពាហ៍ពិពាហ៍ដោយខុសពីឆន្ទៈរបស់ខ្លួន នោះភាគីដែលត្រូវបានភាគីម្ខាងទៀតប្រើប្រាស់ការគំរាមកំហែង អាចស្នើសុំទៅតុលាការដើម្បីលុបចោលអាពាហ៍ពិពាហ៍នោះបាន។

- **អាជ្ញាយុកាលនៃការសុំលុបចោលរូវអាពាហ៍ពិពាហ៍៖** ការគំរាមកំហែង មានរយៈកំណត់ពេលដូចទៅនឹងសិទ្ធិស្នើសុំលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោកដែរ គឺមានរយៈពេល ០៣ (បី) ខែ។

**ទណ្ឌកម្មនៃការមិនគោរពលក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍**[១១៧]

| មោឃភាពនៃអាពាហ៍ពិពាហ៍ | ការលុបចោលអាពាហ៍ពិពាហ៍ |
|---|---|
| ➢ ភាពផ្ទុយច្បាប់កម្រិតខ្ពស់ដែលនឹងធ្វើឱ្យអាពាហ៍ពិពាហ៍ គឺពុំមានអានុភាពទាល់តែសោះ ចាប់ពីពេលបង្កើតមក។<br>➢ ករណីនៃមោឃភាពអាពាហ៍ពិពាហ៍៖ មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី។ | ➢ ភាពផ្ទុយច្បាប់ មានកម្រិតទាបជាងករណីនៃមោឃភាពដូចនេះ អាពាហ៍ពាពិពាហ៍ត្រូវមានអានុភាពរហូតដល់ពេលលុបចោល។<br>➢ ករណីនៃការលុបចោលអាពាហ៍ពិពាហ៍ (មាត្រា ៩៦០ ដល់មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី) |

### ៣.៤.២. អ្នកមានសិទ្ធិលុបចោលអាពាហ៍ពិពាហ៍

ចំពោះបុគ្គលដែលមានសិទ្ធិទាមទារឱ្យលុបចោលមានដូចជា ភាគីណាមួយនៃអាពាហ៍ពិពាហ៍ ឬញាតិរបស់ជននោះ ឬតំណាងអយ្យការ អាចទាមទារតុលាការឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។[១១៨]

---

[១១៧] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងគ្រួសារ, ទំព័រ ៣៣២ និង៣៣៣, បោះពុម្ពលើកទី២ ឆ្នាំ ២០២២។

[១១៨] ហេង បូរ៉ា, នីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី ៣៨, ឆ្នាំ២០២១។

- **ភាគីណាមួយនៃអាពាហ៍ពិពាហ៍៖** ភាគីណាម្ខាងដែលបានដឹងពីភាពមិនប្រក្រតីចំពោះអាពាហ៍ពិពាហ៍របស់ខ្លួនដែលមានលក្ខខណ្ឌចាំបាច់ក្នុងការហាមឃាត់ដូចជា មិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍ជាមួយញាតិលោហិត ឬញាតិពន្ធ ទ្វេពន្ធភាព និងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី ការឆបោក ឬដោយការគំរាមកំហែង នោះភាគីនៃអាពាហ៍ពិពាហ៍អាចប្ដឹងទៅតុលាការដើម្បីសុំលុបចោលអាពាហ៍ពិពាហ៍នោះបាន។
- **ញាតិសណ្ដានរបស់ភាគី៖** ចំពោះសាច់ញាតិរបស់ភាគីនីមួយៗ ក៏អាចដាក់ពាក្យបណ្ដឹងឱ្យលុបចោលអាពាហ៍ពិពាហ៍បានដូចគ្នា ប្រសិនបើដឹងថា អាពាហ៍ពិពាហ៍នោះបានផ្ទុយពីបញ្ញត្តិនៃ មាត្រា៩៦០ នៃក្រមរដ្ឋប្បវេណី ដែលមានចែងអំពី ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់កំណត់។
- **តំណាងអយ្យការ៖** តំណាងអយ្យការអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍បានប្រសិនបើយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ។

ប៉ុន្តែ ក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍បានឡើយ។

### ៣.៤.៣. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ភាគីដែលមិនបានដឹងពីមូលហេតុនៃការលុបចោលនៅពេលអាពាហ៍ពិពាហ៍ ប្រសិនបើបានទទួលទ្រព្យសម្បត្តិ ដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះ ត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួល។ ប៉ុន្តែបើភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ។ ចំពោះកូនដែលបានកើតចេញនៅក្រោយពេលអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ដែលមានក្នុងចំណងអាពាហ៍ពិពាហ៍នោះ។[១១៩]

ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួច សហព័ទ្ធនោះនឹងទទួលបានអានុភាពពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន ដែលប្ដី និងប្រពន្ធអាចរស់នៅជាមួយគ្នាយ៉ាងរីករាយ និងមានសុភមង្គល។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អាពាហ៍ពិពាហ៍នោះត្រូវតែគោរពតាមបញ្ញត្តិច្បាប់ដើម្បីធានាថា វាមិនត្រូវបានលុបចោល ឬទុកជាមោឃៈតាមមធ្យោបាយផ្លូវច្បាប់នោះឡើយ។

[១១៩] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧, មាត្រា ៩៦៤។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ ការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈយ៉ាងស្របច្បាប់ និងត្រូវបានច្បាប់ទទួលស្គាល់ លុះត្រាតែបុរស និងស្ត្រី ដែរមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវគោរពតាមលក្ខខណ្ឌ និងនីតិវិធីច្បាប់ ដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងច្បាប់ពាក់ព័ន្ធនានាទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តួយ៉ាងទោះបីជាការរៀបអាពាហ៍ពិពាហ៍ខ្មែរមានលក្ខខណ្ឌបែបបទ និងនីតិវិធីច្រើនយ៉ាងក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជាមួយចំនួនតូចពួកគាត់នៅមិនបានយល់ដឹងគ្រប់គ្រាន់ និងមិនបានអនុវត្តឱ្យបានពេញលេញនោះទេ គឺពួកគាត់នៅតែប្រកាន់ខ្ជាប់ថា រៀបអាពាហ៍ពិពាហ៍តាមប្រពៃណីនេះ គឺជាការត្រឹមត្រូវទៅតាមច្បាប់ទៅវិញ។ ជាក់ស្តែង វាក៏ត្រឹមត្រូវទៅតាមប្រពៃណីពិតប្រាដកមែន ប៉ុន្តែមិនទាន់ត្រឹមត្រូវទៅតាមច្បាប់កំណត់នោះទេ កាលដែលរៀបអាពាហ៍ពិពាហ៍ត្រឹមតែលោកមេបា ញាតិជិតឆ្ងាយដឹងឮ ដោយមិនបានបំពេញតាមលក្ខខណ្ឌច្បាប់តម្រូវនោះ ជាហេតុនាំឱ្យគូរភាគីជាប្តីប្រពន្ធក្លាយជាអនីតិសង្វាស ហើយជីវិតអាពាហ៍ពិពាហ៍នោះមិនត្រូវបានការពារដោយច្បាប់ឡើយ។ ជាក់ស្តែងយើងសង្កេតឃើញថា ក៏នៅមានប្រជាពលរដ្ឋខ្មែរមួយចំនួន ពួកគាត់បានយល់ដឹងអំពីទំនាក់ទំនងផ្លូវច្បាប់មុននឹងសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយពួកគាត់បានគោរព និងអនុវត្តតាមអ្វីដែរច្បាប់បានកំណត់ទៅលើលក្ខខណ្ឌគ្រឹះ លក្ខខណ្ឌទម្រង់ និងនីតិវិធីផ្សេងៗយ៉ាងខ្ជាប់ខ្ជួនចាប់តាំងពីនីតិវិធី មុនរៀបអាពាហ៍ពិពាហ៍ អំឡុងពេលរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដែលស្របច្បាប់របស់ពួកគេផងដែរ។ ដោយលក្ខខណ្ឌគ្រឹះ ជាលក្ខខណ្ឌដែលអនុញ្ញាតឱ្យអនាគតគូស្វាមី និងភរិយាអាចដំណើរការនៃគម្រោងអាពាហ៍ពិពាហ៍របស់ខ្លួនបាន តែភាគីទាំងសងខាងក៏ត្រូវតែគោរពទៅតាមលក្ខខណ្ឌដែលបានតម្រូវដូចជា អាយុ ភេទ ការស្ម័គ្រចិត្ត និងការយល់ព្រមពីឪពុកម្តាយនៅពេលដែលភាគីម្ខាងបានដល់នីតិភាព និងភាគីម្ខាងទៀតនៅជាអនីតិជននៅឡើយ ជាអាទ៍។ នៅពេលដែលគូរភាគីទាំងសងខាងបានអនុវត្តតាមលក្ខខណ្ឌគ្រឹះរួចហើយនោះ ពេលនោះពួកគេត្រូវគោរពទៅតាមលក្ខខណ្ឌទម្រង់ដែលជាលក្ខខណ្ឌសំខាន់ក្នុងដំណើរការនីតិវិធីចាប់តាំងពី ការដាក់ពាក្យស្នើសុំអនុញ្ញាតរៀបអាពិពាហ៍ពិពាហ៍ រហូតដល់ចេញសំបុត្រអាពាហ៍ពិពាហ៍ដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ ដែលនាំឱ្យអាពាហ៍ពិពាហ៍នោះអាចប្រព្រឹត្តទៅមុខបាន និងមានអានុភាពជាអាពាហ៍ពិពាហ៍មួយដ៏ស្របច្បាប់។

ទោះបីជាយ៉ាងណាក៏ដោយ អាពាហ៍ពិពាហ៍របស់ពួកគេអាចឈានដល់ការមោឃភាព ឬមានការលុបចោលជាផងដែរ។ ការមោឃភាពអាពាហ៍ពិពាហ៍មួយ គឺដោយសារតែភាគីនៃអាពាហ៍ពិពាហ៍នោះបានរំលងនូវនីតិវិធីណាមួយដែលច្បាប់បានកំណត់តម្រូវឱ្យពួកគេធ្វើតាម ដូចជាភាគីពុំមិនបានដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍, ពុំបានជូនដំណឹងជាសាធារណៈ, មិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងភាគីមិនបាន

បំពេញបែបបទក្នុងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅមុខមន្ត្រីអត្រានុកូលដ្ឋានជាអាទិ៍។ ចំណែកឯការលុបចោលនៃអាពាហ៍ពិពាហ៍វិញ ក៏អាចកើតមានឡើងផងដែរ ក្នុងករណីដែលពួកគេមិនបានគោរពលក្ខខណ្ឌច្បាប់ ពោលគឺធ្វើខុសពីអ្វីដែលច្បាប់កំណត់ ដូចជា ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនដែលធ្វើខុសពីលក្ខខណ្ឌដែលអនីតិជនអាចរៀបការបាន អាពាហ៍ពិពាហ៍ជាមួយនឹងញាតិដែលច្បាប់បានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាពាហ៍ពិពាហ៍ក្នុងអំឡុងពេលដែលច្បាប់បានហាមឃាត់ អាពាហ៍ពិពាហ៍ដោយការឆបោក និងគំរាមកំហែងភាគីម្ខាងទៀត អាពាហ៍ពិពាហ៍ដោយមូលហេតុមានការភាន់ច្រឡំទៅលើមនុស្ស អាពាហ៍ដោយមូលហេតុបង្ខិតបង្ខំ និងមូលហេតុផ្សេងៗទៀតជាដើម។ ហេតុនេះហើយបានជាការរៀបអាពាហ៍ពិពាហ៍មួយដាច់ខាតត្រូវតែគោរពទៅតាមអ្វីដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងច្បាប់ទាក់ទងផ្សេងៗទៀតបានកំណត់ បើពុំដូច្នោះទេ អាពាហ៍ពិពាហ៍របស់ពួកគេនឹងអាចត្រូវបានមោឃភាព ឬមានការលុបចោលនូវអាពាហ៍ពិពាហ៍នោះដោយប្រការណាមួយជាក់ជាមិនខាន។

សរុបសេចក្តីមក នៅក្នុងសង្គមមួយ ការកសាងគ្រួសារពិតជាសំខាន់ណាស់។ ប៉ុន្តែការកសាងគ្រួសាររបស់ប្រជាពលរដ្ឋនីមួយៗ មិនប្រាកដថាពួកគេបានគោរពទៅតាមវិធានច្បាប់ដែលបានចែងនោះទេ។ ការដែលសាមីប្តីប្រពន្ធមិនគោរពទៅតាមច្បាប់នោះ ធ្វើឱ្យអាពាហ៍ពិពាហ៍របស់ពួកគេមិនមានអានុភាព ហើយមិនត្រូវបានច្បាប់ទទួលស្គាល់ និងមិនមានការការពារដោយច្បាប់នោះឡើយ។

ហេតុនេះហើយបានជា ការយល់ដឹងពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ពិតជាមានសារៈសំខាន់ណាស់ ហើយការដែលរៀបអាពាហ៍ពិពាហ៍ធ្វើតាមច្បាប់រឹតតែមានសារៈសំខាន់ទៅទៀត ព្រោះថា អាពាហ៍ពិពាហ៍ស្របច្បាប់ ជាចំណងរឹតបណ្តឹងនូវគូរស្វាមី ភរិយាឱ្យកាន់តែរឹងមាំ និងយូរអង្វែង។ ជាពិសេសនោះគឺចំណងគតិយុត្តស្របច្បាប់នៃអាពាហ៍ពិពាហ៍មួយបានកំណត់ពីឋានៈ និងកាតព្វកិច្ចដែលដៃគូរទាំងសងខាងមានចំពោះគ្នា និងមានអានុភាពនានាដែលកើតមានបន្ទាប់ពីពួកគេបានរៀបអាពាហ៍ពិពាហ៍ស្របតាមលក្ខខណ្ឌច្បាប់នឹងគ្នារួច។ ច្បាប់ក៏បានគិតគូរផងដែរពីអនាគតកូនដែលបានមកពីចំណងនៃអាពាហ៍ពិពាហ៍នោះ ដោយផ្តល់ឱ្យនូវភាពជាម្តាយឪពុកសម្រាប់កូនដែលកើតមក និងការរស់នៅក្នុងសង្គមដោយពុំមានការភ័យខ្លាចពីសង្គមខាងក្រៅថាខ្លួនជាកូនឥតខាន់ស្លា ឬអ្វីផ្សេងឡើយ។ ពិតណាស់អាពាហ៍ពិពាហ៍ គឺជាចំណងភ្ជាប់ឱ្យសហព័ទ្ធបំពេញនូវកាតព្វកិច្ច សិទ្ធិ និងករណីកិច្ចមួយចំនួនដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ក៏ដូចជាការមានទំនួលខុសត្រូវលើកូន និងឪពុកម្តាយទាំងសងខាង លើសពីនេះសហព័ទ្ធត្រូវត្រូវចេះសហការគ្នាទៅវិញទៅមក ផ្តល់នូវសិទ្ធិសេរីភាពដល់គ្នា អនុគ្រោះឱ្យគ្នា គោរពនូវឆន្ទៈគ្នាទៅវិញទៅមក និងចេះគ្រប់គ្រងទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលរៀបអាពាហ៍ ទើបគ្រួសារមួយនោះ ទទួលបាននូវភាពសុខសុភមង្គល។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមអនុសាសន៍របស់នាងខ្ញុំទាំងពីរនាក់ ក្រោយពីសិក្សាស្រាវជ្រាវ យកមកសរសេរ និងរៀបចំចេញជាសារណាក្រោមប្រធានបទ « **អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា** » នាងខ្ញុំទាំងពីរនាក់យល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តច្បាប់ទាក់ទៅនឹងអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន គឺមានភាពខ្វះចន្លោះនៅឡើយ។ អាស្រ័យហេតុនេះទើបក្រុមនាងខ្ញុំសូមបញ្ចេញនូវគំនិតយោបល់បន្តិចបន្តួច ក្នុងគោលបំណងដើម្បីធ្វើការកែតម្រូវ និងដើម្បីជាផលប្រយោជន៍បន្ថែមដូចជា៖

- អង្គការ និងស្ថាប័នពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ត្រូវផ្សព្វផ្សាយជាសារធារណៈតាមគ្រប់មធ្យោបាយ ឱ្យបានញឹកញាប់ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទំលាប់ប្រពៃណីជាតិ និងស្របទៅតាមលក្ខខណ្ឌច្បាប់កំណត់។ ជាពិសេសបុគ្គលដែលបានរួមរស់ជាមួយគ្នាជាអនីតិសង្វាសជន ធ្វើយ៉ាងណាណែនាំបុគ្គលទាំងនោះឱ្យងាកទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា ដើម្បីក្លាយជាប្តីប្រពន្ធពេញច្បាប់ និងដោយពន្យល់បន្ថែមពីបែបបទនៃការកសាងគ្រួសារមួយដែលមានភាពសុខដុមរមនាតទៅ។
- អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកពាក់ព័ន្ធទាំងអស់ គប្បីត្រួតពិនិត្យឱ្យបានម៉តចត់ នៅពេលភាគីទាំងសងខាងបានមកស្នើសុំលិខិតរៀបអាពាហ៍ពិពាហ៍ និងពន្យល់បន្ថែមនូវគុណសម្បត្តិនៃអាពាហ៍ពិពាហ៍ និងគុណវិបត្តិប្រសិនបើភាគីមិនបានគោរពនូវលក្ខណ្ឌច្បាប់បានកំណត់ណាមួយ។
- ប្រជាពលរដ្ឋត្រូវមានការចូលរួមជាចាំបាច់ ក្នុងការក្នុងការផ្សព្វផ្សាយ អប់រំ អំពីការរៀបអាពាហ៍ពិពាហ៍មួយនេះ ជាពិសេសមុននឹងរៀបអាពាហ៍ពិពាហ៍ បុរស និងស្ត្រីគួរគប្បីសម្រេចចិត្តឱ្យបានច្បាស់លាស់មុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងត្រូវគោរពទៅតាមច្បាប់ជាធរមាន ជៀសវាងការរៀបអាពាហ៍ពិពាហ៍ដោយមិនស្របច្បាប់ ព្រោះនេះដើម្បីជាផលប្រយោជន៍ចំពោះសហព័ទ្ធទាំងខាងនាពេលអនាគត។
- ម្យ៉ាងទៀតមុននឹងរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុគ្គលណាម្នាក់ គួរណាស់តែសិក្សាស្វែងយល់ពីប្រវត្តិអត្តចរិត ចិត្តថ្លើមគ្នានឹងគ្នាឱ្យបានច្បាស់លាស់ជាមុនសិន។ មិនតែប៉ុណ្ណោះ ភាគីទាំងសងត្រូវយល់ដឹងអំពីបញ្ហាច្បាប់ អនុក្រឹត្យ ព្រមទាំងបទដ្ឋានគតិយុត្តនានាដែលបានចែងជាធរមានផងដែរ។
- ប្រជាពលរដ្ឋគួរតែជ្រើសរើសការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទំលាប់ប្រពៃណីដែរបានបន្សល់ទុកពីបុរាណមក ជាជាងរើសយកវប្បធម៌ពីបរទេស ឬលាយបញ្ចូលគ្នារវាងអាពាហ៍ពិពាហ៍ខ្មែរ និងបរទេស ទោះពិធីនោះរៀបចំឡើងធំដុំ ឬតិចតួចក៏ដោយ ពីព្រោះធ្វើឱ្យកូនចៅជំនាន់ក្រោយមានការភាន់ច្រឡំ។

# ឯកសារយោង

# ឯកសារយោង


❖ **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ២៤ កញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩២០
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ៥៦/ក្រ, ១៧ កក្កដា ឆ្នាំ១៩៨៩
- ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ០១ កញ្ញា ២០០៦
- ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ០១ ខែកក្កដា ឆ្នាំ២០២៣
- អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន, ២៩ ធ្នូ ឆ្នាំ២០០០
- ប្រកាសស្តីពីនីតិវិធីនៃការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១/កយប្រក/១៣, ០៩ សីហា ឆ្នាំ២០១៤
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០០៩ - ២០១០

❖ **ស្នាដៃរបស់អ្នកនិពន្ធ**

- ឆយ យីហ៊ាង, ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ, ឆ្នាំ២០០៨
- ងីម ហួរ, អរិយធម៌ខ្មែរ, ឆ្នាំ២០១៤
- ប៊ួយ ធីតា, នីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០២៤
- រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួសស្មារតី នីតិព្រហ្មទណ្ឌ និងគ្រួសារ, បោះពុម្ពលើកទី២, ឆ្នាំ២០២២
- ហេង បូរ៉ា, នីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, បោះពុម្ព ឆ្នាំ២០២១
- គន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ឆ្នាំ២០២១, ភាគ១

❖ **គេហទំព័រ**

- ដកស្រង់ចេញពីគេហទំព័រ https://search.app/oDriBNqKKuAooTvt5
- គេហទំព័រ https://kroukhen.wordpress.com/wp-content/uploads/2009/12/story-kh.pdf
- គេហទំព័រ http://konkhmerone.blogspot.com/2019/02/blog-post.html?m=1

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- **ឧបសម្ព័ន ទី១៖** ពាក្យសុំរៀបអាពាហ៍អាពិពាហ៍
- **ឧបសម្ព័ន ទី២៖** ពាក្យសុំបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬ ពោះម៉ាយ
- **ឧបសម្ព័ន ទី៣៖** លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬ ពោះម៉ាយ
- **ឧបសម្ព័ន ទី៤៖** សំបុត្រកំណើត
- **ឧបសម្ព័ន ទី៥៖** សេចក្តីចម្លងសំបុត្រកំណើត
- **ឧបសម្ព័ន ទី៦៖** សំបុត្របញ្ជាក់កំណើត
- **ឧបសម្ព័ន ទី៧៖** សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- **ឧបសម្ព័ន ទី៨៖** សៀវភៅគ្រួសារ
